01134434

E1/335.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Aug-2015, 11:07
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៣១៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា រ៉ូប៊ីន្នី គ្រុហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ត្រាវីស ហ្វារ *(Mr.Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន
*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៃ ជុនធី

លោក វ៉េន ពៅ

លោក សំ សុគង់

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេន៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ឈុយ ហ៊ុយ (2-TCW-915) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឈុយ ហ៊ុយ** (2-TCW-915)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............ទំព័រ ២
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្ដើមពី ............ទំព័រ ៦
សួរដោយលោក ពេជ អង្គ ផ្ដើមពី ............ទំព័រ ៣១
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី............ទំព័រ ៣៩
សួរដោយលោក លីវ សុវណ្ណា ផ្ដើមពី ............ទំព័រ ៤៩
សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី ............ទំព័រ ៥២
សួរដោយលោក គង់ សំអុន ផ្ដើមពី ............ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-915។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-915។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះមុននឹងផ្តល់សក្ខីកម្ម ហើយសាក្សីរូបនេះមានមេធាវីប្រឹក្សាលោកមេធាវី មឿន សុវណ្ណ។ នៅថ្ងៃនេះដែរ មានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-269។ សូមអរគុណលោកប្រធាន។

[០៩:០៦:០៥]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ ហើយមុននឹងអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះ

បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ដែលបានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះជាប្រចាំ ហើយមិនអាចអង្គុយបានយូរ និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៧:១៣]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី រួមទាំងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:៣៩]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី! តើលោកឈ្មោះអី?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទឈ្មោះ ឈុយ ហ៊ុយ។

**ស៖** អរគុណលោក ឈុយ ហ៊ុយ។ តើលោកកើតនៅថ្ងៃខែឆ្នាំណា? លោកចាំដែរឬទេ?

**ឆ៖** ឆ្នាំរោង។

**ស៖** លោកចាំឆ្នាំបារាំងបានទេ មួយពាន់ប្រាំបួនរយហាប៉ុន្មាន?

**ឆ៖** ១៩៥៧។

**ស៖** អរគុណលោក ឈុយ ហ៊ុយ។ ហើយតើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** នៅភូមិថ្មី។

**ស៖** លោកមានទីកន្លែងកំណើតនៅទីកន្លែងណា លោករៀបរាប់អំពីភូមិណា ឃុំណា ស្រុកណា ខេត្តណានៃប្រទេសកម្ពុជាណ៎ា ប្រសិនបើកើតនៅក្នុងប្រទេសកម្ពុជា។

[០៩:១១:២០]

**ឆ៖** បាទ នៅភូមិថ្មី ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

**ស៖** បាទ អរគុណ។ ហើយចុះទីកន្លែងកំណើតបច្ចុប្បន្ន តើលោកកើតនៅ -- ទីកន្លែងរស់នៅ រស់នៅសព្វថ្ងៃ តើលោករស់នៅទីកន្លែងណា?

**ឆ៖** បាទ នៅភូមិថ្មី ណាំតៅ។

**ស៖** នៅទីកន្លែងដដែល អ៊ីចឹងណ៎ា?

**ឆ៖** បាទ ភូមិថ្មីដដែលនុ៎ង។

**ស៖** អ៊ីចឹងបានសេចក្ដីថា ទីកន្លែងកំណើតអង្កាល់ពីនោះ គឺមិនមែនខេត្តបន្ទាយមានជ័យទេ គឺខេត្តបាត់ដំបង អ៊ីចឹងមែនទេ? កាលពីសង្គមចាស់ កាលពីមុនហ្នឹង គឺខេត្តបាត់ដំបងទេ កន្លែងដែលលោករស់នៅ ដែលលោកកើតនោះ?

**ឆ៖** បាទ នៅខេត្តបាត់ដំបង។

**ស៖** សព្វថ្ងៃនេះ តើលោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** បាទ មុខរបរធ្វើស្រែចម្ការបាទ។

**ស៖** អរគុណ។ ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឈ្មោះ – ឪពុកឈ្មោះ ឈឹង ឈុយ។ ម្ដាយឈ្មោះ ញ៉ឹប សឺន។

[០៩:១៣:១១]

**ស៖** អរគុណ។ ហើយប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ឈ្មោះ ឈឿង តឹក។ កូនប្រាំមួយនាក់។

**ស៖** អរគុណលោក ឈុយ ហ៊ុយ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ញាតិលោកហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាបចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន និងបុគ្គលដែលត្រូវទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើពិតមែនដែរទេ?

**ឆ៖** អត់មានទេ។

**ស៖** ហើយក្រឡាបញ្ជីថា លោកបានស្បថរួចហើយមុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។ តើពិតមែនទេ?

**ឆ៖** បាទ រួចហើយ។

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះលោក។ ឈុយ ហ៊ុយ ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងកិច្ចដំណើរការសវនាការនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច លោក ឈុយ ហ៊ុយ ក្នុងនាមលោកជាសាក្សី ត្រូវតែឆ្លើយរាល់សំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរបស់លោក ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់សាក្សីរួចមកហើយអម្បាញ់មិញនេះ។

[០៩:១៥:០៥]

ហើយក្នុងឋានៈជាសាក្សី លោកមានកាតព្វកិច្ចត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំ-ជម្រះសួរចំពោះលោក។ លោក ឈុយ ហ៊ុយ តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ កន្លងមក? ហើយបើធ្លាប់តើបានធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? នៅពេលណា? លោកចាំដែរទេ?

**ឆ៖** បាទ បានធ្វើម្តងនៅភូមិថ្មីខាងត្បូង។

**ស៖** ចាំថា ធ្វើនៅពីពេលណាទេ លោកចាំទេ?

**ឆ៖** អត់ចាំផង។

**ស៖** អរគុណ។ ហើយនៅមុនចូលមកនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុន ដែលលោកនិយាយអំមិញថា បានធ្វើនៅភូមិថ្មីត្បូងហ្នឹង ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** ចាំមិនបានផង ភ្លេចច្រើន។

[០៩:១៦:៤០]

**ស៖** តើលោកបានអាន ឬក៏បានស្តាប់អ្នកណាអានឲ្យស្តាប់ទេ អម្បាញ់មិញហ្នឹងមុននឹងចូលមកនេះ?

**ឆ៖** បានអាន ប៉ុន្តែអានរួចភ្លេច។

**ស៖** ហើយក្រោយពីអាន តាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំ តើលោកបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានផ្តល់សក្ខីកម្មកាលពីលើកមុននៅហ្នឹងភូមិចិនខាងត្បូង -- នៅភូមិថ្មីខាងត្បូងហ្នឹង ហើយពិតជាត្រឹមត្រូវ ស៊ីសង្វាក់ស្របគ្នានឹងចម្លើយដែលលោកបានធ្វើសម្ភាសកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ បានឯកភាពជាមួយគាត់អស់ហើយ។

**ស៖** លោក ឈុយ ហ៊ុយ នៅពេលនេះ លោកបានទទួលជំនួយមេធាវីប្រឹក្សាដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឲ្យលោក តាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ តាមសំណើរបស់លោកហើយ គឺលោកមេធាវី មឿន សុវណ្ណ។ ហើយតើលោកបានប្រឹក្សាយោបល់ ជាមួយនឹងមេធាវីប្រឹក្សារបស់លោករួចហើយឬនៅ មុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ?

**ឆ៖** មានយោបល់អីទៀត និយាយអត់កើត។

**ប្រធានអង្គជំនុំ៖**

បាទ ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ឈុយ ហ៊ុយ មុនភាគីដទៃទៀតនៃរឿងក្តី។ ភាគីសហព្រះរាជអាជ្ញា

រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:១៩:០០]

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ សុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ ហើយនៅព្រឹកនេះ ខ្ញុំមានសំណួរមួយចំនួនដើម្បីសាកសួរទៅលោក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិចថា មុនឆ្នាំ១៩៧៥ ថ្ងៃ១៧ មេសា តើលោករស់នៅកន្លែងណា? ហើយលោកធ្វើអីដែរ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំបាទបានទៅបួសនៅវត្ត។

**ស៖** លោកចាំទេថា លោកបានបួសហ្នឹង បួសនៅក្នុងឆ្នាំណាដែរ? ហើយលោកថា លោកបួសនៅវត្ត តើវត្តឈ្មោះអី?

[០៩:២០:០៤]

**ឆ៖** បួសនៅឆ្នាំ១៩៥៧ វត្តណាំតៅ។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ម្តងទៀត លោកថាលោកបួស។ លោកចាំទេថាលោកបួសនៅអាយុប៉ុន្មានដែរ? នៅពេលដែលលោកមានអាយុប៉ុន្មាន?

**ឆ៖** អាយុ២១។

**ស៖** ហើយលោកបានបួសប៉ុន្មានឆ្នាំដែរ?

**ឆ៖** បួសបាន២ឆ្នាំ។

**ស៖** អ៊ីចឹងលោកបួសហ្នឹង បួសមុនឆ្នាំ១៩៧៥ ១៧ មេសា ឬក៏បួសនៅក្នុងអំឡុងឆ្នាំណា? លោកនៅចាំទេ? មុនរបបខ្មែរក្រហម ឬក៏នៅក្នុងអំឡុងរបបខ្មែរក្រហម ឬក៏ក្រោយរបបខ្មែរក្រហម?

**ឆ៖** បាទ មុនរបបខ្មែរក្រហម។

**ស៖** ចុះនៅក្នុងភូមិឃុំរបស់លោកហ្នឹង ខ្មែរក្រហមរំដោះបាននៅក្នុងឆ្នាំណាដែរ? លោកចាំទេ?

**ឆ៖** មិនបានជាចាំទេ។

**ស៖** ចុះលោកថាលោកបួសបាន២ឆ្នាំហ្នឹង បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ ឬរំដោះបានហ្នឹង លោកនៅបួស ឬក៏លោកឈប់បួស? ហើយប្រសិនបើឈប់បួស ដោយសារមូលហេតុអ្វី?

**ឆ៖** ឈប់បួស ដែលមានសង្គ្រាម ពួក ប៉ុល ពត វាអុជភូមិឆេះ អុជវត្ត។

**ស៖** លោកឈប់បួសដោយសារតែគេអុជវត្ត។ លោកចង់បានន័យថាម៉េច? អ្នកណាអ្នកអុជវត្ត ឬក៏ដុតវត្តហ្នឹង?

**ឆ៖** បាទ ខ្ញុំមិនដឹងថាអ្នកណាទេ អុជវត្ត អុជភូមិឆេះ នៅវត្តអត់បាន។

[០៩:២៣:១២]

**ស៖** លោកសាក្សីនៅក្នុងចម្លើយរបស់លោក ដែលឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៅត្រង់ឯកសារ E3/5283។ លោកបាន -- នៅត្រង់ ERN ជាភាសាខ្មែរគឺ 00295941, នៅត្រង់ ERN ជាភាសាអង់គ្លេសគឺ 00321196, ជាភាសាបារាំង 00702918។ លោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា៖ "នៅពេលដែលពួក ប៉ុល ពត ចូលមកដល់ ពួកវាធ្វើការដុតវត្ត និងបណ្ដេញព្រះសង្ឃចេញពីវត្តទាំងអស់។" អ៊ីចឹងខ្ញុំចង់សួរលោកបញ្ជាក់ពីព្រឹត្តិហេតុមួយនោះ។ តើនៅពេលដែល ប៉ុល ពត ចូលមកដុតវត្តហ្នឹង លោកនៅកន្លែងណា? ហើយស្ថានភាពពេលនោះយ៉ាងម៉េចដែរ?

**ឆ៖** បាទ ខ្ញុំក៏បានគេច។ ផ្សឹកជា ហៅថា បានសឹកមកដើម្បីនឹងជម្លៀសទៅតាមភូមិនានា។

**ស៖** ចុះលោកគេចចេញ ឈប់បួសហ្នឹង ដោយសារលោកសម្រេចចិត្តខ្លួនឯង ឬក៏ត្រូវបានគេបង្ខំឲ្យផ្សឹក ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ដោយសារនៅមិនបាន ក៏ភ័យភិតទៅ រត់ទៅតាមភូមិនានា លំបាកច្រើន នៅអត់បាន។

**ស៖** ចុះក្រោយពី ប៉ុល ពត ចូលមកដុតវត្ត ហើយបណ្ដេញព្រះសង្ឃចេញហ្នឹង តើលោកបានរត់ទៅដល់ណាដែរ?

[០៩:២៥:២០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំទើបឮសាក្សីឆ្លើយថា អត់ដឹងទេ មិនដឹងថាអ្នកណាដែលអុជវត្តហ្នឹងទេ។ អាចថាជាទាហាន លន់ នល់ ក៏ថាបាន យើងអត់ដឹងទេ។ ដូច្នេះជាសរុប ជាសង្ខេបមកគឺថា គឺការដែលសួរថាតើខ្មែរក្រហមជាអ្នកដុត ឬវត្តនោះ ឬក៏អត់នោះ គឺថាមិនត្រឹមត្រូវទេ។

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន ខ្ញុំបានយោងទៅនឹងឯកសារដែលសាក្សីបានឆ្លើយហើយៗ។ ហើយមុននឹង ខ្ញុំបានសួរបញ្ជាក់គាត់ទៀត ប៉ុន្តែដើម្បីឲ្យមានភាពច្បាស់លាស់ ខ្ញុំអាចសួរបញ្ជាក់គាត់ម្តងទៀត។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកសាក្សី តើនៅពេលដែលលោកនិយាយថា មានការដុតវត្ត ហើយដេញព្រះសង្ឃចេញហ្នឹង តើអ្នកណាជាអ្នកដុតវត្ត? តើជាទាហាន លន់ នល់ ឬក៏ ប៉ុល ពត – ខ្មែរក្រហម?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំបាទក៏មិនដឹងដែរ។ ស្រាប់តែឃើញឆេះ ក៏គេចខ្លួនបាត់ទៅតាមភូមិនានា នៅភូមិស្វាភីបាទ។

**ស៖** ចុះនៅពេលដែលលោករត់ទៅដល់ភូមិស្វាភីហ្នឹង តើលោកទៅធ្វើអីនៅកន្លែងហ្នឹង?

**ឆ៖** ទៅនៅឲ្យហៅថា ផុតខ្លាច។

[០៩:២៧:១០]

**ស៖** លោកទៅនៅភូមិស្វាភីហ្នឹង តើនៅក្នុងអំឡុងពេលដែលលោករត់ទៅដល់ហ្នឹង លោកចាំទេថា នៅក្នុងខែឆ្នាំណាដែរ?

**ឆ៖** អត់បានជាគិតទេ អត់បានចងចាំផង។

**ស៖** តើលោកធ្លាប់ធ្វើការនៅក្នុងកងចល័តតំបន់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទបាន ហៅថាធ្វើការលើកដីនៅអាងត្រពាំងថ្ម។

**ស៖** ចុះលោកចាប់ផ្តើមធ្វើការនៅក្នុងអាងត្រពាំងថ្មហ្នឹងនៅក្នុងឆ្នាំណា? ចាប់ផ្តើមពីពេលណាដល់ពេលណាដែរ លោកនៅចាំទេ?

**ឆ៖** អត់បានចងចាំផង។

**ស៖** ចុះនៅពេលដែលលោកទៅដល់អាងត្រពាំងថ្មហ្នឹង គេឲ្យលោកធ្វើអី? ហើយមានតួនាទីអ្វីដែរ?

**ឆ៖** បាទ គេឲ្យនាំរែកដី រែកទំនប់។

**ស៖** ចុះលោកដឹងទេថា នៅក្នុងអាងត្រពាំងថ្មហ្នឹងអ្នកណាជាអ្នកគ្រប់គ្រង?

**ឆ៖** បាទ ឮគេហៅតាមពាក្យគេថា ឈ្មោះថា តាវ៉ាល់។

[០៩:២៩:៤៥]

**ស៖** លោកសាក្សី ខ្ញុំចង់សួរបញ្ជាក់លោកម្តងទៀត។ នៅពេលដែលលោកទៅដល់អាងទំនប់ត្រពាំងថ្មហ្នឹង តើលោកធ្លាប់មានតួនាទីអ្វីផ្សេង ក្រៅពីគេឲ្យលោកទៅធ្វើការដូចប្រជាពលរដ្ឋដទៃទេ? តួនាទីក្នុងការមើល ឬក៏គ្រប់គ្រងនៅក្នុងកងចល័តអ្វីជាដើម?

**ឆ៖** បាទ គេឲ្យទទួលខុសត្រូវក្នុងកង។ ចាត់ដោយខ្មែរក។

**ស៖** គេឲ្យលោកទទួលខុសត្រូវកងហ្នឹង មួយកងហ្នឹងមានគ្នាប៉ុន្មាននាក់? ហើយលោកជាប្រធាន ជាអនុប្រធាន ឬក៏ជាសមាជិកកង?

**ឆ៖** ជាមេកងចំនួន៥៥នាក់។

**ស៖** លោកជាមេកងហ្នឹងជាមេកងធំ ឬក៏មេកងតូច ឬក៏ជាប្រធានវរៈជាអីដែរ? សូមលោកបញ្ជាក់ឲ្យច្បាស់។

**ឆ៖** ជាមេកងធំ។

**ស៖** លោកជាមេកងធំទីប៉ុន្មានដែរ? ហើយមានប៉ុន្មានកងធំ?

**ឆ៖** ចាំ -- ភ្លេចហើយ អានេះប៉ុន្មានកងធំ ខ្ញុំចាំមិនបាន ច្រើន មានច្រើន។

**ស៖** ចុះលោកជាមេកង ឬក៏ជាប្រធានកងហ្នឹង ប្រធានកងទីប៉ុន្មាន? លោកចាំទេ?

**ឆ៖** ចាំអត់បានទេ ភ្លេចហើយ យូរហើយ។

**ស៖** នៅក្នុងចម្លើយដែលលោកធ្លាប់ឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេត គឺនៅត្រង់ ERN ជាភាសាខ្មែរ 00295942, ជាភាសាអង់គ្លេស 00321197, ជាភាសាបារាំង 00702919។ លោកបានឆ្លើយថា៖ “គេតែងតាំងខ្ញុំជាប្រធានកងធំទី១”។ តើព័ត៌មានដែលលោកផ្តល់ឲ្យអ្នកស៊ើបអង្កេត ពេលនុ៎ងលោកនៅចាំបានទេ?

[០៩:៣៣:២០]

**ឆះ** បាទ រយ: -- ច្រើនពេក ខ្ញុំចាំមិនបាន ភ្លេចអស់។

**សះ** ចុះមេវរ: ប្រធានវរ: លោកនៅចាំបានទេ? គាត់មានឈ្មោះអ្វីដែរ?

**ឆះ** នៅភូមិផ្សេង ភ្លេច។

**សះ** ខ្ញុំយោងទៅដល់ចម្លើយ ដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតដដែលហ្នឹង គឺនៅត្រង់ ERN ជាភាសាខ្មែរដដែល ជាភាសាអង់គ្លេសគឺនៅ ERN ដដែល ហើយជាភាសាបារាំងក៏ ERN ដដែលដែរ។ គឺលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា ខ្ញុំដកស្រង់៖ "កងរបស់ខ្ញុំនៅក្រោមប្រធានវរៈដែលដឹកនាំដោយឈ្មោះ ឈ្លូង (ឮថានៅសៀមរាប តែមិនដឹងស្លាប់ ឬរស់) ហើយនៅលើ តាឈ្លូង នេះមាន តាវ៉ាល់, តាផេង និង តាថង។ តាផេង, តាថង ជាអ្នកដឹកនាំកងចល័តតំបន់ដែលទទួលខុសត្រូវក្នុងការលើកអាងត្រពាំងថ្មបន្ទាប់ពី តាវ៉ាល់។" អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា លោកនៅចាំបានទេ ព្រោះលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតថា ប្រធានវរៈរបស់លោកនោះមានឈ្មោះ តាឈ្លូង? តើការដែលខ្ញុំអានព័ត៌មានដែលលោកធ្លាប់ឆ្លើយនេះ លោកអាចជួយរំឭកដល់ការចងចាំរបស់លោកដែរឬទេ? ហើយព័ត៌មានហ្នឹង តើវាត្រឹមត្រូវដែរឬទេ?

**ឆះ** បាទ ពិតជាត្រឹមត្រូវមែន។

[០៩:៣៥:៣៤]

**សះ** ចុះលោកមានដែលធ្លាប់ប្រជុំជាមួយនឹង តាឈ្លូង ឬក៏ តាវ៉ាល់ ដែរឬទេ?

**ឆះ** បាទ បានធ្លាប់ឲ្យតាំងចិត្តខិតខំរែកទំនប់ មានតែប៉ុណ្ណោះ។

**សះ** ខ្ញុំនឹងត្រឡប់មកសួរពីបុគ្គលទាំងនេះនៅពេលក្រោយ ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ពិភាក្សាជាមួយលោកអំពីស្ថានភាពនៅពេលដែលលោកចាប់ផ្ដើមធ្វើការនៅទំនប់ត្រពាំងថ្ម។ តើពេលដែលលោកទៅត្រពាំងថ្មហ្នឹង ជាក់ស្ដែងលោកធ្វើការអ្វីខ្លះ? ហើយការងារហ្នឹងចាប់ផ្ដើមពីម៉ោងណាដល់ម៉ោងណាដែរ?

**ឆះ** បាទ ចាប់ផ្ដើមធ្វើការតាំងពីម៉ោងប្រាំពីរ ដល់ម៉ោងដប់ ដប់មួយសម្រាក។

**សះ** ហើយចុះពេលថ្ងៃ ហើយនិងពេលយប់មានការងារដែរឬទេ? ហើយប្រសិនបើមានគេធ្វើការហ្នឹង ធ្វើការពីម៉ោងណាដល់ម៉ោងណា?

**ឆះ** យប់បើមានបញ្ហា ដូចជា ថាទឹកវាហៀរអី មានផែនការលើកយប់ ដោយជួនទឹកវាឡើង។

មានតែប៉ុណ្ណោះ។

**ស៖** ផែនការដែលគេដាក់ឱ្យលោកនុំង គឺលោកលើកដីហ្នឹង តើលើកមានចំនួនកំណត់ទេថា ម្នាក់ ឬក៏មួយកង មួយក្រុមអីត្រូវលើកចំនួនប៉ុន្មាន ប៉ុន្មានម៉ែត្រការ៉េ ប៉ុន្មានម៉ែត្រគូបអីដែរ លោកនៅចាំទេ?

**ឆ៖** បាទ ចាំ ២ម៉ែត្រ ដែលគេហៅថា ២ម៉ែត្រគូបម្នាក់មួយថ្ងៃ។

**ស៖** ម្នាក់ឱ្យ២ម៉ែត្រគូបក្នុងមួយថ្ងៃ តើផែនការហ្នឹងអ្នកណាជាអ្នកសម្រេច ឬក៏ដាក់បញ្ជាឱ្យធ្វើអ៊ីចឹង?

**ឆ៖** មេថ្នាក់លើប្រគល់ឱ្យ។

[០៩:៣៨:៤០]

**ស៖** ថ្នាក់លើហ្នឹងជាអ្នកណា? សូមលោកបញ្ជាក់ឱ្យច្បាស់មក។

**ឆ៖** មេទំនប់អាងឈ្មោះថា តាវ៉ាល់ នោះឯង។

**ស៖** តើមេទំនប់អាងឈ្មោះ តាវ៉ាល់ ហ្នឹងគាត់ដាក់បញ្ជាពេលណា ពេលដែលចុះទៅធ្វើការ ឬក៏មានការប្រជុំណែនាំដើម្បីដាក់បញ្ជា ដាក់ផែនការហ្នឹងដែរ?

**ឆ៖** មានការប្រជុំណែនាំដាក់កំណត់ឱ្យ។

**ស៖** តើពេលប្រជុំណែនាំដាក់កំណត់ហ្នឹង ជាការប្រជុំទូទៅ ឬក៏ប្រជុំត្រឹមឋានៈលោកជាប្រធានកងបានបានទៅប្រជុំ?

**ឆ៖** បាទ ប្រជុំទាំងអស់ ទាំងចំណុះដែលនៅកន្លែងនោះ។

**ស៖** ចុះក្រោយពីមានការប្រជុំណែនាំដោយ តាវ៉ាល់ ឱ្យលើកដី២ម៉ែត្រគូបក្នុងមួយថ្ងៃហ្នឹង តើប្រជាពលរដ្ឋយើង ឬក៏អ្នកដែលធ្វើការនៅទំនប់អាងត្រពាំងថ្មហ្នឹងគាត់លើកបានសម្រេចទេ? ហើយប្រសិនបើលើកមិនបានទេ តើមានការដាក់វិន័យអ្វីដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទ ហៅថាអ្នកណាដែលខ្សោយ លើកមិនបាន ក៏សុំជំនួយជួយឱ្យទាល់តែដាច់ទាំងអស់គ្នា។

**ស៖** សូមលោកបញ្ជាក់ឱ្យច្បាស់មើល តើការលើកដីដែលកំណត់ជា២ម៉ែត្រគូបក្នុងមួយថ្ងៃហ្នឹង វាភាគច្រើនមានគេអនុវត្តបានដូចផែនការ ឬក៏មិនដូចទេ? ហើយប្រសិនបើមិនដូចហ្នឹង ត្រូវជួយគ្នា ឬក៏ដោះស្រាយរបៀបម៉េចដែរ?

[០៩:៤១:៣៣]

**ឆ៖** បាទ វាមិនស្មើគ្នាទេ ខ្លះក៏ពន្យារនាទី មុនក្រោយ។ ម្ល៉ោះហើយអ្នកណាដែលក្រោយ បានឯកភាពគ្នាជួយ ជួយសម្រេចគ្នា។

**ស៖** ចុះនៅពេលដែលធ្វើការហ្នឹង អ្នកណាជាអ្នកតាមដាន ឬត្រួតពិនិត្យពីលើ ថាតើការងារហ្នឹងធ្វើបានដែរឬទេ? ហើយត្រូវរាយការណ៍ពីណាទៅណាដែរ?

**ឆ៖** បាទ គ្មានទេ។ មានតែប្រធានថ្នាក់លើត្រួតពិនិត្យ។

**ស៖** ថ្នាក់លើដែលត្រួតពិនិត្យហ្នឹងជាអ្នកណា លោកមាននៅចាំឈ្មោះទេ? សូមរៀបរាប់ឈ្មោះមក។

**ឆ៖** ជាប្រធានវរៈ គេអ្នកទទួលខុសត្រូវ។

**ស៖** ប្រធានវរៈហ្នឹងគឺឈ្មោះ ឈ្លួង ដែលលោកទើបតែឆ្លើយអម្បាញ់មិញហ្នឹង ឬក៏អ្នកណា?

**ឆ៖** បាទ ឈ្មោះ ឈ្លួង នោះឯង។ គាត់ជាប្រធានវរៈទទួលខុសត្រូវ។

**ស៖** អ៊ីចឹងឈ្មោះ ឈ្លួង ហ្នឹងជាអ្នកត្រួតពិនិត្យជាប្រចាំ ឬក៏មានអ្នកផ្សេងដែរ? ហើយប្រសិនបើគាត់ជាអ្នកត្រួតពិនិត្យហ្នឹង គាត់មករាល់ថ្ងៃ ឬក៏ពេលវេលាណាដែលគាត់មកត្រួតពិនិត្យ?

**ឆ៖** បាទ គាត់នៅប្រចាំរាល់ថ្ងៃ។

**ស៖** អ៊ីចឹងពេលណាដែលគាត់ចុះមកត្រួតពិនិត្យ? ពេលព្រឹក ពេលថ្ងៃ ឬក៏ល្ងាច ពេលយប់ ពេលថ្មើរម៉ោន ជាប្រចាំដែលគាត់ចុះមកត្រួតពិនិត្យ?

**ឆ៖** បាទ ពិនិត្យនៅកំពុងពេលដែលពលកម្ម។

[០៩:៤៤:២៤]

**ស៖** ចុះក្រៅពី តាឈ្លួង មានអ្នកផ្សេងទៀតដែរឬទេ ដែលជាថ្នាក់លើចុះមកត្រួតពិនិត្យដែរ?

**ឆ៖** មិនមានទេ មានតែលោកតា – តាវ៉ាល់។

**ស៖** ចាស អរគុណ។ ចុះការហូបចូកនៅទំនប់អាងត្រពាំងថ្មហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ក្នុងការហូបចុកតែងតែមានរាំងស្ទះ។ បើដឹកជញ្ជូនមិនទាន់ ក៏មានការខ្វះខាត ខ្សោយ។

**ស៖** លោកថាតែងតែមានការស្ទះ ឬក៏ដឹកជញ្ជូនមិនទាន់ មានការខ្សោយហ្នឹង យ៉ាងម៉េចទៅ? សូមលោកជួយបញ្ជាក់អំពីស្ថានភាពហ្នឹងឲ្យច្បាស់មើល? តើប្រជាពលរដ្ឋ ឬក៏អ្នកដែលធ្វើការនៅទំនប់អាងត្រពាំងថ្មហ្នឹង គាត់ហូបចុកគ្រប់គ្រាន់ទេ ឬក៏មានការខ្វះខាត?

**ឆ៖** បាទ ដូចជាកំណត់ឲ្យហូបថា មួយកង៣០កំប៉ុងអ៊ីចេះ ដល់វាខ្វះខាត បន្ថយពីនោះទៅ វាមិនគ្រប់ទេ វាស្ទើរ។ ការវាមិនពេញកំណត់។

**ស៖** ចុះមួយកងដែលលោកនិយាយហ្នឹង មួយកងហ្នឹងមានប៉ុន្មាននាក់ ហូប៣០កំប៉ុងហ្នឹង?

**ឆ៖** បាទ ខ្ញុំបាទជាភ្លេចទៅ ក៏ឧទាហរណ៍ឲ្យ ឧទាហរណ៍ក្នុងការខ្វះខាត។

**ស៖** លោកថាពេលខ្វះខាត មានការកាត់បន្ថយ។ តើបន្ថយហ្នឹងបន្ថយពាក់កណ្តាល ឬក៏បន្ថយបន្តិចបន្តួចទេ ឬក៏បន្ថយលើសពាក់កណ្តាល?

**ឆ៖** បន្ថយបែងចែកក្រុមនានាឲ្យបាន ហៅថាស្មើភាពគ្នា កុំឲ្យដាច់។

**ស៖** ខ្ញុំចង់ដឹងអំពីចំនួនដែលបន្ថយរបបអាហារហ្នឹង។ ប្រសិនបើមានការកាត់បន្ថយដោយសារការខ្វះខាតហ្នឹង តើចំនួនដែលបន្ថយហ្នឹង បន្ថយចំនួនប៉ុន្មាន? បន្ថយមកពាក់កណ្តាលតែម្តង ឬក៏បន្ថយមកខាងក្រោមពាក់កណ្តាលទៀត ឬក៏លើសពីពាក់កណ្តាល បន្ថយហ្នឹង?

**ឆ៖** បន្ថយពាក់កណ្តាល ចំនួន។

[០៩:៤៧:៤៥]

**ស៖** ចុះការកាត់បន្ថយហ្នឹងវាកើតឡើងញឹកញាប់ដែរឬទេ?

**ឆ៖** មិនញឹកញាប់ទេ យូរៗម្តង។

**ស៖** លោកនៅចាំទេ ថាប្រហែលជារយៈពេលប៉ុន្មានមានការខ្វះខាតម្តង? ប្រហាក់ប្រហែលមួយអាទិត្យ មួយខែ រាប់ខែ ឬក៏យ៉ាងណាដែរ?

**ឆ៖** បាទ ប្រហែលជា២០ថ្ងៃទៅ២៥ថ្ងៃ។

**ស៖** ២០ថ្ងៃទៅ២៥ថ្ងៃក្នុងមួយខែ មានការខ្វះខាតម្តង ឬក៏យ៉ាងម៉េច? លោកជួយបញ្ជាក់បន្តិចមើល។

**ឆ៖** ខ្វះខាតវានៅក្នុង២០ថ្ងៃទៅ២៥ថ្ងៃ។

**ស៖** ចុះស្ថានភាពអ្នកដែលធ្វើការនៅទំនប់អាងត្រពាំងថ្មហ្នឹងយ៉ាងម៉េចដែរសុខភាពរបស់គាត់?

**ឆ៖** បាទ សុខភាព--

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៤៩:៤៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ នេះគ្រាន់តែជាការកត់សម្គាល់ នេះក៏ពាក់ព័ន្ធនឹងសំណួរពីខាងដើមដែរ។ ខ្ញុំសូមផ្ដល់អនុសាសន៍ដល់តំណាងសហព្រះរាជអាជ្ញាថា សូមកម្រិតតែត្រឹមសំណួរទៅនឹងអ្វីដែលគាត់ ថាតើគាត់បានដឹងការងារនៅក្នុងកងរបស់គាត់ទេ ឬក៏យ៉ាងហោចណាស់ ក៏សួរតែត្រឹមអ្វីដែលគាត់ដឹងបានហើយ។ ប៉ុន្តែនៅពេលនេះគឺថា សំណួរសួរលក្ខណៈទូទៅពេក។ បើនេះបើតាមខ្ញុំកត់សម្គាល់ទៅមើលការតាំងសំណួរនេះ។

**កញ្ញា សុង ឆវ័ន្តៈ**

ចាស លោកប្រធាន ជាក់ស្ដែងខ្ញុំបានសួរគាត់អំពីតួនាទីរបស់គាត់នៅក្នុងកងហ្នឹងហើយៗ។ គាត់បានបញ្ជាក់ថាគាត់ជាប្រធានកង។ អ៊ីចឹងខ្ញុំអាចបញ្ជាក់ថា បានបរិបទដែលខ្ញុំសួរនេះ គឺសួរអំពីលទ្ធភាពរបស់គាត់ក្នុងការងារដែលគាត់បានទទួលខុសត្រូវ ហើយនិងដឹង អនុវត្តដោយផ្ទាល់នៅក្នុងកងរបស់គាត់។

**ប្រធានអង្គជំនុំ៖**

បញ្ជាក់ផងណា បញ្ជាក់នៅកងរបស់គាត់ ឬក៏កងណាដែលគាត់បានឃើញ បានដឹង។ ចៀសវាងសំណួរសួរថា នៅក្នុងការដ្ឋានទំនប់ត្រពាំងថ្ម វាមនុស្សមានដល់ទៅជាង៣០.០០០នាក់ឯណោះ។ អ៊ីចឹងមនុស្សហ្នឹងមិនអាចគ្រប់គ្រង ឬក៏ក្ដាប់ព័ត៌មានបានទេ ព័ត៌មានទូលំទូលាយរហូតដល់ជាង៣០.០០០នាក់នោះ។ អ៊ីចឹងគឺក្នុងដែនកំណត់ គឺកងរបស់គាត់ ឬកងដែលក្បែរៗដែលគាត់បានឃើញ បានកត់សម្គាល់។

[០៩:៥១:០៨]

**កញ្ញា សុង ឆវ័ន្តៈ**

ចាស លោកប្រធាន ខ្ញុំនឹងធ្វើដូច្នេះ។

**សួរដោយកញ្ញា សុង ឆវ័ន្តៈ**

**ស៖** លោកសាក្សី មុននេះខ្ញុំសួរលោកអំពីស្ថានភាពសុខភាព។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅក្នុងកងដែលលោកធ្វើការ ឬក៏កងដែលនៅក្បែរៗលោកហ្នឹង ស្ថានភាពសុខភាពរបស់អ្នកដែលធ្វើការនៅអាងទំនប់ត្រពាំងថ្មហ្នឹង យ៉ាងម៉េចដែរ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ មានសុខភាព ហៅថាអាចធ្វើបានការងារតាមកំណត់ផែនការ។

**ស៖** ចុះមានអ្នកជំងឺ មានអ្នកឈឺថ្កាត់ដែរឬទេ? ហើយមានថ្នាំសង្កូវអីដែរឬទេ?

**ឆ៖** បាទ មាន។

[០៩:៥២:០៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមលោកស្ដាប់សំណួរហើយ លោកយកសំណួរហ្នឹងមកគិតមួយភ្លែត ដើម្បីជាការឆ្លើយតបឲ្យបានត្រឹមត្រូវ។ ហើយការគិតរបស់លោកនឹងអាចដកឃ្លារហូតដល់ពេលដែលក្បាលមីក្រូហ្វូនហ្នឹងប្រតិបត្តិការតែម្ដង។ ហើយបើសួរភ្លាម ឆ្លើយភ្លាមអ៊ីចឹង ទី១ គឺមិនប្រាកដថាលោកឆ្លើយតបនឹងសំណួរដែលភាគីសួរលោកទេ។ ហើយបញ្ហាទី២ វាអាចប៉ះពាល់ដល់ប្រព័ន្ធចែកចាយសំឡេង ព្រោះសំឡេងលោកដែលឆ្លើយតបទៅនឹង អង្គជំនុំជម្រះត្រូវរៀបចំ ដើម្បីឲ្យមានការបកប្រែភាសាបានល្អ ហើយក្លាយទៅ បានទៅជាពីរភាសាផ្សេងទៀត គឺភាសាបារាំង និងភាសាអង់គ្លេសផងដែរ។ យើងឃើញថា វាស្ទើរតែគ្រប់ចម្លើយហើយ លោកឆ្លើយភ្លាមៗអ៊ីចឹង ឃើញថាក្បាលមីក្រូហ្វូនមិនប្រតិបត្តិការ ស្មើនឹងលោកមិនបានឆ្លើយតប។

សាកសួរសំណួរចុងក្រោយម្ដងទៀតចំពោះគាត់។

**សួរដោយកញ្ញា សុង ឆវ័ន្ត**

**ស៖** លោកសាក្សីនៅក្នុងកងដែលលោកធ្វើការ ឬក៏កងដែលនៅក្បែរៗលោកហ្នឹង មានអ្នកដែលមានជំងឺដែរឬទេ? ហើយមានប្រហែលជាប៉ុន្មាននាក់?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ មានអ្នកជំងឺនៅក្នុងមួយកងៗ តែងតែមានបួនប្រាំនាក់ ហើយមានពេទ្យប្រចាំព្យាបាល។

[០៩:៥៤:០១]

**ស៖** ខ្ញុំចង់សួរផ្ទៀងផ្ទាត់អ្វីដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតតិច ថាតើវាអាចនឹងជួយរំឭកដល់ការចងចាំរបស់លោក ឬក៏យ៉ាងណាដែរ ដោយសារព័ត៌មានហ្នឹងវាហាក់ដូចជាមិនស៊ីគ្នា។ គឺនៅត្រង់ឯកសារដដែល E3/5283 ត្រង់ ERN ជាភាសាខ្មែរ 00295946, ERN ជាភាសាអង់គ្លេសគឺ

00321201, ជាភាសាបារាំង 00702924។ នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកថា៖ "តើនៅក្នុងកងរបស់លោកមានអ្នកឈឺដែរឬទេ? លោកបានឆ្លើយថា៖ នៅក្នុងកងរបស់ខ្ញុំមានអ្នកឈឺច្រើនណាស់។ នៅក្នុងចំណោមមនុស្ស១០០នាក់ មានអ្នកឈឺដល់ទៅ២០នាក់។ ហើយលោកបានបន្តទៀតថា៖ យើងដឹងថាអ្នកឈឺទាំងនោះដោយសារនៅពេលដែលចាប់ផ្តើមធ្វើពលកម្ម ពួកគេក៏ប្រាប់ថាឈឺ មិនអាចទៅធ្វើការបាន។ អ្នកជំងឺមានដូចជា រាក អាសន្នរោគ ឈឺក្បាល វិលមុខ។ អ្នកជំងឺទាំងនោះ ត្រូវកាត់របបឱ្យហូបតែបបរទេ។" បញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកថា នៅក្នុងកងរបស់លោកហ្នឹង តាមដែលលោកឆ្លើយ គឺលោកថាមានអ្នកជំងឺច្រើន ហើយមានដល់២០នាក់ ប៉ុន្តែមុននេះ លោកបានឆ្លើយថា មានប្រហែលប្រាំនាក់ប៉ុណ្ណោះ។ អ៊ីចឹងតើចង់ដឹងថា ព័ត៌មានដែលលោកផ្តល់មួយណាឱ្យពិតប្រាកដ?

**ឆ៖** បញ្ហានេះ មិនដឹងផង វាហៅថាចងចាំមិនបាន។ វាយូរថ្ងៃ យូរឆ្នាំហើយ ភ្លេច។

**ស៖** អ៊ីចឹងតាមដែលលោកអាចចងចាំបានច្រើនបំផុតហ្នឹង តើប្រាំនាក់ ឬក៏ចន្លោះពីដល់ទៅ២០នាក់ដែលមានអ្នកជំងឺនៅក្នុងកងរបស់លោកហ្នឹង?

**លោក គង់ សំអុន៖**

លោកប្រធាន។

[០៩:៥៦:៤៦]

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ វាមិន--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ហើយវាជាសំណួរច្រំដែល។ សាក្សីបានឆ្លើយបញ្ជាក់ហើយថា លោកមិនអាចចាំបានទេ។ ដូច្នេះបើសិនជាសួរគាត់ដដែលៗនេះ គាត់អាចផ្តល់នូវចម្លើយដែលមិនច្បាស់លាស់។ បាទ សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស លោកប្រធាន ដោយសារតែចម្លើយរបស់គាត់មានភាពខុសគ្នា ហើយមុននេះ គាត់ថា

គាត់មិនចាំ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់គាត់តែប៉ុណ្ណោះ ថាតាមលទ្ធភាពដែលគាត់អាចចងចាំបានច្រើនបំផុត ហ្នឹង តើវានៅក្នុងចន្លោះលេខមួយណា ដោយសារតែប្រាំ ហើយនិង២០វាហាក់ដូចជាមានតួលេខ ដែលខុសគ្នាច្រើន។

**ប្រធានអង្គជំនុំ៖**

យើងអាចបញ្ជាក់អ៊ីចេះ បើសិនជាចង់រំឭកការចងចាំ បន្ទាប់ពីសួរហើយត្រូវយកសំណួរចម្លើយដែលគាត់បានឆ្លើយមុនៗនោះ គឺយកមកសួរបញ្ជាក់គាត់ ដើម្បីបញ្ជាក់ថា រំឭកការចងចាំហ្នឹង តើចម្លើយមុនហ្នឹងវាយ៉ាងម៉េចដែរ វាខុសនឹងចម្លើយនេះ តើមួយណាត្រឹមត្រូវ តែប៉ុណ្ណឹងទៅបានហើយ។ យើងសួរតែចង់តាមបំណងរបស់យើង ដូចជាមិនអាចយកជាភស្តុតាងបានទេ។ វាត្រូវសួរតាមសាច់រឿង សត្យានុម័តនៃបញ្ហាដែលកើតមានឡើង និងលទ្ធភាពរបស់សាក្សីដែលត្រូវឆ្លើយតបទៅនឹង ម្ចាស់សំណួរ។

[០៩:៥៨:១៣]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

ចាស លោកប្រធាន។

**ស៖** លោកសាក្សី រវាងអ្នកជំងឺប្រាំនាក់ ឬក៏២០នាក់ហ្នឹង លោកឆ្លើយខុសគ្នា តើចម្លើយមួយណា ដែលលោកយកជាបានការ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ អ្នកជំងឺអត់ទៀត ថ្ងៃណាទៅក៏តិច ថ្ងៃណាទៅក៏ច្រើន មិនទៀងទេ។

**ស៖** អ៊ីចឹងខ្ញុំសួរលោកបញ្ជាក់អ៊ីចេះវិញ។ ពេលដែលតិចជាងគេ ហ្នឹងប្រហែលប៉ុន្មាននាក់? ហើយដល់ពេលឈឺ ឈឺដែលច្រើនជាងគេហ្នឹង រហូតដល់ប៉ុន្មាននាក់?

**ឆ៖** បាទ តិចនៅចំនួនប្រាំ បើច្រើនដល់ទៅ២០។

**ស៖** ចាស សូមអរគុណ។ ចុះនៅពេលដែលមានអ្នកឈឺអ៊ីចឹង តើមានការថែទាំ ឬក៏ការផ្តល់ថ្នាំសង្កូវដែរឬទេ? ហើយបើសិនបើមាន តើថ្នាំ ថ្នាំប្រភេទអីដែរ? លោកនៅដឹង ឬក៏នៅចាំទេ?

[០៩:៥៩:៥៧]

**ឆ៖** បាទ ខ្ញុំបាទក៏មិនស្គាល់ដែរ។ ទៅលើតែគ្រូពេទ្យដែលព្យាបាល មិនដឹងថាថ្នាំហ្នឹងយ៉ាងម៉េចៗ ទេ។

**សៈ** ចុះនៅក្នុងកងរបស់លោកហ្នឹង នៅពេលដែលគេមានអ្នកឈឺហ្នឹង មានអ្នកឈឺរហូតដល់ស្លាប់នៅក្នុងកងហ្នឹងដែរឬទេ?

**ផៈ** អត់ដែលមានផង។

**សៈ** មុននេះ ខ្ញុំបានអានចម្លើយរបស់លោកនៅអ្នកស៊ើបអង្កេតហើយៗ ហើយទាក់ទងទៅនឹងចម្លើយហ្នឹង លោកក៏បានឆ្លើយថា អ្នកជំងឺទាំងនោះត្រូវកាត់របបឲ្យហូបតែបបរ។ តើគេកាត់របបអាហារហ្នឹងកាត់របៀបម៉េច? ហើយការហូបចុកបន្ទាប់ពីគាត់ឈឺហ្នឹង តើគេកាត់ដល់ពេលណា ដល់ស្ថានភាពណាដែរ?

**ផៈ** គេ ផែនការទិសកំណត់ថាឲ្យអ្នកជំងឺឲ្យហូបបបរ តែជាហូបបាយវិញ។

**សៈ** ពាក់ព័ន្ធទៅនឹងអនាម័យនៅក្នុងអាងទំនប់ត្រពាំងថ្មហ្នឹង តើស្ថានភាពអនាម័យនៅក្នុងអាងទំនប់ត្រពាំងថ្មហ្នឹងយ៉ាងម៉េចដែរ? មានបង្គន់ មានទឹកយ៉ាងម៉េចដែរ ការហូបចុក?

**ផៈ** បង្គន់ជីកកន្ទុករណ្ដៅ ហើយអនាម័យក៏មិនបានជាប់រាប់ខែ ដាំក្ដៅ ទឹកក្ដៅបានតែចំនួនមួយខែ ឬកន្លះខែ ក៏ឈប់។

**សៈ** ចុះដាំទឹកក្ដៅបានកន្លះខែ មួយខែហ្នឹង ផុតពីហ្នឹងទៅ ប្រជាពលរដ្ឋគាត់ពិសាទឹកអីដែរ?

**ផៈ** ពិសាទឹកត្រជាក់។

[១០:០៣:០១]

**សៈ** ទឹកត្រជាក់ហ្នឹងយកមកពីកន្លែងណា?

**ផៈ** ទឹកត្រជាក់នៅក្បែរៗកន្លែងលើកហ្នឹង តាមថ្លុក កន្ទុកជ្រៅ។

**សៈ** ចុះការសម្រាក គេស្នាក់នៅកន្លែងណា? ហើយការរៀបចំឲ្យមានការសម្រាកហ្នឹងយ៉ាងម៉េចដែរ?

**ផៈ** សម្រាកធ្វើរោងមួយកន្លែងបាំងស្លឹកឈើ។

**សៈ** ធ្វើរោងហ្នឹង គឺមួយរោងហ្នឹងស្នាក់នៅប៉ុន្មាននាក់? ហើយធ្វើរោងហ្នឹងឆ្ងាយ ប្រវែងប៉ុន្មានម៉ែត្រពីកន្លែងដែលលោកធ្វើការលើកទំនប់ហ្នឹង?

**ផៈ** មិនឆ្ងាយប៉ុន្មានទេ ចំនួនចម្ងាយប្រហែល១០០ម៉ែត្រក្បែរៗ។

**សៈ** ក្នុងមួយរោងហ្នឹងស្នាក់នៅប៉ុន្មាននាក់?

**ផៈ** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)* ក្នុងមួយកង។

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន ខ្ញុំត្រូវចូលដល់ប្រធានបទថ្មីមួយ ប្រធានបទហ្នឹងគឺវាធំ។ អ៊ីចឹងចង់ជម្រាបសួរលោកប្រធានថាតើ--

[១០:០៥:៤៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមស្របនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរសវនាការ។ ហើយបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានពេលមួយវគ្គទៀតប៉ុណ្ណោះនៅព្រឹកនេះ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៦ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:២៩:២១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដែលរួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផងមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះបន្តបញ្ចប់។ សូមអញ្ជើញ!

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកសាក្សី មុននេះយើងបានពិភាក្សាអំពីស្ថានភាពធ្វើការនៅទំនប់អាងត្រពាំងថ្ម។ ហើយមុននឹងខ្ញុំបន្តដល់ប្រធានបទថ្មី ខ្ញុំមានសំណួរមួយចំនួនចង់សួរត្រឡប់ទៅខាងក្រោយបន្តិច។ នៅពេលដែលខ្ញុំសួរលោកអំពីស្ថានភាពអ្នកជំងឺ ហើយមានពេទ្យទេ លោកឆ្លើយថាមានពេទ្យនៅក្នុងកងចល័ត។ ប៉ុន្តែនៅពេលដែលលោកឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេត គឺនៅត្រង់ ERN ជាភាសាអង់គ្លេស 00321201, ជាភាសាខ្មែរ 00295947 និងជាភាសាបារាំង 00702924។ នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកថា៖ "នៅការដ្ឋានលើកទំនប់ តើមានពេទ្យនិងថ្នាំពេទ្យដែរឬទេ? លោកបានឆ្លើយថា៖ មានគ្រូពេទ្យប្រចាំការមើលកងចល័ត។ នៅក្នុងកងរបស់ខ្ញុំគ្មានពេទ្យប្រចាំការទេ។ ពេទ្យទាំងនោះគឺគ្មានជំនាញទេ គឺចាប់យកពីភូមិមកធ្វើតែម្តង។ ថ្នាំពេទ្យគឺជាថ្នាំប្រឌិត ជាថ្នាំបូរាណ ថ្នាំនោះមានពណ៌ខៀវ ពិបាកលេបណាស់។ អ្នកខ្លះក៏លេបថ្នាំនេះ ហើយអ្នកខ្លះទៀតមិនលេបទេ ដោយគេរវែងចោល មិនឱ្យគេឃើញ។" អ៊ីចឹងខ្ញុំចង់សួរលោកបញ្ជាក់ថា តើលោកនៅចាំបានទេ ថាតើចម្លើយដែលលោកឆ្លើយមុននេះថា មានថ្នាំ ប៉ុន្តែលោកមិនដឹងថ្នាំ ហើយអ្វីដែលលោកឆ្លើយជាមួយអ្នកស៊ើបអង្កេតហ្នឹង លោកបានឆ្លើយយ៉ាងច្បាស់ថា មានថ្នាំប្រឌិត ថ្នាំបូរាណ មានពណ៌ខៀវ មានអ៊ីចឹង។ តើចម្លើយមួយណាដែលលោកយកជាបានការ?

[១០:៣២:១១]

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ ពិតមែន។ ចម្លើយនេះទៅតាមចម្លើយស្របមុននោះឯង។ ខ្ញុំមកថា វាជាជំងឺ ហៅថាមិនបានជាគិតមិនដល់ អស់ វាវង្វេង ឈឺយូរខែច្រើន។ បាទដែលនាង និមល ទៅជួបខ្ញុំនៅភូមិ ខ្ញុំក្រោកស្ទើរមិនរួចទេ ឃើញខ្ញុំស្រាប់ហើយ។ ឈឺយូរខែច្រើនទៅ វង្វេងអស់។

**ស៖** អ៊ីចឹងតើចម្លើយដែលលោកឆ្លើយនៅក្នុងសវនាការមុននេះ ហើយនិងចម្លើយដែលលោកធ្លាប់ឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតកាលពីប៉ុន្មានឆ្នាំមុននោះ តើលោកយកចម្លើយមួយណាដែលបានការ ដែលត្រឹមត្រូវ?

**ឆ៖** *(ឮមិនច្បាស់)*

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតប!

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** មិនដឹងយកមួយណាអ៊ីចេះ គិត នឹករកមិនឃើញ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាស មិនអីទេលោកសាក្សី។ សំណួរមួយទៀតហ្នឹងចង់សួរលោកថា នៅក្នុងអំឡុងពេលដែលលោកធ្វើការនៅទំនប់អាងត្រពាំងថ្ម តើលោកធ្លាប់ត្រូវបានគេចោទថាមានជំងឺសតិអារម្មណ៍ដែរឬទេ?

[១០:៣៤:៣៤]

**ឆ៖** ទេ មិនដែលមានទេ។ ឮតែពាក្យថា ឮតែពាក្យធ្វើការថា សតិអារម្មណ៍ៗ។ តែចំពោះម្នាក់នេះ ម្នាក់នោះអត់ឮ។

**ស៖** ចុះលោកខ្លួនឯងហ្នឹង នៅក្នុងពេលដែលលោកធ្វើការនៅទំនប់អាងត្រពាំងថ្ម លោកធ្លាប់ត្រូវបានគេចោទប្រកាន់ដែរឬទេ ថាលោកមានជំងឺសតិអារម្មណ៍?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះចំណុចនេះ។ សាក្សីបានឆ្លើយបញ្ជាក់រួចហើយថា ពុំមាននរណាត្រូវបានចោទពីជំងឺសតិអារម្មណ៍នៅក្នុងក្រុមរបស់គាត់ រួមទាំងគាត់ផង។ ហើយអ្វីដែលគាត់ឮពីពាក្យថា ជំងឺសតិអារម្មណ៍នេះ គ្រាន់ជាលក្ខណៈជាពាក្យទូទៅ ដែលឮគេនិយាយតែប៉ុណ្ណោះ។ បាទ សូមអរគុណ។

[១០:៣៥:៤៩]

**កញ្ញា សុង ឆវ័ន្ត៖**

ខ្ញុំដូចជាស្តាប់សាក្សីឮនៅក្នុងន័យផ្សេងដែលគាត់ថា គាត់ធ្លាប់ឮរឿងសតិអារម្មណ៍ ប៉ុន្តែគាត់ខ្លួនឯងមិនច្បាស់ អ៊ីចឹងបានខ្ញុំសួរបញ្ជាក់។ តែដើម្បីឲ្យច្បាស់ជាងហ្នឹង ខ្ញុំអាចយោងទៅនឹងឯកសារតែម្តង។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកសាក្សី លោកធ្លាប់ឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតដដែលហ្នឹង គឺឯកសារដដែល ហើយនៅត្រង់ ERN ជាភាសាខ្មែរគឺ 00295947, ជាភាសាអង់គ្លេស 00321202, ជាភាសាបារាំង 00702924។ លោកឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា ខ្ញុំដកស្រង់៖ "គេបានដកខ្ញុំពីប្រធានកងនៅពេលដែលខ្ញុំមានជំងឺបន្តិចបន្តួច ហើយខ្ញុំមិនបានចុះទៅកន្លែងធ្វើការជាប់លាប់ គេក៏បានចោទខ្ញុំថា ឈឺសតិអារម្មណ៍។" អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា លោកនៅចាំបានទេ ថាពេលនោះ គេពិតជាបានចោទប្រកាន់លោកថា លោកឈឺសតិអារម្មណ៍? ហើយពេលហ្នឹង តើឈឺសតិអារម្មណ៍ហ្នឹង មានន័យថាម៉េច? ហើយលោកមានយល់ថា យ៉ាងម៉េចដែរ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ ពិតមែន។ ខ្ញុំមិនស្រួលមែនពិត ធ្វើការអត់កើត ហើយគេចោទខ្ញុំថាសតិអារម្មណ៍។ ហើយគេដាក់ខ្ញុំទៅ ឱ្យទៅពលកម្មបោចរពាក់នៅភូមិខ្លាយ។ ដល់បោចរពាក់ហើយ ធ្វើបង្គី ដាក់កំណត់ឱ្យខ្ញុំធ្វើម្ង៉ៃ១០បង្គី គ្នាប្អូនប្រាំនាក់។ ដល់ខ្ញុំគោរពផែនការបាន ហៅខ្ញុំមកបញ្ចូលកន្លែងដដែល សាដើមវិញ។

[១០:៣៧:៥៥]

**ស៖** អ៊ីចឹងពេលហ្នឹងលោកឈឺមែនទែន មានន័យថា លោកពិតជាមានជំងឺមែន ឬក៏លោកឈឺតាមការចោទប្រកាន់របស់គេ គ្រាន់តែឈឺសតិអារម្មណ៍ទេ?

**ឆ៖** បាទ ឈឺពិតប្រាកដមែន ឈឺធ្វើការអត់កើត។

**ស៖** ចុះនៅពេលដែលគេបញ្ជូនលោកទៅធ្វើការនៅកន្លែងផ្សេងទៅបោចរពាក់ ទៅធ្វើបង្គីអីហ្នឹង អ្នកដែលធ្វើការនៅក្នុងក្រុមកន្លែងបោចបង្គី កន្លែងអីហ្នឹង កន្លែងបោចរពាក់ ឬក៏ធ្វើបង្គីអីហ្នឹង សុទ្ធតែអ្នកដែលត្រូវបានគេចោទប្រកាន់ដូចគ្នា ឬក៏គាត់មកពីកងផ្សេង ហើយមានមូលហេតុអីដែរ?

**ឆ៖** នៅកងផ្សេង គេចាត់កម្លាំងក្នុងមួយកងពីរនាក់ បីនាក់ ប្រមូលតែមួយកន្លែងទៅបោចរពាក់។

**ស៖** ចុះពេលហ្នឹង អ្នកណាជាអ្នកសម្រេចដកលោកទៅបោចរពាក់ ទៅធ្វើបង្គីហ្នឹង?

**ឆ៖** មិនដឹងផង។ ស្រាប់តែប្រធានវរៈប្រាប់ថា ឱ្យទៅដក ឱ្យទៅបោចរពាក់។

**ស៖** ប្រធានវរៈដែលលោកថា ឱ្យលោកទៅបោច ឬក៏ទៅធ្វើបង្គីហ្នឹង គាត់មានឈ្មោះអ្វីដែរ?

**ឆ៖** ឈ្មោះ ឈ្មួង។

**ស៖** ចុះពេលដែលគាត់ប្រាប់លោកឲ្យទៅបោចរពាក់ ឬក៏ធ្វើបង្គីហ្នឹង លោកមានសិទ្ធិបដិសេធទេ ឬក៏អាចបដិសេធថាមិនទៅបានទេ?

**ឆ៖** ទៅ មិនហ៊ានប្រកែកទេ ទៅតាមទិស មិនហ៊ានប្រកែក។

**ស៖** ហេតុអ្វីបានជាលោកមិនហ៊ានប្រកែក? ព្រោះលោកបានឆ្លើយថា លោកពិតជាឈឺមែនពេលហ្នឹង។ ចុះបើសិនបើលោកឈឺ ហេតុអ្វីបានជាលោកមិនមកប្រកែកថា លោកមិនទៅ?

**ឆ៖** មិនហ៊ានប្រកែកទេសម័យនោះ តែហ៊ានប្រកែក និយាយមិនបានទេ។ និយាយប្រកែកប្រណាំងមិនបានទេ។ សុខចិត្តយកថ្នាំតាមលេប ថ្នាំពេទ្យលេបទៅធ្វើការ។

**ស៖** ចុះនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅទំនប់អាងត្រពាំងថ្មនេះ តើលោកធ្វើការដោយស្ម័គ្រចិត្ត ឬក៏លោកអាចមានសិទ្ធិបដិសេធដែរ នៅពេលដែលគេឲ្យលោកទៅរែកដី លើកទំនប់ លើកអីហ្នឹង?

**ឆ៖** ទូទៅគ្រប់ភូមិ ឲ្យតែយុវជន គឺហៅប្រមូលទាំងអស់ យុវជន-នារីហៅទាំងអស់។

[១០:៤២:១១]

**ស៖** ចុះពេលហ្នឹង លោកទៅដោយស្ម័គ្រចិត្ត ឬក៏មានគេបង្ខំឲ្យលោកទៅ ឬក៏ពេលហ្នឹងលោកប្រកែកថាមិនទៅបានដែរឬទេ?

**ឆ៖** មិនទៅអត់បាន ត្រូវតែទៅ។ ឲ្យតែយុវជន-នារី នៅមិនបានទេ មិនឲ្យសល់ទេ។

**ស៖** ហេតុអ្វីបានជាត្រូវតែទៅ? ហេតុអ្វីបានមិនបដិសេធទៅ ប្រសិនបើមិនចង់ទៅ?

**ឆ៖** មិនដឹងផង គេហៅហើយ ក៏តាមគេ។ មិនដឹងយ៉ាងណា ទៅក៏ទៅជាមួយគេ។

**ស៖** ចុះនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅទំនប់អាងត្រពាំងថ្មហ្នឹង គេមានដែលដើរស្រង់ប្រវត្តិរូបអ្នកដែលធ្វើការនៅទីនោះទេ?

**ឆ៖** មានខ្លះៗតើ។

**ស៖** ខាងណាជាអ្នកដើរស្រង់ប្រវត្តិរូបហ្នឹង? ហើយលោកដឹងទេ គេស្រង់យកធ្វើអី?

**ឆ៖** មានមេវរៈ គេអ្នកឲ្យធ្វើ។

**ស៖** មេវរៈដែលប្រាប់ឲ្យស្រង់ប្រវត្តិរូបហ្នឹង គឺស្រង់ទាំងអស់អ្នកដែលធ្វើការនៅក្នុងទំនប់អាងត្រពាំងថ្ម ឬក៏ស្រង់តែនៅក្នុងកងរបស់លោកទេ?

**ឆ៖** ស្រង់ឯកភាពទាំងអស់ គ្មានសល់មួយ។

**ស៖** ចុះលោកដឹងទេថា ហេតុអ្វីបានជាគេដើរស្រង់ ឬក៏ប្រមូលប្រវត្តិរូបរបស់អ្នកដែលធ្វើការនៅអាងត្រពាំងថ្មហ្នឹង?

**ឆ៖** បាទ មិនដឹងទេ។ ចម្ងល់ណាស់ មិនដឹងគេស្រង់ទៅយ៉ាងណាទេ។

**ស៖** ចុះមុននឹងមានការដើរស្រង់ ដើរប្រមូលហ្នឹង ក្នុងនាមលោកជាប្រធានកងធំដែរហ្នឹង មានការប្រជុំណែនាំមុននឹងពីរបៀបនៃការស្រង់ ឬក៏គោលការណ៍នៃការស្រង់ដែរទេ បានចាប់ផ្ដើមស្រង់?

**ឆ៖** គេគ្រាន់តែប្រាប់ដើរស្រង់តាមកងៗ អ្នកណាមិនបានស្រង់ ត្រូវតែស្រង់ឲ្យអស់។

**ស៖** អ៊ីចឹងនៅក្នុងកងរបស់លោកហ្នឹង លោកជាអ្នកស្រង់ប្រវត្តិរូបផ្ទាល់ ឬក៏មានអ្នកផ្សេងជាអ្នកស្រង់?

**ឆ៖** បាទ ទេ អត់ស្គាល់ទេ។ មានគេអ្នកផ្សេងគេដើរស្រង់ ចំណូលចូលផ្សេង។

**ស៖** ហើយលោកដឹងទេថា នៅពេលដែលគេស្រង់បានហ្នឹង គេរាយការណ៍ឲ្យអ្នកណាខ្លះ?

**ឆ៖** មិនដឹងទេ។ គេស្រង់ គេយកទៅណា មិនដឹងទេ។

[១០:៤៦:៥៦]

**ស៖** ចាស អរគុណ។ ខ្ញុំចូលដល់ប្រធានបទថ្មីមួយផ្សេងទៀត ដែលពាក់ព័ន្ធទៅនឹងការចាប់ខ្លួន និងការសម្លាប់មនុស្សនៅក្នុងទំនប់អាងត្រពាំងថ្ម។ ខ្ញុំចង់សួរលោកថា តើនៅក្នុងកងរបស់លោកហ្នឹង មានធ្លាប់មានការចាប់ ឬក៏ការសម្លាប់មនុស្សដែរឬទេ នៅក្នុងកងរបស់លោក តាមដែលលោកដឹង តាមដែលលោកចាំ?

**ឆ៖** បាទ មានមួយ – មានម្នាក់។

**ស៖** សូមលោករៀបរាប់មើលថា ម្នាក់ដែលគេយកទៅ ចាប់ ហើយនិងសម្លាប់ហ្នឹង តើរឿងហេតុហ្នឹងវាកើតឡើងរបៀបម៉េច? ហើយគាត់ហ្នឹងមកពីណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយសារសំណួរនេះគឺថា សួរតែមួយឃ្លាក៏ប៉ុន្តែគ្របដណ្ដប់ទៅ

លើប្រធានបទដល់តែពីរឯណោះ។ នៅពេលដែលសួរ ខ្ញុំឃើញថាសាក្សីឆ្លើយថា មានករណីមួយនោះ គឺថាមានគេចាប់មនុស្សខ្លះ។ ប៉ុន្តែក្រោយមកក៏សួរអំពីករណីថា តើមានឃើញគេចាប់មនុស្ស ហើយសម្លាប់? អត់ទេ គាត់អត់បាននិយាយអំពីការសម្លាប់មនុស្សនេះទេ។

[១០:៤៨:៣២]

**កញ្ញា សុង ឆវ័ន្តៈ**

ខ្ញុំមិនដឹងថា ជាភាសាអង់គ្លេសគាត់បានស្តាប់ឮរបៀបម៉េចទេ ប៉ុន្តែខ្ញុំកំពុងតែសួរលើករណីមនុស្សម្នាក់ដែលសាក្សីកំពុងតែបាននឹងឆ្លើយប្រាប់មុននេះ គឺគាត់ថាគាត់បានដឹងរឿង មានមនុស្សម្នាក់ត្រូវបានគេចាប់ ហើយសម្លាប់។ អ៊ីចឹង ខ្ញុំកំពុងតែសួរនឹងករណីដែលគាត់បានរៀបរាប់មុននេះ។

**ប្រធានអង្គជំនុំៈ**

គាត់ចង់ជំទាស់រឿងបញ្ហាសំណួរសួរហ្នឹង គឺទាំងពីរអង្គហេតុ ការចាប់ផង ហើយនិងសម្លាប់ផង។ ហើយគាត់បញ្ជាក់រឿងបញ្ហាចាប់ ហើយនិងសម្លាប់វាមានអង្គហេតុខុសគ្នា។ តើគាត់ដឹងទាំងការចាប់ ទាំងការសម្លាប់ ឬក៏យ៉ាងម៉េច? ចង់បញ្ជាក់ឲ្យបានច្បាស់លាស់ បើសិនជាចាប់គឺអង្គហេតុចាប់ ហើយនិងអង្គហេតុសម្លាប់ហ្នឹង ជាអង្គហេតុមួយទៀត ដែលជាប់ភ្ជាប់គ្នាជាមួយនឹងអង្គហេតុហ្នឹងដែរ ប៉ុន្តែសំណួរគួរតែញែកឲ្យដាច់ពីគ្នា ព្រោះនៅក្នុងព័ត៌មានដែលទទួលបានដូចជា មិនមែនចាប់ ហើយសម្លាប់ទេ បានន័យថា រឿងចាប់ផ្សេង ហើយសម្លាប់ផ្សេង។ គាត់អាចដឹងរឿងចាប់ ប៉ុន្តែអាចមិនដឹងរឿងសម្លាប់ ឧទាហរណ៍អ៊ីចឹង។ អ៊ីចឹងសូមញែកឲ្យបានច្បាស់លាស់ ដើម្បីងាយយល់ ហើយចៀសវាងកាលណាអង្គហេតុមិនមែនសម្លាប់ទេ យើងសួរគាត់ទាំងចាប់ហើយសម្លាប់ គាត់ឆ្លើយទៅវាជាអង្គហេតុដែលគាត់មិនដឹង។ ដល់ពេលមេធាវីសួរទៅ បញ្ជាក់ទៅ គាត់មិនដឹងទេអំពីការសម្លាប់ ឧទាហរណ៍អ៊ីចឹង វាអត់មានប្រយោជន៍អីទេក្នុងការសួរឆ្លើយហ្នឹង។ វាអត់មានប្រយោជន៍ស្វែងរកការពិតទេ។

[១០:៥០:០១]

**កញ្ញា សុង ឆវ័ន្តៈ**

ចាស លោកប្រធានខ្ញុំអាចញែកប្រធានបទនេះជាពីរ ប៉ុន្តែដើម្បីសន្សំពេលវេលា ដោយសារសាក្សីបានបញ្ជាក់ហើយ ថាគាត់ពិតជាបានដឹងអំពីហេតុការណ៍មួយនឹង។

**សួរដោយកញ្ញា សុង ឆវ័ន្តៈ**

**សៈ** អ៊ីចឹងខ្ញុំយោងដល់ចម្លើយរបស់គាត់ហ្នឹង ជាមួយនឹងអ្នកស៊ើបអង្កេតនៅការិយាល័យសហ

ចៅក្រមស៊ើបអង្កេតគឺនៅត្រង់ ERN ជាភាសាខ្មែរ 00295943, ជាភាសាអង់គ្លេស 00321198, ជាភាសាបារាំង 00702920។ លោកសាក្សី លោកបានឆ្លើយថា៖ "នៅក្នុងកងរបស់ខ្ញុំមានការចាប់មនុស្សយកទៅសម្លាប់ចោល។" អ៊ីចឹងខ្ញុំចង់សួរលោកបញ្ជាក់ថា នៅពេលដែលលោកឆ្លើយថា មានការចាប់ ហើយយកទៅសម្លាប់ហ្នឹង ឥឡូវខ្ញុំពិភាក្សារឿងការចាប់មនុស្សមុន តើពេលដែលគេចាប់មនុស្សហ្នឹងចាប់នៅកន្លែងណា ហើយពេលណាដែរ? លោកជួយរៀបរាប់អំពីហេតុការណ៍នោះជូនដល់តុលាការផង។

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ ចាប់នៅកន្លែងអាងទំនប់រំចេក។

**ស៖** ចាប់អ្នកណា ហើយដោយសារមូលហេតុអ្វីដែរ? ហើយហេតុការណ៍ហ្នឹងវាកើតឡើងរបៀបម៉េច? សូមលោកជួយរៀបរាប់ឲ្យលម្អិតបន្តិចមក។

[១០:៥១:៤២]

**ឆ៖** មិនដឹងមូលហេតុយ៉ាងម៉េចផង អត់ដឹង ស្រាប់តែឮ។ ហើយតាមពាក្យដែលនេះថា ពាក្យដែលស្រង់ប្រវត្តិរូបនោះឯង។

**ស៖** ពាក្យដែលចាប់ហ្នឹង ត្រង់ប្រវត្តិរូបនោះ លោកចង់បានន័យថាម៉េច? សូមលោកបញ្ជាក់ឲ្យច្បាស់បន្តិចមក ខ្ញុំដូចជាមិនយល់។

**ឆ៖** ស្រង់ប្រវត្តិរូបទៅថា អ្នកអាកាសចរណ៍ ហើយសូមដកហូតខោអាវ អត់ព្រមឲ្យទៅឮពាក្យថាអ៊ីចេះឯង មិនដឹងថាពិត អត់ពិត។

**ស៖** តើខាងណាជាអ្នកចុះមកចាប់?

**ឆ៖** អត់ស្គាល់។ មិនដឹងផង យប់។

**ស៖** នៅក្នុងចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតដដែលហ្នឹងគឺនៅ ERN ដដែល ប៉ុន្តែមកឆ្លងមកទំព័រខាងមុខបន្តិច។ លោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា៖ "ការចាប់ខ្លួននោះត្រូវធ្វើឡើងដោយពួកទាហានរបស់ តាវ៉ាល់"។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា ការដែលលោកឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនោះ តើជាការត្រឹមត្រូវដែរឬទេ នៅពេលដែលលោកនិយាយថាពួកទាហានដែលចុះមកហ្នឹង គឺជាទាហានរបស់ តាវ៉ាល់?

**ឆ៖** បាទ មិនពិតឃើញខ្លួនឯងទេ ឮពាក្យគេថា ថាតាមគេ។

**ស៖** លោកមុននេះបាននិយាយថា គាត់ហ្នឹងជាអ្នកអាកាសចរណ៍។ តើលោកដឹងប្រវត្តិរបស់គាត់ទេ ថាគាត់មកពីណា? ហើយធ្វើការនៅកន្លែងណាដែរ?

[១០:៥៤:៣៩]

**ឆ៖** បាទ បងប្អូនជម្លៀសថ្មី។

**ស៖** បងប្អូនជម្លៀសថ្មីហ្នឹង គឺបងប្អូនដែលជាអ្នក១៧មេសា មកពីភ្នំពេញហ្នឹង តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** ឆ្លើយស្តាប់អត់បាន។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមលោកឆ្លើយម្តងទៀត អំមិញហ្នឹងនៅពេលលោកឆ្លើយក្បាលមីក្រូអត់ទាន់បើកទេ។ អ៊ីចឹងលោកឆ្លើយម្តងទៀត ថាតើខ្ញុំសួរសំណួរចុងក្រោយអំមិញហ្នឹង សួរថា លោកនិយាយថាអ្នកថ្មីហ្នឹង ខ្ញុំចង់សួរបញ្ជាក់លោកថា អ្នកថ្មីហ្នឹងគឺអ្នក១៧មេសា មកពីភ្នំពេញ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ពិតមែននោះហើយ។

**ស៖** ចុះលោកដឹងទេថា គាត់មកពីភ្នំពេញធ្វើជាអ្នកបើកយន្តហោះហ្នឹង តើគាត់ធ្វើការនៅកន្លែងណានៅពេលដែលគាត់ធ្វើនៅភ្នំពេញហ្នឹង? លោកបានដឹងរឿងនេះទេ?

[១០:៥៦:២៧]

**ឆ៖** មិនដឹងទេ។

**ស៖** លោកសាក្សីនៅក្នុងចម្លើយរបស់លោកដដែលគឺនៅ ERN បន្តមកទំព័រខាងមុខបន្តិច មុននឹងខ្ញុំអានមុននេះបន្តិចហ្នឹង។ លោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា៖ “មុនពេលចាប់ខ្លួននរណាម្នាក់តែងតែមកសួរប្រធានជាមុនសិន។ ដោយសារអ្នកនោះជាកូនកងរបស់ខ្ញុំ គេបានមកសួរខ្ញុំរកឈ្មោះអ្នកដែលត្រូវចាប់នោះ។ ពេលនោះខ្ញុំក៏បានប្រាប់គេ ហើយគេបានមកចាប់អ្នកនោះតែម្តង យកទៅតែម្តងនៅពេលពួកយើងកំពុងធ្វើការនៅពេលយប់។” អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា ហេតុការណ៍ដែលគេចុះ

មកចាប់ហ្នឹង តើវាកើតឡើងនៅពេលយប់ហ្នឹងម៉ោងប្រហែលជាប៉ុន្មានដែរ?

**ឆ៖** មិនបានជាផ្ទៀងគិតម៉ោងដល់ផង។ ម៉ោងកំពុងធ្វើការ ម៉ោងណាទេ មិនបានជាគិត។

**ស៖** អ៊ីចឹងពេលដែលគេចុះមកចាប់ហ្នឹង គឺពេលយប់កំពុងតែធ្វើការលើកទំនប់ហ្នឹង ឬក៏បានសម្រាកពីការងារលើកទំនប់ហ្នឹងហើយ បានគេចុះមក?

**ឆ៖** នៅមិនទាន់សម្រាកធ្វើការទេ កំពុងធ្វើការ។

**ស៖** ចុះបន្ទាប់ពីចាប់គាត់ហើយ តើគេយកគាត់ទៅណា?

**ឆ៖** មិនដឹងគេយកទៅឯណាទេ។ យប់ទៅ គេនាំឯណាហើយ គេមិនឲ្យខ្ញុំបៀត។

[១០:៥៨:៥១]

**ស៖** លោកសាក្សី នៅក្នុងចម្លើយរបស់លោកដដែល ប៉ុន្តែបន្តមកខាងមុខបន្តិចហ្នឹង លោកបានឆ្លើយថា៖ "ពេលនោះខ្ញុំក៏បានទៅជាមួយ ពេលគេបណ្តើរទៅដល់គោករំចេកដែលមានចម្ងាយពីកន្លែងធ្វើការប្រហែលជា៦០ម៉ែត្រ រំពេចនោះអ្នកនោះបានរត់គេចខ្លួន ខ្ញុំចង់ជួយដែរ។--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមានការជំទាស់ទៅនឹងការតាំងសំណួរនេះទេ។ ដោយសារក្នុងចម្លើយនេះគឺថាសាក្សីបានឆ្លើយថា គាត់មិនចាំទេ។ ប៉ុន្តែខ្ញុំសូមឲ្យជៀសវាងបញ្ហាដែលយើងជួបប្រទះកាលពីសប្តាហ៍មុន គឺថាកាលណា គឺការអានចម្លើយលម្អិតពេក យើងឃើញថាវាជាការរំឭកដល់ការចងចាំ ក៏ប៉ុន្តែអានក្នុងលក្ខណៈទូលំទូលាយពេក។ ស្នើសុំឲ្យតំណាងសហព្រះរាជអាជ្ញា សូមកុំផ្តល់ភាពលម្អិតមកដល់សាក្សីជាមុនពេក លើសពីសម្រង់។ បាទ អ៊ីចឹងខ្ញុំស្នើសុំតែប៉ុណ្ណោះឯង។

**ប្រធានអង្គជំនុំ៖**

បាទ លោក -- គាត់គ្រាន់តែកត់សម្គាល់ទេ ហើយសហព្រះរាជអាជ្ញារងជាតិអាចធ្វើបាន ក្នុងក្របខ័ណ្ឌនៃសំណេរដែលសរសេរនៅក្នុងកំណត់ហេតុ ចៀសវាងតែយកទៅពន្លាត ពន្យល់ឲ្យហួសពេក ឆ្ងាយពីដែលប្រតិចារឹកនៅក្នុងកំណត់ហេតុ បានហើយ។ មិនមែនដកស្រង់ ចាំបាច់តែដកស្រង់នោះទេ បើដកស្រង់ជាល្អហើយ។

[១១:០១:០៤]

**កញ្ញា សុង ឆវ័ន្គ៖**

ចាស អរគុណលោកប្រធាន។

**សួរដោយកញ្ញា សុង ឆវ័ន្គ៖**

**ស៖** លោកសាក្សី ខ្ញុំសួរសំណួរចុងក្រោយមុននេះម្តងទៀត។ លោកធ្លាប់ឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៅត្រង់ ERN ដដែលហ្នឹង លោកបានឆ្លើយជាមួយអ្នកស៊ើបអង្កេតថា៖ "ពេលនោះខ្ញុំក៏បានទៅជាមួយ គេបណ្តើរទៅដល់គោករំចេក ដែលមានចម្ងាយពីកន្លែងធ្វើការប្រហែល៦០ម៉ែត្រ រំពេចនោះអ្នកនោះបានរត់គេចខ្លួន ខ្ញុំចង់ជួយដែរ តែអ្នកបណ្តើរនោះបានកៀសខ្ញុំចេញ រួចហើយបាញ់ប្រហារអ្នកនោះស្លាប់តែម្តងនៅកណ្តាលវាលស្រែ"។ ខ្ញុំចង់សួរលោកថា លោកដឹងទេថា អ្នកដែលបាញ់ប្រហារនោះ គាត់ជាអ្នកណាដែរ ហើយនៅក្នុងក្រុម ឬក៏កងណា ឬក៏មានឋានៈអ្វីដែរ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បញ្ហាដែលគេបាញ់នោះ ឋានៈគេជាអ្នកថា យោធាប្រចាំទំនប់នោះ។

**ស៖** មុននេះលោកបានឆ្លើយថា អ្នកដែលមកចាប់គឺពួកទាហានរបស់ តាវ៉ាល់។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ថា ពេលដែលបាញ់ហ្នឹងគឺជាមនុស្សមួយក្រុមដែលចុះមកចាប់ដដែលហ្នឹង ឬក៏ជាអ្នកផ្សេងដែលជាអ្នកបាញ់ប្រហារពេលនោះ?

**ឆ៖** ពួកគេអ្នកយោធាហ្នឹងហើយ គេមកចាប់យកដល់កន្លែង។

**ស៖** ខ្ញុំដឹងថា លោកបានឆ្លើយហើយថា យោធាហ្នឹងឯងជាអ្នកចាប់ ប៉ុន្តែអ្នកដែលបាញ់ តើជាយោធាដដែលហ្នឹង ឬក៏មានក្រុមផ្សេង?

[១១:០៣:២០]

**ឆ៖** មិនដឹងផង។ គ្រាន់គេកៀសខ្ញុំឲ្យចេញ ក៏ខ្ញុំគេចខ្លាច មិនដឹងទៅយ៉ាងណា មិនដឹងថាមួយណា យប់ងងឹតផង។

**ស៖** អ៊ីចឹងពេលដែលគេបាញ់ហ្នឹង តើលោកនៅកន្លែងណា? ហើយលោកបានឃើញការបាញ់ប្រហារហ្នឹងដោយផ្ទាល់ដែរឬទេ?

**ឆ៖** មិនបានឃើញទេ ឮតែស្នូរ គេចចម្ងាយឆ្ងាយ។ គេមិនឲ្យបៀត។

**ស៖** លោកសាក្សី ចម្លើយដែលលោកឆ្លើយមុននេះ ជាមួយនឹងចម្លើយដែលលោកធ្លាប់ឆ្លើយពីមុនជាមួយអ្នកស៊ើបអង្កេត ហាក់ដូចជាមានភាពផ្ទុយគ្នា ពីព្រោះនៅពេលដែលលោកឆ្លើយជាមួយ

អ្នកស៊ើបអង្កេត ខ្ញុំដកស្រង់គឺនៅ ERN ដដែល លោកបាននិយាយថា៖ "ខ្ញុំបានឃើញគេបាញ់ដោយផ្ទាល់ភ្នែក"។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា តើពេលនោះ លោកបានឃើញគេបាញ់ដោយផ្ទាល់ភ្នែក ឬក៏លោកនៅឈរឆ្ងាយ ដោយមិនបានឃើញទេ? តើចម្លើយមួយណាឲ្យត្រឹមត្រូវហើយពិតប្រាកដ?

**ឆ៖** គ្រាន់តែនៅចម្ងាយ បានតែមួយឮ។ ក្រោយពីបាត់រូបនោះទៅ ក៏សន្មតថាមែន។

**ស៖** ចុះហេតុអ្វីពេលដែលអ្នកស៊ើបអង្កេតសួរលោកថា លោកបានឃើញគេបាញ់អត់ទេ លោកឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេត ពេលដែលគេទៅសម្ភាសលោកនោះ លោកឆ្លើយថា "ខ្ញុំបានឃើញដោយផ្ទាល់ភ្នែក ពេលគេបាញ់ហ្នឹង"?

[១១:០៥:២៨]

**ឆ៖** បានឃើញនឹងភ្នែកទេ គ្រាន់តែឮ យល់ថាជាស្លូវហើយ ក៏គិតមែន ថាឃើញ សម្រេចចិត្តថាឃើញ។

**ស៖** ចុះមនុស្សម្នាក់ដែលលោកបាននិយាយថា គេចាប់ ហើយគេបាញ់ហ្នឹង ក្រោយមកថ្ងៃកើតហេតុហ្នឹង លោកមានដែលជួបគាត់ម្តងទៀតទេ?

**លោក គង់ សំអុន៖**

លោកប្រធាន! ខ្ញុំសូមធ្វើការកត់សម្គាល់ទាក់ទងនឹងការសន្និដ្ឋានរួមមួយថា សាក្សីនិយាយថា មនុស្សម្នាក់ដែលសាក្សីឃើញគេចាប់ ហើយគេបាញ់ ប៉ុន្តែវាមានអង្គហេតុមួយទៀតនៅចន្លោះនេះ គឺគេចាប់ ហើយអ្នកនោះឯងបានរត់ ព្យាយាមរត់ បានមានការបាញ់។ អ៊ីចឹងនេះជាអង្គហេតុដែលសាក្សីបានផ្តល់ឲ្យ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិត្រឹមត្រូវហើយ។ គាត់ចង់បញ្ជាក់បញ្ហាហ្នឹង ថាតើគាត់បានឃើញមនុស្សហ្នឹងទៀតដែរឬទេ? មកពីគាត់ប្រហែលជាមិនជឿថា រឿងបញ្ហាមិនច្បាស់លាស់ បាញ់ ឬមិនបាញ់ហ្នឹងឯង បានពេលគាត់ត្រូវសួរបញ្ជាក់បញ្ហាហ្នឹង។ នេះជាលទ្ធផលនៃបញ្ជាក់អង្គហេតុដែលបានកំពុងដេញដោល។ អញ្ជើញតទៀត!

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកនៅចាំសំណួរចុងក្រោយរបស់ខ្ញុំអំមិញទេ ឬក៏ខ្ញុំសួរលោកម្តងទៀតតែម្តង។ បន្ទាប់ពីលោកឃើញគេបាញ់ហើយហ្នឹង តើលោកមានដែលបានជួបមនុស្សម្នាក់ហ្នឹងទៀតដែរឬទេ?

[១១:០៧:៣៣]

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** ចាប់ពីថ្ងៃនោះទៅ ក៏បាត់មែនពិត។

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ សូមផ្ទេរវេទិកានេះទៅសហមេធាវីនាំមុខ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម ភាគី សាធារណជន និងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានវត្តមាននៅក្នុងសវនាការនេះ។ បាទ ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានចំណុចមួយចំនួនចង់សួរទៅដល់លោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមជម្រាបសួរលោកសាក្សី។ ខ្ញុំចង់សួរជាបឋមពាក់ព័ន្ធទៅនឹងបញ្ហាការរៀបការនៅក្នុងសម័យខ្មែរក្រហម ដែលលោកដឹងឮ ជួបប្រទះផ្ទាល់។ លោកមានបានដឹងអំពីបញ្ហារៀបការនៅក្នុងសម័យខ្មែរក្រហមហ្នឹងដែរឬទេ? លោកអាចមានប្រសាសន៍បានដែរឬទេ?

[១១:០៨:៥៥]

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ អរគុណណាស់។ ខ្ញុំបាទក៏បានដឹងថា ក្នុងសង្គមនោះ រៀបការហើយ ទាល់តែស្នើដល់មេប្រធានៗនារី មេប្រធានយុវជនស្នើដល់ទៅប្រធាននារី។ តើនារីទាំងពីរនោះយល់ស្រប មិនស្រប ក៏ស្រេចលើ នៅលើប្រធានកង។ តែបើបានស្របហើយ ប្រាប់ដំណឹងអ្នកទាំងពីរនោះថាស្រប។ នេះអាចបានរៀបការបាន។

**ស៖** អម្បាញ់មិញលោកមានប្រសាសន៍ថា បើសាម៉ីខ្លួនស្រប មិនស្រប វាស្រេចតែលើប្រធាននារី។ តើលោកចង់មានន័យ -- ចង់សំដៅទៅលើយ៉ាងម៉េច? ថាតើអ្វីដែលលោកមានប្រសាសន៍

អម្បាញ់មិញមានអត្ថន័យយ៉ាងដូចម្ដេចដែរ លោកអាចពន្យល់បានទេ?

**ឆ៖** បាទ ដើរតាមខ្សែបណ្ដោយ ហៅថា ពីក្រុមទៅមេឲ្យទាក់ទង តាមខ្សែរយៈមេប្រធាន។

**ស៖** តើលោកមានបានដឹងច្រើនទេ អំពីការរៀបការនៅកន្លែងដែលលោករស់នៅហ្នឹង ថាតើមានការរៀបការជាច្រើនលើកដែរឬទេ?

**ឆ៖** បាទ មានខ្លះៗតើ មានភាគច្រើន។ រៀបការម្ដងមានតែ២០គូ ទៅ៣០គូ។

**ស៖** តើលោកអាចបញ្ជាក់ឲ្យច្បាស់បានទេ នៅពេលដែលលោកនៅរយៈពេល៣ឆ្នាំ ៨ខែហ្នឹង ថាតើលោកបានដឹងអំពីការរៀបការប៉ុន្មានដងដែរ ឬក៏បានដឹងតិចតួចទេ? អាចលោកអាចរាប់ជាលើកទេ បានប៉ុន្មានលើកៗ ដែលលោកដឹងថាតើមានការរៀបការប៉ុន្មានលើកដែលលោកដឹង?

**ឆ៖** បាទ មានពីរដង។ ក្នុងភូមិត្រពាំងថ្មម្ដង ក្នុងកន្លែងស្ពានម្ដង ពីរដង។

[១១:១២:០២]

**ស៖** តើស្ពានហ្នឹងៗនៅកន្លែងណា លោកអាចបញ្ជាក់បានទេ? ស្ពានហ្នឹងស្ពានគេហៅស្ពានអី?

**ឆ៖** ស្ពានអាងត្រពាំងថ្មហ្នឹង ស្ពានទី១។

**ស៖** តើការរៀបការហ្នឹង ថាតើនៅក្នុង -- ខ្ញុំសួរអំពីបញ្ហាការរៀបការនៅក្នុងភូមិ ថាតើលោកបានចូលរួមផ្ទាល់ ឬក៏លោកគ្រាន់តែបានឮទេ ការរៀបការនៅក្នុងភូមិហ្នឹង?

**ឆ៖** គ្មានបានបៀតទេ គ្រាន់តែមួយឮ បានគ្រាន់តែមួយឮ មិនបានបៀតគេទេ។

**ស៖** លោកឮយ៉ាងម៉េច លោកអាចបញ្ជាក់បានទេ? ហើយនៅក្នុងការរៀប -- ពេលហ្នឹងការរៀបការនៅក្នុងភូមិហ្នឹងមានប៉ុន្មានគូដែរ ដែលលោកឮគេនិយាយហ្នឹង?

**ឆ៖** មានដល់ទៅ២០គូ។

**ស៖** តើលោកស្គាល់អ្នកដែលរៀបការនៅពេល នៅក្នុងចំណោមអ្នក២០គូហ្នឹងដែរឬទេ?

**ឆ៖** មិនស្គាល់ទេ។

**ស៖** តើលោកដឹងអំពីការរៀបការហ្នឹងយ៉ាងដូចម្ដេច? តើមានអ្នកណាគេប្រាប់លោក ឬក៏យ៉ាងម៉េច? លោកដឹងអំពីការរៀបការនៅក្នុងភូមិហ្នឹងតាមវិធីណា?

**ឆ៖** គេឲ្យអង្គុយតុមួយកន្លែង សឹមរៀប--

**ស៖** សុំទោសៗលោក ខ្ញុំលើកសំណួរខ្ញុំឡើងវិញ ខ្ញុំគិតថាលោកស្ដាប់អត់បាន។ ថាតើលោកដឹងអំពីការរៀបការនៅក្នុងភូមិហ្នឹងដោយវិធីណា? គេនិយាយប្រាប់លោក ឬក៏លោកបានឃើញ?

ហើយគេនិយាយថាយ៉ាងដូចម្ដេចខ្លះ? លោកអាចនិយាយបានទេ បើសិនជាគេនិយាយប្រាប់លោក?

[១១:១៤:៤៧]

**ឆ៖** បាទ បានឃើញគេឡើងមួយគូៗសម្រេចចិត្ត ថាអាចថាទទួលចិញ្ចឹមរក្សាគ្នាក្នុងមួយគូៗ។

**ស៖** បាទ អរគុណ។ លោកអាចនិយាយអំពីការរៀបចំអំពីការរៀបការនៅក្នុងភូមិហ្នឹង ថាតើមានអ្នកណាខ្លះចូលរួម? បើលោកអម្បាញ់មិញ លោកមានប្រសាសន៍ថាលោកបានឃើញតែម្ដង អ៊ីចឹង តើលោកអាចនិយាយបានទេ មានអ្នកណាខ្លះចូលរួមនៅក្នុងពេលនោះ? ចង់និយាយថាអ្នកដែលជាមេកង ឬក៏ថាជាមេភូមិអីអ៊ីចឹង ថាតើមានពួកគាត់ចូលរួមដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថាដូចជាមានភាពច្របូកច្របល់បន្តិចចំពោះសំណួរចម្លើយដែលសហមេធាវីនាំមុខបានសួរចុងក្រោយនេះ។ ទាក់ទងទៅនឹងចម្លើយដែលថាសាក្សីបានចូលរួមនៅក្នុងពិធីរៀបការនោះដែរឬទេ? សាក្សីបានឆ្លើយបញ្ជាក់រួចហើយថា គាត់មិនបានចូលរួមទេ ហើយគាត់មិនបាននៅបៀតទេ គេមិនឲ្យទៅបៀតផង។ បាទ ប៉ុន្តែក្រោយមកសាក្សីហាក់ដូចជានិយាយថាបានឃើញ ប៉ុន្តែមិនមែនមានភាពច្បាស់លាស់ទេ។ អ៊ីចឹងចំណុចនេះគួរតែមានការសួរបញ្ជាក់ទៅលើជំហររបស់សាក្សី ថាតើបានចូលរួមពិតប្រាកដ បានឃើញផ្ទាល់ភ្នែក ឬមួយគ្រាន់តែឮគេថាទេ។ បាទ សូមអរគុណ។

[១១:១៦:៣០]

**ប្រធានអង្គជំនុំ៖**

សូមភាគីចាប់អារម្មណ៍ថា សាក្សីបានបញ្ជាក់ខ្លួនគាត់រួចហើយ ថាស្ថានភាព កាលៈទេសៈបច្ចុប្បន្ននេះ គាត់ស្ថិតនៅក្នុងស្ថានភាពបញ្ហាសុខភាពរបស់គាត់ដោយសារគាត់ឆ្លងកាត់ការឈឺរយៈពេលយូរ គាត់បាត់បង់ការចងចាំ ភ្លេចភ្លាំង ឬក៏ភាំងភ័ន្តភាំងស្មារតី ដូច្នេះភាគីពាក់ព័ន្ធគប្បីរៀបចំសំណួរទៅតាមគោលដៅប្រភេទដែលរបៀបនេះ ដើម្បីឲ្យបានលទ្ធផលដែលអាចទទួលយកបានទាំងអស់គ្នា។ បើយើងរៀបរាប់វែងអន្លាយពេក មិនអង្កន់ សម្រួលធ្វើឲ្យទៅជាសាមញ្ញដើម្បីកម្រិតសាក្សីស្ដាប់សំណួរ

យល់ទេ លទ្ធផលវានឹងប្រឈមនឹងការលំបាកដែលវាមិនច្បាស់លាស់។ សូមរៀបចំនូវសំណួរសាមញ្ញៗ សួរឲ្យច្រើនចុះ ប៉ុន្តែឲ្យខ្លី អាចសួរសាក្សីយល់ ហើយអាចឆ្លើយតបបាន។ ចង់បង្ហាញសមត្ថភាពរបស់ខ្លួន ប៉ុន្តែប្រយោជន៍វាអត់បានផល ដោយសារតបមកវិញ វាមិនបានតបទេ។ អ្នកស្តាប់វាពីរោះហើយ វាល្អហើយចំពោះសំណួរដែលសួរ ប៉ុន្តែផលវាអត់បានប្រយោជន៍អី ពីព្រោះអ្នកឆ្លើយតប ស្តាប់មិនយល់។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ ដោយសាររយៈពេលនៅខ្លីមែនទែន ខ្ញុំសូមបន្តសំណួរហើយលើកខ្លីៗ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកអាចនិយាយអំពីអ្វីដែលលោកបានមើលឃើញនៅក្នុងពេលរៀបការនៅក្នុងភូមិនោះដែរឬទេ? សូមលោកអញ្ជើញ បើសិនបើថាលោកអាចនិយាយបាន សូមអញ្ជើញ!

[១១:១៨:២៥]

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ គ្រាន់តែដើរទៅមើលគេមួយភ្លែតៗ ក៏ដើរចេញ មិនបាននៅយូរទេ។

**ស៖** តើមានសកម្មភាពអ្វីខ្លះដែលលោកបានឃើញនាពេលនោះ?

**ឆ៖** បានឃើញមានតាមសកម្មភាពយ៉ាងណាទេ មិនបានជានៅយូរផង គេរៀបការក៏គេចចេញ។

**ស៖** បាទ ខ្ញុំឈានទៅពេលវេលារៀបការមួយទៀតដែលលោកមានប្រសាសន៍ថា ជាការរៀបការនៅទំនប់ -- នៅទំនប់នៅស្ពានទី១ ត្រពាំងថ្ម។ តើការរៀបការនោះ រៀបការនៅពេលណា លោកអាចបញ្ជាក់បានទេ ខែ ឆ្នាំ?

**ឆ៖** បាទ មិនបានគិតចងចាំថ្ងៃឆ្នាំទេ។ ថ្ងៃណាមិនបានគិតគូរ។

**ស៖** តើលោកបានដឹងពីការរៀបការនៅទីនោះតាមមធ្យោបាយណាដែរ? ដោយខ្លួនឯងឃើញផ្ទាល់ ឬក៏គេនិយាយប្រាប់?

**ឆ៖** បាទ ស្រាប់តែមានមីក្រូគេហៅឈ្មោះអ្នកដែលត្រូវរៀបការ។ ស្រាប់តែឮ ឃើញដើរមើលគេ។

**សះ** លោកមានបានឃើញថា មានការរៀបការហ្នឹងមានច្រើនគូទេ?

**ផះ** មានច្រើនតើ មាន២០ក៏មាន ប្រាំក៏មាន។

[១១:២១:០៣]

**សះ** សូមៗកាត់លោក ការរៀបការនៅជិតស្ពានទី១ ទំនប់ត្រពាំងថ្មដែលលោកបានឃើញហ្នឹង ថាតើមានប៉ុន្មានគូតាមការប៉ាន់ស្មានរបស់លោក?

**ផះ** ការស្មានមាន១៣, ១៤គូ ហើយទៅ២០គូ ជាពីរលើក។

**សះ** តើមាន -- លោកមានបានឃើញមានពិធីសាសនា ឬក៏មានពិធីអ្វីផ្សេងត្រូវបានធ្វើនាពេលនោះដែរឬទេ នៅស្ពានទី១ហ្នឹង ក្នុងពេលរៀបការៗហ្នឹង?

**ផះ** បាទ ឃើញមានគេហៅថា មានជាផ្កា មានជាផ្កាដាក់នឹងមុខតំណាងគេតែប៉ុណ្ណោះ។

**សះ** តើពេលនោះមានអ្នកផ្សេងពីគូស្វាមីចូលរួមដែរឬទេ? លោកមានបានឃើញទេ អ្នកផ្សេងក្រៅពីប្ដីប្រពន្ធហ្នឹង មានពួកគាត់មានចូលរួមដែរឬទេ?

**ផះ** អត់មានទេ។ គ្មានឃើញទេ។

**សះ** អ្នកណាជាអ្នកដឹកនាំការរៀបការនៅទំនប់ នៅលើទំនប់នៅលើស្ពានទី១ហ្នឹង លោកមានបានចាំទេ មានស្គាល់ទេ?

**ផះ** មានតែអ្នកកាន់ការនៅនឹងអាង។

**សះ** តើលោកអាចបញ្ជាក់ឲ្យច្បាស់ទេ ពួកគាត់មានតួនាទីអី? ហើយគាត់មានឈ្មោះអ្វីដែរ អ្នកកាន់ការនៅអាងហ្នឹងដែលលោកឃើញនោះ?

**ផះ** មានតែលោកតា – តាវ៉ាល់ ជាអ្នកកាន់ការអាងត្រពាំងថ្ម។

**សះ** ចង់សួរបញ្ជាក់លោក ថាតើ តាវ៉ាល់ មានវត្តមាននៅក្នុងពេលរៀបការហ្នឹងតែម្ដង ឬយ៉ាងណា?

[១១:២៤:១៦]

**ផះ** មិនដឹងច្បាស់ផងកន្លែងហ្នឹង ដឹងមានអ្នកណាៗច្រើនណាស់។ ភាគច្រើនមើលមិនស្គាល់ទេ។

**សះ** ខ្ញុំសុំសួរលោកពូសាជាថ្មីឡើងវិញ។ អ្នកដែលរៀបចំ ឬក៏ជាអ្នកមានវត្តមានជាអធិបតីនៅក្នុងពេលរៀបការនៅស្ពានទី១ ដែលលោកពូបានឃើញនុំង ថាតើអ្នកណាជាអ្នកអធិបតី ឬក៏ជាអ្នក

រៀបចំការរៀបការនៅស្ពានទី១ ដែលពូបានឃើញហ្នឹង?

**ធ៖** មិនស្គាល់អស់ទេ ព្រោះឃើញហៅថាជាអ្នកបម្រើរបស់ ហៅថាលោកតាប្រចាំទំនប់នោះរៀបចំទៅ ក៏មិនបានជាសម្គាល់អ្នកនោះ អ្នកនេះ គ្រាន់តែហៅតាមឈ្មោះ។

**ស៖** បាទ អ៊ីចឹងអរគុណច្រើន សូមអធ្យាស្រ័យខ្ញុំកាត់បន្តិច។ តើលោកពូខ្លួនឯង នៅពេលរបបខ្មែរក្រហម លោកពូមានគ្រួសារហើយឬនៅ? ហើយបើមាន លោកពូរៀបការនៅពេលណាដែរ អាចបញ្ជាក់បានទេ?

**ធ៖** ខ្ញុំនៅពេលសម័យនោះឯង ក៏ខ្ញុំរៀបនៅភូមិ នៅគេហៅថា កន្លែងសហករណ៍។

**ស៖** តើពេលនោះមានប៉ុន្មានគូ? ហើយអ្នកណាជា -- តើដំណើរការឈានទៅដល់ការរៀបការរបស់លោកពូហ្នឹងធ្វើយ៉ាងដូចម្តេចដែរ លោកពូអាចបញ្ជាក់រឿងហ្នឹងបានទេ?

**ធ៖** កម្មវិធីដូចតែគ្នាហ្នឹងឯង រៀបដូចតែឯណោះ ដូចតែនៅអាងអ៊ីចឹងឯង។ ខ្ញុំរៀបនៅកន្លែងសហករណ៍ មេប្រធានសហករណ៍រៀបចំ។

[១១:២៦:៣៨]

**ស៖** មានប៉ុន្មានគូដែរ លោកពូ?

**ធ៖** ខ្ញុំ ចំនួនតែបួនគូទេ។

**ស៖** បាទ នៅក្នុងពាក្យរបស់លោកពូ ដែលមានជាភាសា -- កំណត់ហេតុរបស់លោកពូដែលមានជាភាសាខ្មែរ ERN 00295947 និងជាភាសាអង់គ្លេស 00321201 និងជាភាសាបារាំង 00702924។ នៅក្នុងនោះ លោកពូបានមានប្រសាសន៍ថា លោកពូរៀបការមានបីគូ។ អ៊ីចឹងលោកពូអាចបញ្ជាក់បានទេ ថាតើមួយណាខុស មួយណាត្រូវរវាងអ្វីដែលលោកពូបញ្ជាក់អម្បាញ់មិញថាបួនគូ ហើយនៅក្នុងនេះថាបីគូ?

**ធ៖** រាប់ៗគូដែលការ?

**ស៖** ពេលដែលពូការហ្នឹង មានប៉ុន្មានគូ? ពូអាចបញ្ជាក់ឲ្យច្បាស់ ហើយខ្ញុំអត់មានសំណួរច្រើនទៀតទេ មានតែពីរបីសំណួរទៀតទេ។ បាទ អ៊ីចឹងមិនអីទេ បើពូពិបាកនៅក្នុងការរំឭកមកវិញ ខ្ញុំក៏មិនសួរ មិនបង្ខំឲ្យពូឆ្លើយចំពោះសំណួរនេះដែរ។ លោកពូអាចបញ្ជាក់បានទេ នៅពេលរបបខ្មែរក្រហមនោះថាតើស្រី និងប្រុស គាត់ពីរនាក់ហ្នឹងអាចរៀបចំ ឬក៏គាត់អាចស្រឡាញ់គ្នារវាងគាត់ និងគាត់ ហើយស្នើឲ្យមានការរៀបការដោយខ្លួនឯងបានដែរឬទេ?

**ឆ៖** បាទ រៀបខ្លួនឯងមិនបានទេ ទាល់តែតាមរយៈមេក្រុម មេកង ទើបបានរៀបបាន។

[១១:២៩:២៩]

**ស៖** ប្រសិនបើគាត់សម្រេចរស់នៅដោយខ្លួនឯង តើអាចមានអ្វីកើតឡើងចំពោះគាត់ដែរឬទេ?

**ឆ៖** បាទ តែគាត់មានយោបល់ខ្លួនឯង គ្មានអ្នកណាគេទទួលស្គាល់ ទុកជាកំហុស មិនត្រូវ។

**ស៖** បាទ សំណួរចុងក្រោយរបស់ខ្ញុំ សម្រាប់ពេលនេះ។ ខ្ញុំចង់សួរលោកពូថា នៅពេលនោះ លោកពូជាប្រធានកងធំមួយ នៅកាន់កងចល័តនៅទំនប់។ តើលោកពូអាចយល់ ឬក៏ដឹងទេថា តើអ្វីជាគោលដៅនៃការរៀបការនាពេលនោះ ដែលថ្នាក់លើគេ -- គោលដៅនៃការរៀបការនៅសម័យនោះ គេមាននិយាយទេ?

**ឆ៖** ទេ មិនមានបញ្ហាអីនិយាយច្រើនទេ គ្រាន់តែឲ្យមកម្ចាស់ខ្លួនទាំងគូនោះសម្រេចចិត្ត សម្រេចចិត្តចប់តែប៉ុណ្ណោះ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកពូ។ ខ្ញុំដោយយល់ថាលោកពូមានបញ្ហាសុខភាព ពិបាកនៅក្នុងរំពូកឡើងវិញ ដូចលោកប្រធានមានប្រសាសន៍ ខ្ញុំមិនមានសំណួរអ្វីទៀតទេ ហើយម៉ោងក៏ដល់ដែរ។ ដូច្នេះខ្ញុំសូមអរគុណលោកពូ ហើយសូមអរគុណលោកប្រធានចំពោះការផ្តល់ឱកាសដើម្បីឲ្យខ្ញុំសួរទៅលោកសាក្សីរូបនេះ។ សូមអរគុណលោកប្រធាន។

[១១:៣១:២៨]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ប្រហែលដោយសារការបកប្រែហើយមើលទៅ។ គ្រាន់ជាការកត់សម្គាល់ទេ ថាថ្ងៃនេះគាត់សុខភាពស្រួលទេ។ នេះតាមដែលខ្ញុំយល់ តាមរយៈការបកប្រែ ហើយក៏អម្បាញ់មិញ ក៏ស្តាប់ឮថាគាត់មានសុខភាពមិនស្រួល។ ដូច្នេះយើងខ្ញុំសូមស្នើការបញ្ជាក់ ថាតើគឺគាត់សុខភាពមិនស្រួលនៅពេលនេះ ឬក៏សុខភាពនេះមិនស្រួលនៅពេលដែលគាត់បានផ្តល់ចម្លើយទៅដល់អ្នកស៊ើបអង្កេតតាំងពី៦ឆ្នាំមុន?

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញ យើងបានធ្វើការកត់សម្គាល់នូវសម្តីរបស់គាត់ គឺថាគាត់ពីមុននេះគាត់មានអាការៈបានជួបប្រទះនូវជំងឺធ្ងន់ រយៈពេលយូរ។ ហើយក្រោយមកនេះ យើងបានធ្វើកោះអញ្ជើញគាត់ដើម្បីមក

ផ្តល់សក្ខីកម្ម ហើយគាត់បានប្រឹងប្រែងដើម្បីមកផ្តល់សក្ខីកម្ម។ ដូច្នេះរយៈពេលថ្មីៗនេះ ដែលគាត់ទើបតែជាពីឈឺនេះ គាត់វាមានបញ្ហាប្រឈមលើបញ្ហាការចងចាំ លើបញ្ហានៃការឆ្លើយតបទៅនឹងសំណួរ។ យើងគ្រាន់តែឲ្យភាគីយល់អំពីបញ្ហានេះ ហើយឲ្យសម្រួលនូវសំណួរនេះឲ្យបានងាយយល់ ដើម្បីឲ្យគាត់ហ្នឹងអាចឆ្លើយតបទៅនឹងសំណួររបស់ភាគីបាន។ ចៀសវាងនិយាយវែងពេកទៅ គាត់ស្តាប់អាសំណួរដែលវែង រៀបរាប់ហ្នឹងមិនបាន ឬក៏ប្រើពាក្យហ្នឹងវប្បធម៌ពេក ដែលវាទូលំទូលាយពេក ស្តាប់វាមិនយល់ ឆ្លើយវាមិនកើត។ ឧទាហរណ៍សួរថា តើឃើញសកម្មភាពនៃអាពាហ៍ពិពាហ៍ហ្នឹងយ៉ាងម៉េច? អាហ្នឹងវាទាមទារការរៀបរាប់វែង។ បើថាឃើញអ្នកណាខ្លះចូលអីអ៊ីចឹងទៅ ជាគណៈអធិបតី អាហ្នឹងវាងាយជាង វាឲ្យវាបញ្ហាវាងាយប៉ុណ្ណឹងទេ។

បាទ ឥឡូវនេះដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សារបស់គាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមសហមេធាវីការពារក្តីជនជាប់ចោទ ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយដំបូងនេះ ប្រគល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរសហការី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សាក្សីខ្ញុំមានសំណួរមួយចំនួនសួរទៅលោកនៅរសៀលនេះ។ ដំបូង ខ្ញុំសូមពិនិត្យឡើងវិញនូវអ្វីដែលលោកបានលើកឡើងមុនពេលបាយថ្ងៃត្រង់។ តាមដែលខ្ញុំយល់ ប្រហែលជាអាចជាការយល់មិនត្រឹមត្រូវទេ ប៉ុន្តែលោកបាននិយាយអំពីជំងឺ។ លោកថាលោកបានធ្លាក់ខ្លួនឈឺ ហើយលោកមានបញ្ហាបាត់បង់ការចងចាំ។ តើវត្តមាន ឬក៏ថាស្ថានភាពដែលនៃការចងចាំនេះ វាមានពាក់ព័ន្ធអ្វីដែលទៅដល់វាធ្វើឲ្យប៉ះពាល់ដល់ការឆ្លើយរបស់លោកទៅនឹងអ្នកស៊ើបអង្កេត៦ឆ្នាំកន្លងមកហើយទេ?

[១៣:៣១:៥០]

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបនឹងសំណួរដែលសួរ ឬមួយក៏លោកស្តាប់បានទេ?

**លោក ឈុយ ហ៊ុយ៖**

នៅមិនទាន់យល់ ស្តាប់មិនបាន។

**ប្រធានអង្គជំនុំ៖**

លោក១ ស្តាប់ -- ឥឡូវស្តាប់ឮខ្ញុំនិយាយដែរឬទេ?

លោក វ៉ិចទ័រ កូប៉េ រៀបចំនូវសំណួរម្តងទៀត ហើយសូមរៀបចំសំណួរសាមញ្ញបានហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងរៀបចំយ៉ាងដូច្នេះ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ឥឡូវនេះលោកនៅមានជំងឺក្នុងខ្លួនទេ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** នៅមាន។ ដូចមិនសូវច្បាស់ នៅតែដូចជាភាំងៗស្មារតី។ និយាយភ្លេច ភាំងភ្លាត់ៗ អត់ច្បាស់។

[១៣:៣៣:០៥]

**ស៖** ជំងឺដែលលោកកំពុងតែមាននេះ បើខ្ញុំយល់មិនច្រឡំទេ វាជំងឺនេះវាធ្វើឲ្យប៉ះពាល់ដល់ការចងចាំរបស់លោក មែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកមានស្ថានភាពដូចគ្នានេះដែរឬទេ កាលពីប្រាំ ប្រាំមួយឆ្នាំកន្លងទៅនោះ នៅពេលដែលលោកបានឆ្លើយប្រាប់ទៅមន្ត្រីស៊ើបអង្កេត?

**ឆ៖** បាទ មិនបានចងចាំអស់ទេ វាភ្លាំងភ្លាត់ គិតមិនយល់អស់។

**ស៖** តើជំងឺនេះ វាប៉ះពាល់ដល់សមត្ថភាពចងចាំរបស់លោកទេ? ហើយបើវាប៉ះពាល់ហ្នឹង វាយ៉ាងម៉េចដែរ? ប៉ះក្នុងកម្រិតណាដែរ?

**ឆ៖** ស្តាប់ន័យអត់បានទេ យ៉ាងណាទេ។ ស្តាប់មិនយល់ទេ។

**ស៖** តើវេជ្ជបណ្ឌិតមានបានប្រាប់មកលោកថា លោកពិតជាមានបញ្ហាក្នុងការចងចាំមែនទេ?

**ឆ៖** មិនដឹងថាយ៉ាងណា ស្តាប់អត់បាន។

**ស៖** លោកបានឆ្លើយថា លោកមានបញ្ហាក្នុងការចងចាំ។ លោកដឹងទេថា ហេតុអ្វីបានលោកបាត់បង់ការចងចាំ? តើគ្រូពេទ្យមានប្រាប់មូលហេតុមកលោក ប្រាប់មូលហេតុនៃការបាត់ការចងចាំនេះមកប្រាប់លោកទេ?

**ឆ៖** មិនប្រាប់ទេ។

**ស៖** ចុះខ្លួនលោកផ្ទាល់ លោកអាចប្រាប់អំពីមូលហេតុវាបានទេ? តើបញ្ហានៃការបាត់បងការចងចាំនេះ ក្នុងខ្លួនលោក ក្នុងនេះលោកហ្នឹង ថាតើវាមកពីបញ្ហាអ្វីដែរ?

[១៣:៣៦:១៧]

**ឆ៖** បាទ វាមានជំងឺច្រើន គ្រូពេទ្យប្រាប់ថាជំងឺរោគជាច្រើន។

**ស៖** តើលោកកំពុងតែជួបប្រទះនឹងការលំបាក ឬក៏ថាការបាត់បង់ការចងចាំនេះ វាទើបតែកើតក្នុងពេលថ្មីៗនេះ ឬក៏វាកើតមកពីជំនាន់ ប៉ុល ពត ជិត៤០ឆ្នាំមកហើយនោះ?

**ឆ៖** ទេ កើតកន្លងរយៈចំនួនពីរខែបីខែដែលមិនស្រួលថ្មីៗ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមរំខានបន្តិច លោកមេធាវីការពារក្តី។ យើងបានទទួលរបាយការណ៍លម្អិតពីខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញទៅ ឃើញអំពីប្រវត្តិសាវតារនៃជំងឺរបស់គាត់ហើយ ហើយលោកបន្តទៅមុខទៀតទៅ ចាំយើងសួរមកក្រោយវិញអំពីជំងឺរបស់គាត់នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម ហ្វេនស៍។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ ខ្ញុំសុំសួរសំណួរខ្លីៗ ទៅនឹងអ្វីដែលលោកបានឆ្លើយមុនពេលយើងឈប់សម្រាកបាយថ្ងៃត្រង់។ ឧទាហរណ៍ជាក់ស្តែងមួយ គឺខ្ញុំចង់ដឹងអំពីថា តើវាមានភាពខុសគ្នាទេអ្វីដែលលោកកំពុងតែឆ្លើយនៅពេលនេះ និងអ្វី និងរយៈពេលជិត៤០ឆ្នាំមកនោះ? ព្រឹកមិញលោកឆ្លើយថា លោកបានឮសូរសំឡេងគ្រាប់បាញ់សម្លាប់មនុស្សម្នាក់ ប៉ុន្តែអង្កាល់ពីប៉ុន្មានឆ្នាំនោះ លោកឆ្លើយថា៖ “ខ្ញុំបានឃើញគេបាញ់សម្លាប់មនុស្សផ្ទាល់ភ្នែក”។ សូមលោកពន្យល់ចំណុចពីរនេះបន្តិចបានទេ? ទី១ លោកបានថា បានឮ ហើយឥឡូវនេះលោកថា លោកមិនបានឃើញទេ ប៉ុន្តែមុនហ្នឹង ឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា លោកបានឃើញគេបាញ់សម្លាប់មនុស្ស។

[១៣:៣៨:៥៧]

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ បានឮ ហៅថាវាជិតក្បែរ ជិតក្បែរកន្លែងធ្វើការនោះ ហៅថាបានឃើញ បានឮ។

**ស៖** លោកចាំទេ នៅពេលដែលលោកឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេត ប្រាំប្រាំមួយឆ្នាំកន្លងទៅហើយ ហើយតើកំណត់ហេតុនេះ ពេលសរសេរចប់ហើយ គេមានអានឲ្យលោកស្តាប់ទេ មុននឹងលោកផ្តិតមេដៃ?

**ឆ៖** បាទ មានតើ ប៉ុន្តែមិនចងចាំ នៅតែភ្លេច។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញសាក្សីនូវទំព័រចុងក្រោយនៃចម្លើយរបស់គាត់។ ខ្ញុំចង់សុំសួរទៅគាត់មើល៍ ថាតើនេះជាអក្សរគាត់សរសេរដោយដៃ ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

លោក ឈុយ ហ៊ុយ លោកចេះអក្សរទេ?

**លោក ឈុយ ហ៊ុយ៖**

អត់ចេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែខ្ញុំនៅតែសុំការអនុញ្ញាតសូមបង្ហាញគាត់ទោះមិនចេះអក្សរក្ដី ក្រែងគាត់ចំណាំបានអ្វីមួយនៅលើទំព័រនេះ។ ដោយសារថាយ៉ាងដូច្នេះ នៅអត្ថបទជាភាសាអង់គ្លេសដែលខ្ញុំមាន គឺៗខ្ញុំសូមសួរតែគំនូសទេ គាត់មិនចេះអក្សរទៅហើយ ប៉ុន្តែខ្ញុំសូមសួរអំពីនេះ គំនូសនៅលើឯកសារមួយនេះ។

[១៣:៤១:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកចាំទេនៅលើទំព័រនេះ នេះគឺជាអ្វីដែលលោកបានគូរមែនទេ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** មិនដែលៗបានឃើញទេ។

**ស៖** បាទ មិនថ្វីទេ។ លោកប្រធាន បាទខ្ញុំសុំឯកសារនេះវិញ។

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** លោកសាក្សី ក្បាលមីក្រូអត់ទាន់បើកទេ លោកចង់ឆ្លើយឡើងវិញ យ៉ាងម៉េចដែរ?

**ឆ៖** បាទ មានៗ យល់ទេ។

**ស៖** បាទ មិនថ្វីទេលោកខ្ញុំបន្តទៅមុខទៀត។ លោកឆ្លើយពីខាងដើមថា កងរបស់លោកក៏ធ្វើការនៅពេលយប់ដែរ។ តើលោកចង់និយាយថាម៉េច នៅពេលដែលលោកថាកងរបស់លោកក៏ធ្វើការនៅពេលយប់ដែរ? ធ្វើការពីម៉ោងប៉ុន្មាន ទៅដល់ម៉ោងប៉ុន្មាន?

**ឆ៖** ធ្វើការទៅតាមសភាព ហៅថាមិនពេញនាទីទេ ធ្វើដោយហៅថាល្បឿនដែលវាលិចលង់បន្តិចបន្តួច។ មិនគោលដៅមិនទៀងមិនទាត់ទេ ដែលវាលិចទាបត្រង់ណា ក៏ជួសជុលបំប៉នបន្តិចបន្តួចតែប៉ុណ្ណោះឯង។

[១៣:៤៥:០៤]

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺរយៈពេលពីម៉ោងប្រាំមួយល្ងាចទៅនេះ វាមិនមានពេលកំណត់នេះច្បាស់លាស់ក្នុងភាសាខ្មែរ ប៉ុន្តែចាប់ពីម៉ោង -- តើការងារពេលយប់នេះ ចាប់ផ្ដើមពីម៉ោងប៉ុន្មានលោក? ចាប់ធ្វើពីម៉ោងប្រាំមួយ ម៉ោងប្រាំបួន ឬក៏ម៉ោងដប់?

**ឆ៖** បាទ ចាប់ផ្ដើមពីម៉ោងប្រាំពីរ។ ម៉ោងប្រាំពីរ ម៉ោងប្រាំបួនចប់។

**ស៖** មានសាក្សីមួយចំនួនបានឆ្លើយនៅចំពោះមុខតុលាការថា ម៉ោងការងារពេលយប់នេះ គឺគេធ្វើតែនៅពេលណាដែលមានពន្លឺព្រះចន្ទទេ ធ្វើតែនៅក្នុងខែភ្លឺទេ។ តើលោកយល់ថា យ៉ាងដូច្នេះដែរទេ?

**ឆ៖** បាទ ខែភ្លឺបានធ្វើបាន ខែងងឹតធ្វើមិនបាន។

**ស៖** ហើយព្រឹកមិញនេះ លោកក៏ត្រូវបានសួរអំពីពាក្យថា "ខ្វាក់មាន់ ឬក៏ងងឹតមាន់" នេះ តើលោកមានបានដឹងទេពេលនុ៎ង មានអ្វីដែលនាំឲ្យមនុស្សមានជំងឺ ប្រជាជនមានជំងឺខ្វាក់មាន់?

**ឆ៖** បាទ យល់ដឹងខ្លះ ព្រោះតាមហៅថា មេក្រុមគេ ដែលវាងងឹតហើយ ស្រេចនឹងប្រធានក្រុមគេចាត់ចែង ឲ្យនៅកន្លែង ទៅមិនរួច។

**ស៖** ប៉ុន្តែ ខ្ញុំសួរអ៊ីចេះលោក តើនៅពេលនោះគេមានប្រាប់លោកថា មានមូលហេតុអីដែលបណ្ដាលឲ្យកម្មករ ពលករហ្នឹងមានជំងឺខ្វាក់មាន់ហ្នឹងដែរទេ?

[១៣:៤៧:៥៩]

**ឆ៖** គ្មានទេ ឮថាពាក្យថា "ងងឹតមាន់" ទៅមិនរួច ប្រធានគេ ក្រុមគេឲ្យនៅតាមកន្លែងសម្រាកតាមកន្លែង។

**ស៖** ក្នុងចម្លើយរបស់លោក ERN អង់គ្លេស 0032102, បារាំង 00702923, ខ្មែរ 00295946។ លោកបានឆ្លើយថា ទិត សាម៉េត ជា-- គឺថាគេជាអ្នកទទួលខុសត្រូវខាងផ្នែកត្រីសាច់។ អ៊ីចឹងឯងបានជាលោកត្រូវបានគេចាត់តាំងឲ្យដើររកត្រី។ តើនេះ គឺជាចម្លើយរបស់លោកឆ្លើយប្រាប់អ្នកស៊ើបអង្កេត អ៊ីចឹងមែនទេ?

**ឆ៖** សាម៉េត ដែលស្គាល់ណា សាម៉េត។ មិនយល់ មិនស្គាល់។

**ស៖** ប៉ុន្តែយ៉ាងហោចណាស់ក៏សម្រង់ដែលខ្ញុំអានឲ្យលោកស្ដាប់នេះ គឺលោកមិនចងចាំទេឬ?

**ឆ៖** ស្ដាប់មិនបានទេ វាដូចថា សាម៉េត ណានោះ ឈ្មោះ សាម៉េត ណាអត់ស្គាល់ទេ។

**ស៖** បាទ ប្រហែលជាអាចជាកំហុសរបស់ខ្ញុំ លោក។ ឥឡូវខ្ញុំរៀបសំណួរឡើងវិញទៅចុះ។

តើកងរបស់លោកត្រូវទទួលខុសត្រូវទៅរកត្រីសាច់ ឬអត់ទេ កងរបស់លោកទាំងមូលតែម្តង?

**ឆ៖** បាទ ទៅតាម ហៅថាដោះស្រាយតាមកង ចាត់ចែងឲ្យរក ជាសេដ្ឋកិច្ចត្រី។

**ស៖** តើកងរបស់លោកអាចរកត្រីបានជារៀងរាល់ថ្ងៃទេ?

**ឆ៖** បាទ រកបាន ដោះស្រាយគ្រប់គ្រាន់។

**ស៖** តើសមាជិកនៅក្នុងកងរបស់លោកហ្នឹង មានត្រីនិងបាយហូបរាល់ថ្ងៃដែរឬទេ?

**ឆ៖** បាទ បានហូប ហៅថាមានការដាច់ខ្លះៗ។ មិនជាប់រាល់ថ្ងៃទេ មានពេលដាច់ ដោះស្រាយតាម ហៅថាមេទំនប់ដោះស្រាយ ដូចជា ត្រីងៀត អំបិល ប្រហុក បាទ។

[១៣:៥២:២០]

**ស៖** ចុះបន្លែវិញ តើលោកមានបន្លែហូបរាល់ថ្ងៃទេ បន្លែមពីលើបាយ?

**ឆ៖** បាទ មានដំណោះស្រាយធម្មតា ថ្ងៃណាទៅក៏មាន ថ្ងៃណាទៅក៏អត់។

**ស៖** ហើយថាតើលោកចាំទេ កងលោកហ្នឹងបានបន្លែអ្វីដែរហូបប្រចាំថ្ងៃនុំង?

**ឆ៖** បាទ មានបន្លែត្រកួនតាមវាល ដុះតាមវាល អាចបេះធ្វើជាបន្លែបានដែរ សម្បូរណាស់បន្លែត្រកួនតាមវាលស្រែនោះ។

**ស៖** នៅពេលនោះ តើលោកធ្លាប់ឮថា -- តើលោកធ្លាប់ឮអំពីចំណុចទី១ គឺនិយាយអំពីការដែលមានត្រីសាច់ហូបជាប្រចាំហ្នឹង? ហើយនិងចំណុចទី២ តើលោកឮថា មានមនុស្សកើតជំងឺខ្វាក់មាន់ទេ?

**ឆ៖** បាទ មានខ្លះៗតើ។ មានឃើញ គ្នាដើរជល់ដុំ ជល់ ធ្លាក់កន្ធុកមានតើ ពិតមែន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមរំខានលោកបន្តិច ដូច្នេះលោកមានពេលវេលារៀបចំសំណួរឡើងវិញ។ ដូច្នេះមិនមានរបាយការណ៍បញ្ជាក់អំពីសាក្សីរូបនេះទេ។ អ៊ីចឹងកាលណាសួរពាក់ព័ន្ធនឹងសុខភាពរបស់គាត់ អនុញ្ញាតឲ្យសួរ គឺថាឲ្យតែទាក់ទង និងសមស្រប។

**លោក វិចទ័រ កូប៉េ៖**

តើអង្គជំនុំជម្រះមានបានដឹងទេ ថាមានរបាយការណ៍ហ្នឹង ឬក៏មិនមានទេ? ពីព្រោះខ្ញុំទើបតែទទួលបានអ៊ីម៉ែល ហើយខ្ញុំដឹងថា វាមានបញ្ហាអ្វីនោះ។

[១៣:៥៥:៣៥]

**ប្រធានអង្គជំនុំ៖**

យើងខ្ញុំមិនមានការដាក់របាយការណ៍ពាក់ព័ន្ធជាមួយនឹងបញ្ហាសុខភាពរបស់គាត់ទេ។ ខ្ញុំបានទទួលព័ត៌មានព្រឹកមិញ ដោយសារការកត់សម្គាល់យើងខ្ញុំ ក្នុងនាមប្រធានអង្គជំនុំជម្រះ អំពីបញ្ហាគាត់ចម្លើយរបស់គាត់ វាមិនឆ្លើយតបបានល្អិតល្អន់ ដូចលទ្ធផលដែលគាត់បានឆ្លើយនៅក្នុងកំណត់ហេតុដែលគាត់ផ្តល់ចម្លើយឲ្យអ្នកស៊ើបអង្កេតកាលពីឆ្នាំ២០០៩។ ហើយតាមរយៈក្រឡាបញ្ជី គឺគាត់បានផ្តល់នូវព័ត៌មានឲ្យខ្ញុំថា តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនថា សាក្សីរូបនេះក្រោយពេលដែលគាត់បានជាសះស្បើយពីជំងឺ មុនពេលដែលគាត់មកផ្តល់សក្ខីកម្មនេះ គាត់មានបញ្ហាភ្លេចភ្លាំងស្មារតីក្នុងការឆ្លើយតប។ អ៊ីចឹងហើយបានសុំឲ្យខ្ញុំហ្នឹង ជម្រាបទៅភាគីដើម្បីឲ្យសម្រួលក្នុងការតាំងសំណួរហ្នឹងធ្វើយ៉ាងណាឲ្យគាត់អាចមានសមត្ថភាព និងលទ្ធភាពអាចស្តាប់នូវសំណួរខ្លីៗ ដើម្បីអាចឆ្លើយតបបាន ដើម្បីឲ្យដំណើរការសវនាការនៅថ្ងៃនេះប្រព្រឹត្តទៅបានល្អ ដូចអ្វីដែលយើងបាន យើងខ្ញុំបានជម្រាបជូនបន្ថែមទៀតនៅពេលមុនពេលសម្រាកអាហារថ្ងៃត្រង់។ រឿងប៉ុណ្ណឹងទេ អ៊ីចឹងហើយបានជាយើងមិនយកបញ្ហានោះយកមកសង្កត់ធ្ងន់ ថាតើយើងពិភាក្សាលើបញ្ហារបាយការណ៍ពាក់ព័ន្ធនឹងការវាយតម្លៃនោះ ថាតើត្រូវធ្វើសវនាការឬអត់ តាំងពីព្រឹកមិញនោះ ដោយសារថាយើងមិនមានព័ត៌មានអីដែលថារហូតដល់វាពិភាក្សា ថាកំណត់ថា ត្រូវស្តាប់សក្ខីកម្មគាត់ពេលនេះ ឬក៏ត្រូវលើកទៅថ្ងៃក្រោយនោះទេ។ គ្រាន់តែថាវាស្ថានភាពក្រោយពេលបានជាសះស្បើយឡើងវិញហ្នឹង គឺស្ថានភាពនៃការចងចាំរបស់គាត់មានបញ្ហាភ្លេចភ្លាំងខ្លះៗប៉ុណ្ណោះ។

[១៣:៥៧:៣០]

**លោក វិចទ័រ កូប៉េ៖**

បាទ ខ្ញុំយល់ហើយលោកប្រធាន ប៉ុន្តែថាតើការចងចាំរបស់គាត់នេះ វាទើបតែប៉ះពាល់ពេលវេលានេះ ទើបពីព្រឹកមិញទេឬ? ហើយថាតើជំងឺនេះវាប៉ះពាល់ដល់អ្វី ហើយការចងចាំនេះ វាបណ្តាលមកពីអ្វី? នេះគឺជាចំណុចខ្វះចន្លោះខុសគ្នារវាង កំណត់ -- ដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់កាលពីលើកមុន និងនាពេលនេះ។ ដូច្នេះយើងខ្ញុំគឺថា បានជាខ្ញុំសួរថាតើ ទោះបីជារបាយ-ការណ៍នោះខ្លី វែងអីយ៉ាងម៉េចអីក្តី បែបណាក្តី បើសិនជាអង្គជំនុំជម្រះបានទទួលពីអង្គភាពគាំពារនិងសាក្សី ឬអ្នកជំនាញ យើងខ្ញុំចង់សុំពិនិត្យមើលឯកសារណាមួយដែលបានមកពីនោះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ទី១ យើងឲ្យលោកបន្តនូវការតាំងសំណួរតទៅទៀតនាពេលនេះ ពីព្រោះខាងសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខបានខិតខំប្រឹងប្រែងការតាំងសំណួរតាមលទ្ធភាពដែលអាចធ្វើទៅបានរួចហើយ។ បញ្ហាទី២ គឺយើងចាត់ឲ្យក្រឡាបញ្ជីសវនាការទាក់ទងជាមួយនឹងខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នូវរបាយការណ៍ពាក់ព័ន្ធជាមួយនឹងសាក្សីរូបនេះ ដើម្បីផ្ដល់ជូនភាគីពាក់ព័ន្ធនាពេលឲ្យបានឆាប់ ឥឡូវៗនេះ តាមតែអាចធ្វើទៅបាន។

[១៣:៥៩:០៤]

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវខ្ញុំសូមបន្តទៅសួរពាក់ព័ន្ធទៅនឹងសុខភាព បាទស្ថានភាពសុខភាពនៅការដ្ឋានលើកទំនប់នោះ។ តើលោកដឹងថា ប្រជាជនធ្វើការនៅឯ កម្លាំងដែលធ្វើការនៅការដ្ឋានហ្នឹងមានជំងឺរាករូសអីដែរទេ? មានជំងឺអាសន្នរោគដែរទេ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ មានខ្លះៗ។ មាននៅក្នុងតាមកន្លែង តែឈឺហើយនៅតាមកន្លែង សម្រាក អ្នកជាធ្វើការបាទ។

**ស៖** ហើយធ្វើម៉េចទើបលោកអាចសន្និដ្ឋាន ឬក៏ថាតើពេទ្យនៅពេលនោះមានប្រាប់លោកថា វាមូលហេតុអីបានជាប្រជាជនមានជំងឺអាសន្នរោគដែរទេ?

**ឆ៖** មិនយល់ដឹងផងកន្លែងនោះ ស្រេចទៅនឹងគ្រូពេទ្យព្យាបាលជានិច្ច តាម។

**ស៖** តាមរយៈកំណត់ហេតុស្ដាប់ចម្លើយរបស់លោកគឺថា មានអ្នកខ្លះនៅពេលធ្លាក់ខ្លួនឈឺហ្នឹងគឺថាមិនអាចជាសះស្បើយឡើងវិញទេ ត្រូវតែបញ្ជូនទៅមន្ទីរពេទ្យស្រុក។ តើមន្ទីរពេទ្យស្រុកហ្នឹងឈ្មោះអ្វីដែរ? តើជាមន្ទីរពេទ្យស្រុកអន្លង់សារមែនទេ?

**ឆ៖** បាទ មិនដឹង តើកន្លែងនោះ មិនឮមិនដឹងទេ មិនសូវយល់ផង។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំលោកសាក្សី។ លោកនៅនឹកឃើញទេ ថាសមាជិកក្នុងកងរបស់លោកហ្នឹងមានមុងសម្រាប់ចងដេកទេ?

**ឆ៖** មិនដែលមានទេសម័យនោះ អត់ទាំងអស់។

[១៤:០២:០៣]

**ស៖** តើលោកឆ្លើយថាមិនមានមុងទាំងអស់ហ្នឹង តែកងរបស់លោកទេ ឬក៏កងផ្សេងទៀតក៏មិនមានមុងដែរ?

**ឆ៖** ទាំងអស់ អត់ទាំងអស់។

**ស៖** នេះជាសំណួរចុងក្រោយមែនទែនហើយលោក។ កាលពីសប្តាហ៍មុនមានសាក្សីម្នាក់បានឆ្លើយថា នៅពេលយប់ហ្នឹងគឺថាគាត់ដេកគាត់មានមុង មានមុងចងដេក។ តើលោកអាចឆ្លើយបានទេ សាក្សីម្នាក់នេះជាមនុស្សម្នាក់ពិសេស ឬក៏លើកលែង ឬក៏យ៉ាងម៉េចបានជាគាត់មានមុងដេក ហើយលោកឆ្លើយថាអត់មានទាំងអស់គ្នា?

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញបាទ!

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន ខ្ញុំគិតថាវានឹងជួយដល់អង្គជំនុំជម្រះ ហើយនិងអង្គសវនាការទាំងមូល ប្រសិនបើមេធាវីអាចយោងទៅដល់ឯកសារដែលគាត់កំពុងតែប្រាប់នេះ ពីព្រោះគាត់ថាសាក្សីមួយ ហើយមិនដឹងសាក្សីមួយណា ហើយឯកសារណា ឬក៏ឈ្មោះសាក្សីណាដែលគាត់យោងដល់ហ្នឹង។ អ៊ីចឹងសូមឲ្យមេធាវីផ្តល់លេខឯកសារ និងលេខ ERN ផងលោកប្រធាន។

[១៤:០៣:៤១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអត់ទាន់មាននៅខាងមុខខ្ញុំនៅឡើយទេ ប៉ុន្តែសាក្សីដែលមកឆ្លើយពីសប្តាហ៍មុននេះ--

**លោក ត្រាវីស ហ្វារ៖**

បើសិនណាជាសាក្សី ខ្ញុំស្តាប់ឮសាក្សីម្នាក់បានឆ្លើយថា គេអនុញ្ញាតឲ្យគាត់យកមុងមកដោយខ្លួនឯង គេអត់បានបើកឲ្យនៅការដ្ឋាននោះទេ។ ហ្នឹងខ្ញុំស្តាប់ឮ សូមជួយបញ្ជាក់បានថាយ៉ាងដូច្នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ហ្នឹងគឺជាគោលបំណងនៃសំណួររបស់ខ្ញុំហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើវាត្រឹមត្រូវទេដែលខ្ញុំសួរសាក្សីរូបនេះថា អារឿងដែលសាក្សីហ្នឹងគាត់ថាគាត់មានមុងហ្នឹង វាជារឿងអាចមានកងណាមួយមានមុងដែរឬក៏អត់? ម៉េចឥឡូវខ្ញុំរៀបសំណួរឡើងវិញ។ តើលោកដឹងថាកងដទៃទៀតត្រូវបានគេចែកមុងឲ្យប្រើប្រាស់ដែរទេ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ មិនទាន់ឃើញទេ។ មិនឃើញមានមុងទេ មានតែដែលហៅថារបស់ខ្លួនយកទៅពីផ្ទះមួយពីរ។

[១៤:០៥:១៧]

**ស៖** មួយពីរហ្នឹងក្នុងកងរបស់លោក លោកថាមានមុងមួយ ឬពីរបានឃើញ ហើយក្នុងកងរបស់លោក ឬក៏លោកឃើញនៅឯណា?

**ឆ៖** ថាក្នុងកងខ្ញុំបាទ ដែលហៅថា បានដោះស្រាយពីផ្ទះទៅ ក៏យកទៅជាប់ជាមួយ។ ផុតពីនោះទៅ មិនដឹងដល់ដែរ មិនដឹងថាមាន មិនមាន។

**ស៖** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ គឺថាសមាជិកស្ទើរតែទាំងអស់ក្នុងកងរបស់លោកមានមុងដេក អ៊ីចឹងឬក៏អត់ទេ?

**ឆ៖** វាខាងហៅថាមិនរដូវឆ្នាំ ទាល់តែធ្វើឡើងយូរខែឆ្នាំណោះ បានមានផ្តល់មកឲ្យ។ ខាងដើមមិនមានទេ រយៈមួយឆ្នាំ ឬពីរឆ្នាំដាច់មិនមានប្រើប្រាស់ទេ។ រយៈដល់ពីរទៅបីឆ្នាំ បានថ្នាក់លើផ្តល់ឲ្យសម្លៀកបំពាក់ ទាំងខោអាវ។

**លោក វ៉ិចទ័រ កូប៉េ៖**

ដើម្បីឲ្យវាមានលក្ខណៈពេញលេញ ខ្ញុំយោងទៅលើឯកសារ E3/ *អ៊ីងគ្លីស* ERN 00277822 ដែលបានឆ្លើយនៅក្នុងឯកសារ E3/7803 ថាគាត់បានឆ្លើយថាគាត់មានមុងដេក។ បាទ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សាក្សីរូបនេះឈ្មោះ១ កាន ថុល។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក នួន ជា!

[១៤:០៧:៣៦]

**លោក លីវ សុវណ្ណា៖**

ខ្ញុំបាទសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការ ខ្ញុំបាទឈ្មោះ លីវ សុវណ្ណា ជាមេធាវីជាតិក្នុងក្រុមការពារលោក នួន ជា។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ខ្ញុំបាទសូមជម្រាបសួរលោកសាក្សី ខ្ញុំបាទ សូមតាំងសំណួរពីរបីសំណួរ។ ទី១ វេនធ្វើការពេលថ្ងៃ តើគេចាប់ផ្ដើមធ្វើការពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មានវេនព្រឹក?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ ពេលព្រឹកចាប់ផ្ដើមពីម៉ោង ហៅថាម៉ោងប្រាំមួយ ទល់ទៅម៉ោងដប់មួយ។

**ស៖** ចុះវេនល្ងាចវិញ គេចាប់ផ្ដើមពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន?

**ឆ៖** ពេលល្ងាចម៉ោងបី ទៅម៉ោងប្រាំ។

**ស៖** ក្នុងវេនព្រឹក និងវេនល្ងាចហ្នឹង តើមានគេមានឲ្យឈប់សម្រាករយៈពេលខ្លីដែរឬទេ?

**ឆ៖** ទៅតាមវិធានការឯកភាពក្នុងក្រុម ក្នុងកង ត្រូវឯកភាពគ្នាសម្រាកតាមហៅថានឿយហត់អី សម្រាកតាមឯកភាព តាមក្រុមៗ។

**ស៖** តើកងរបស់លោកមានការឈប់សម្រាករយៈពេលខ្លី នៅពេលនឿយហត់អីចឹងអីទេ?

**ឆ៖** បាទ ខ្ញុំកូនកងហៅថាសម្លាញ់ខ្ញុំពេញចិត្ត ខ្ញុំធ្វើអត់ឲ្យប៉ះពាល់ តែនឿយខ្ញុំឲ្យឈប់ នឿយខ្ញុំឲ្យឈប់។ បាទគាត់ក៏ត្រេកអរនឹងខ្ញុំខ្លាំង។

[១៤:១០:០៥]

**ស៖** កាលពីព្រឹកមិញ លោកថា កងរបស់លោកគេចែកផែនការងារ គឺ២ម៉ែត្រគូបក្នុងមួយថ្ងៃសម្រាប់មនុស្សម្នាក់។ អីចឹងសំណួរខ្ញុំសួរថា តើក្រុមរបស់លោកមានអ្នកដែលធ្វើការមិនហើយតាមផែនការដែរទេ?

**ឆ៖** បាទ វាមានគ្រាន់តែយឺតយ៉ាវ ជាមុន ជាក្រោយ ហើយយើងខ្ញុំ បើអ្នកណាមិនទាន់ផែនការគឺយើងខ្ញុំអាចទាញកម្លាំងដើម្បីកាប់ឲ្យបានទាន់ទៅតាមផែនការ។

**ស៖** អ្នកដែលធ្វើមិនបានតាមផែនការ ហើយលោកបានទាញកម្លាំងជួយហ្នឹង ក្រៅពីការជួយគាត់ហើយ តើលោកមានបានដាក់ទណ្ឌកម្ម ឬក៏ស្ដីបន្ទោសអ្វីដល់គាត់ដែរឬទេ?

**ឆ៖** អត់ទេ ព្រោះមើលទៅកម្លាំងរាងខ្សោយ មានអត់មានបញ្ហាស្ដីបន្ទោសទៅលើរូបនោះទេ មានតែយឹតយោងគ្នាជួយតែប៉ុណ្ណោះ។

**ស៖** តាមការកត់សម្គាល់របស់លោក នៅក្នុងក្រុមរបស់លោក ឬក៏ក្រុមជិតខាងរបស់លោក តើនៅក្នុងអំឡុងពេលធ្វើការហ្នឹង មានអ្នកណាទទួលរងគ្រោះថ្នាក់ពីការងារហ្នឹងរហូតដល់បាត់បង់ជីវិតអីដែរឬទេ?

**ឆ៖** អត់មានទេ សុខសប្បាយ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន សំណួរចុងក្រោយជាសំណួរដែលមានទៅជាពីរផ្នែក។ ទី១ សួរអំពីគ្រោះថ្នាក់ការងារ ហើយមួយទៀត សួរថាតើមានឃើញគេយកមនុស្សទៅសម្លាប់ចោលឬទេ? ការសួរមួយសំណួរ ច្បាមយកដល់ពីរចំណុចនេះ ធ្វើឱ្យសាក្សីមានការច្របូកច្របល់។ អ៊ីចឹងសូមឱ្យញែកសំណួរឱ្យដាច់ៗពីគ្នា។

[១៤:១២:៤៤]

**លោក លីវ សុវណ្ណា៖**

បាទ សូមគោរពលោកប្រធាន។ ការពិតប្រហែលជាមានបញ្ហាបកប្រែ ព្រោះសំណួរខ្ញុំអំមិញសួរថា តើមានគ្រោះថ្នាក់ការងារបណ្ដាលឱ្យដល់មានការស្លាប់បាត់បង់ជីវិតអីដែរទេបាទ។ អ៊ីចឹងបាទ។

**ប្រធានអង្គជំនុំ៖**

បញ្ជាក់សំណួរហ្នឹងម្ដងទៀត ហើយឱ្យសាក្សីឆ្លើយម្ដងទៀត!

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ ខ្ញុំសូមបញ្ជាក់សំណួរខ្ញុំឡើងវិញ គឺសំណួរខ្ញុំថា តើក្នុងអំឡុងពេលធ្វើការងារហ្នឹង តាមការកត់សម្គាល់របស់លោក តើមានពលករណាមួយជួបនឹងគ្រោះថ្នាក់ការងារដែរឬទេ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ អត់ទេ ក្នុងអំឡុងពលកម្មនោះ អត់មានបញ្ហាទេ។

**ស៖** ចុះលោកមានដែលឃើញ ពេលដែលពលករកំពុងធ្វើការហ្នឹងមានយោធាគេដើរយាមពលករដែរឬទេ?

**ឆ៖** បាទ មានតើ តាមជាប់ជានិច្ចនៅតាមខ្សែត្រៀមពលកម្ម។

[១៤:១៤:១៩]

**ស៖** តើការដែលយាមហ្នឹង គាត់យាមដើម្បីអ្វី?

**ឆ៖** បាទ មិនដឹងផង គាត់ដើរអង្គុយត្រង់ណេះបន្តិច ត្រង់ណោះបន្តិច មិនដឹងទេ។

**ស៖** គាត់យាមហ្នឹងនៅចម្ងាយប៉ុន្មានម៉ែត្រពីកន្លែងដែលធ្វើការ?

**ឆ៖** មិនបានឆ្ងាយទេ គាត់ដើរទៅអង្គុយនិយាយជាមួយអ្នកធ្វើការនុ៎ង ដើរលេង ដើរនិយាយ អង្គុយ។

**ឆ៖** មិនឆ្ងាយទេ គាត់ដើរទៅអង្គុយនិយាយជាមួយអ្នកធ្វើការហ្នឹង។ ដើរលេង ដើរនិយាយ អង្គុយ។

**ស៖** ចុះនៅពេលដែលពលករគាត់នឿយហត់ ដែលឈប់សម្រាក ដែលលោកមានប្រសាសន៍មុនហ្នឹង ពេលហ្នឹងគឺគាត់មានស្តីឲ្យពលករ ឬក៏បង្ខំពលករត្រូវតែធ្វើការដែរឬទេ?

**ឆ៖** អត់ទេ មិនដែលមានស្តីនិយាយអីទេ។

**ស៖** អ៊ីចឹងបើសិនជាខ្ញុំយល់ឃើញថា សង្ខេបថា គឺគាត់រាល់ការងារដែលចាត់ចែងការធ្វើការងារ ក៏ដូចជាការឈប់សម្រាកជាដើមហ្នឹង ជាសិទ្ធិរបស់ប្រធានកងនីមួយៗ មិនមែនជាសិទ្ធិរបស់យោធា។ តើត្រឹមត្រូវដែរទេបាទ?

[១៤:១៦:២៩]

**ឆ៖** បាទ អត់មែនសិទ្ធិយោធាទេ គឺសិទ្ធិហៅថាអំពីមេប្រធានក្រុម ប្រធានកង។

**ស៖** អំមិញលោកបានមានប្រសាសន៍ថា ក្រុមសេដ្ឋកិច្ចសម្រាប់ដើររកត្រី រកបន្លែហ្នឹង តើក្រុមសេដ្ឋកិច្ចនេះសម្រាប់កងតូច ឬក៏កងធំ ដែលមានក្រុមសេដ្ឋកិច្ចនេះបាទ?

**ឆ៖** បាទ សម្រាប់ដោះស្រាយក្នុងមួយកងធំ។ រកត្រី ដាំបាយ អ្នកដាំបាយផ្សេង អ្នករកត្រីផ្សេង។

**ស៖** តើនៅក្នុងក្រុមសេដ្ឋកិច្ចនេះមានចំនួនប៉ុន្មាននាក់ដែរបាទ?

**ឆ៖** អ្នករកត្រីបួននាក់ ដាំបាយបួននាក់។

**ស៖** អ៊ីចឹងការដាំស្លហ្នឹង គឺគេធ្វើក្នុងក្រុមធំ ឬក៏ក្រុមតូចដែលគាត់មានភារកិច្ចដាំស្ល?

**ឆ៖** ដាំរោងក្នុងកងធំតែមួយ។

**លោក លីវ សុវណ្ណា៖**

ខ្ញុំបាទសូមអរគុណ សូមអស់សំណួរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៤:១៩:០៩]

**លោក អាកទ្វូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទ្វូរ វែកគែន៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ អាកទ្វូរ វែកគែន ខ្ញុំជាសហមេធាវីការពារលោក ខៀវ សំផន។ បាទ ជាបឋមខ្ញុំសូមចោទសំណួរបញ្ជាក់ឲ្យដឹងថា តើស្រុកកំណើតរបស់លោកនុ៎ងពិតជានៅស្រុកភ្នំស្រុកមែន ឬក៏យ៉ាងណា?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ នៅស្រុកភ្នំស្រុកពិតមែន។

**ស៖** បាទ ពីភូមិរបស់លោក ហើយនិងការដ្ឋាន ទៅការដ្ឋាននុ៎ងមានចម្ងាយប៉ុន្មានម៉ែត្រដែរ បើយើងកាត់ត្រង់តែម្តងហ្នឹង ពីផ្ទះលោកទៅការដ្ឋានទំនប់ត្រពាំងថ្មមានចម្ងាយប្រហែលប៉ុន្មាន?

**ឆ៖** បាទ មានដល់ទៅ១២គីឡូណោះ។

**ស៖** លោកបាននិយាយថា ក្នុងរយៈពេល២ឆ្នាំនោះលោកបានបួសជាព្រះសង្ឃនៅវត្តណាំតៅនៅស្រុកភ្នំស្រុកដដែល។ អ៊ីចឹងខ្ញុំសុំសួរលោកថា តើពីវត្តដែលលោកបានបួសជាលោកសង្ឃនៅទីនោះ២ឆ្នាំនោះ ទៅទំនប់ត្រពាំងថ្មនោះមានចម្ងាយប៉ុន្មានដែរ?

**ឆ៖** ប្រហែលជា១៣គីឡូម៉ែត្រណោះ ពីវត្ត។

**ស៖** ហើយវត្តហ្នឹងនៅជិតភូមិកំណើតលោកដែរ ស្រុកកំណើតលោកដែរ ឬក៏យ៉ាងណា? ឬក៏វត្ត ហើយនិងភូមិកំណើតលោកនោះនៅឆ្ងាយពីគ្នា?

**ឆ៖** ចម្ងាយពីវត្ត ចម្ងាយចំនួន៣គីឡូ។

[១៤:២១:៣៣]

**សៈ** បាទ សូមអរគុណ។ ខ្ញុំកត់សម្គាល់នូវកំណត់ហេតុស្តាប់ចម្លើយរបស់លោកកាលពីឆ្នាំ ២០១១ នោះ លោកបានបញ្ជាក់ថា លោកចេះនិយាយភាសាថៃ និងភាសាឡាវ ក្រៅពីភាសាខ្មែរ។ តើពិតជាត្រឹមត្រូវដែរឬទេ?

**ផះ** អ៊ូ! មិនមែនទេ មិនដឹងទេ។ ចេះតែតិចទេ មិនដែលបានស្គាល់ដីថៃផង។

**សៈ** ប្រហែលជាមានបញ្ហាបកប្រែទេ ព្រោះថាខ្ញុំអាន ខ្ញុំអាននោះជាភាសាបារាំង ហើយឃើញមានគូសនៅលើទម្រង់បែបបទកំណត់ហេតុស្តាប់ចម្លើយរបស់លោកហ្នឹង ដែលគេបកប្រែជាភាសាបារាំង ថាលោកចេះថៃ ហើយនិងឡាវ។ អ៊ីចឹងមិនបញ្ហាអ្វីទេ អ៊ីចឹងខ្ញុំចង់សួរលោកថា កាលដែលលោកនៅវត្តនោះ តើលោកធ្វើអ្វីខ្លះ? សកម្មភាពរបស់លោកជាប្រចាំហ្នឹង ឬក៏លោកបង្រៀនអ្នកផ្សេងទៀតនៅវត្តហ្នឹង?

**ផះ** អត់ទេ នៅជាភិក្ខុធម្មតា គ្មានបានចេះដល់ទៅគ្រូអីបង្ហាត់បង្រៀនទេ។

**សៈ** កាលពីព្រឹកមិញ នៅពេលដែលគេចោទសំណួរលោកទាក់ទងនឹងប្រវត្តិរូបរបស់លោក លោកបានឆ្លើយថា អ្នកទាំងអស់គ្នាហ្នឹងបានធ្វើប្រវត្តិរូប ហើយលោកខ្លួនឯងផ្ទាល់ក៏បាននិយាយថា មិនយល់ដែរ ថាហេតុអីបានគេឲ្យសរសេរប្រវត្តិរូបឡើងវិញ។ ពេលលោកសរសេរនៅក្នុងប្រវត្តិរូបរបស់លោកនោះ ខ្ញុំចង់សួរថា កាលនោះ លោកមានបានសរសេរថា លោកធ្លាប់ធ្វើជាព្រះសង្ឃដែរឬទេ?

[១៤:២៤:០៨]

**ផះ** បាទ ដាក់ថាធ្វើនូវព្រះសង្ឃ។

**សៈ** អ៊ីចឹង តើការដែលលោកប្រាប់ថាលោកធ្លាប់ជាព្រះសង្ឃនេះ មានធ្វើឲ្យលោកមានបញ្ហាអ្វីដែរឬទេ? បង្កបញ្ហាអីចំពោះរូបលោកដែរឬទេ?

**ផះ** អត់ទេ មិនដែលមានបញ្ហាអ្វីទេ។

**សៈ** បាទ តាមពិតទៅ មើលទៅកាលនោះ គេដូចជាទុកចិត្តលោកទៅវិញទេ ពីព្រោះថាគេតែងតាំងឲ្យលោកធ្វើជាប្រធានកងធំ ដែលមានទំនួលខុសត្រូវខ្ពស់។ ហើយទាក់ទងនឹងប្រធានបទនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីការឆ្លើយរបស់លោកនៅឆ្នាំ២០១១ នៅពេលគេសួរចម្លើយលោក។ ពេលនោះលោកបានឆ្លើយថា មេរបស់លោកកោះប្រជុំពីរបីថ្ងៃម្តង ហើយលោកបាននិយាយពីកិច្ចប្រជុំទាំងអស់នោះ ហើយក៏បាននិយាយអំពីសន្និបាតផងដែរ ពីមីទ្និង។ ខ្ញុំមិនដឹងថាគេបកប្រែជាភាសាខ្មែរយ៉ាងម៉េចទេ ក៏ប៉ុន្តែនៅពេលដែលយើងអានកំណត់ហេតុរបស់លោក គឺថាមានសរសេរទាំងពីរគឺថាមានប្រជុំ

ហើយនិងសន្និបាត។ អ៊ីចឹងនៅពេលដែលលោកនិយាយពាក្យ "សន្និបាត" នោះលោកនិយាយថា "ក្នុងឱកាសហ្នឹង គេអនុញ្ញាតឲ្យសម្រាក"។ អ៊ីចឹងតើលោកចាំទេ ថាបាននិយាយអ៊ីចឹង? ហើយលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាបែងចែកឲ្យដាច់រវាងពាក្យថា "សន្និបាត" ហើយនិង "កិច្ចប្រជុំ"? លោកអាចពន្យល់ជូនតុលាការបានទេ ខុសគ្នាយ៉ាងម៉េចដែរ "សន្និបាត" ហើយនិង "ប្រជុំ" នេះ?

**ឆ៖** បាទ ហៅថាពាក្យ "សន្និបាត" នេះហៅថាដើម្បីសម្រាកកម្លាំង១បាទសម្រាកកម្លាំងមួយថ្ងៃ ឬពីរបីថ្ងៃ បាទហើយធ្វើហៅថា ការដើម្បីសម្រេចការងារឲ្យបានខ្លាំងក្លាតទៅមុខបាទ។

[១៤:២៦:០៧]

**ស៖** ខ្ញុំមិនដឹងថា ពាក្យដែលលោកប្រើហ្នឹងជាភាសាខ្មែរ មិនដឹងថានិយាយថាយ៉ាងម៉េចទេ បកប្រែថាយ៉ាងម៉េចទេ ប៉ុន្តែសម្រាប់ភាសាបារាំងវិញ បើសំដៅទៅលើការប្រមូលផ្តុំមនុស្សជាច្រើនដែលមកជួបគ្នា ពិភាក្សាគ្នា ហើយនិងចេញសេចក្តីសម្រេចមួយទាក់ទងនឹងប្រធានបទណាមួយ។ តើពាក្យថា "សន្និបាត" ហ្នឹង លោកសំដៅថាខ្លឹមសារសន្និបាតហ្នឹង គឺចង់និយាយថាអ៊ីចឹង ឬក៏យ៉ាងម៉េច?

**លោក ត្រាវីស ហ្វារ៖**

សាក្សីគឺថាអាច -- មេធាវីការពារក្តីអាចសួរតែអ្វីដែលគាត់បានឃើញទៅបានហើយ វាខុសពីអ្វីដែលគាត់បានឆ្លើយកាលនៅក្នុងកំណត់ហេតុនោះ។

**លោក អាកឡូវ វែកគែន៖**

លោកប្រធាន ខ្ញុំសូមបន្តទៅមុខទៀតបានទេ ពីព្រោះអីការកត់សម្គាល់របស់ព្រះរាជអាជ្ញានេះ ខ្ញុំមិនយល់។

**លោក ត្រាវីស ហ្វារ៖**

ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់បន្តិច ដោយសារខ្ញុំនិយាយលឿនពេកមុននេះ។ វាជាលំនាំនៃសំណួរនាំមុខហើយ ពីព្រោះគាត់សួរប្រាប់សាក្សីទៅ ហើយបានសួរតើសាក្សីដឹងអ៊ីចឹង ឬក៏អត់។ ជាការល្អនោះគឺគាត់ត្រូវសួរមុន មុននឹងការពន្យល់ ហើយទើបសួរជាក្រោយ។

[១៤:២៨:៣៧]

**សួរដោយលោក អាកឡូវ វែកគែន៖**

**ស៖** លោកសាក្សី ពាក្យសន្និបាតហ្នឹង មានន័យយ៉ាងម៉េចដែរ ក្រៅពីការដែលគេឲ្យលោកសម្រាករាល់ពេលដែលមានសន្និបាតនោះ? អ៊ីចឹងខ្ញុំចង់សួរលោកថាតើនៅពេលសន្និបាតម្តងៗគេនិយាយ

អំពីអ្វីខ្លះ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំបាទក៏បានឃើញ បានយល់ ពាក្យសន្និបាតនេះហៅថា ហៅទៅរួមប្រជុំមួយកន្លែង គឺមានអ្នកទៅហៅថា ចម្លើយស្រែកជយោការងារក្នុងកន្លែងនោះឲ្យបានជោគជ័យតែប៉ុណ្ណោះឯង។

**ស៖** អ៊ីចឹងនៅពេលដែលមានសន្និបាតហ្នឹង គឺថាគេបានកោះហៅអ្នកធ្វើការនៅការដ្ឋានហ្នឹងទាំងអស់ទៅសន្និបាតទេ គេហៅតែមនុស្សមួយចំនួនទេ ឬក៏យ៉ាងណា?

**ឆ៖** បាទ សម្រាកទាំងអស់ កន្លែងណាក៏សម្រាកប្រមូលផ្តុំជួបជុំគ្នាទាំងអស់ បាទទៅក្នុងមួយកន្លែងនោះ។

**ស៖** តើសន្និបាតហ្នឹងប្រព្រឹត្តទៅក្នុងរយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំម្តង?

**ឆ៖** ក្តាប់មិនបាន។ ប៉ះឆ្នាំណាទៅក៏ពីរដង បីដង មិនទៀងទេ ហើយហៅថា "សន្និបាតៗ" នេះមានហៅថា មានមេថ្នាក់លើទៅ ឲ្យឈរត្រៀមតាមថ្នល់សងខាងចម្ងាយរាប់ចំនួនថាកន្លះគីឡូម៉ែត្រ ត្រៀមបន្តៗបន្ទាប់គ្នា។

[១៤:៣១:១១]

**ស៖** តើលោកធ្វើការនៅទំនប់ត្រពាំងថ្មនុំងអស់រយៈពេលប៉ុន្មានខែដែរ គឺថាចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ៧៩នេះ? ក្រោមរបបកម្ពុជាប្រជាធិបតេយ្យនេះ លោកធ្វើការរយៈពេលប៉ុន្មានខែដែរ ឬក៏លោកធ្វើការតែរយៈពេលខ្លីមួយទេ? លោកអាចបញ្ជាក់ពីរយៈពេលច្បាស់លាស់ដែលលោកធ្វើការនៅលើទំនប់ត្រពាំងថ្មហ្នឹងបានដែរឬទេ?

**ឆ៖** ខ្ញុំបាទធ្វើ សឹងថាមួយចប់ក៏បាន។ ទាល់តែខ្ញុំហៅថា ចាប់អារម្មណ៍បានខ្ញុំមកផ្ទះ។ ចាប់អារម្មណ៍ឲ្យខ្ញុំនៅ ខ្ញុំមិននៅទេ ខ្ញុំមកផ្ទះ។ ខ្ញុំរត់មក ភ័យឡើង។ ខ្ញុំបាទមានគ្រួសារហើយ ខ្ញុំមិននៅទេ ខ្ញុំទៅផ្ទះ។ គ្រួសារខ្ញុំនៅតាមវាល នៅលើកដីតាមវាល ខ្ញុំទៅផ្ទះតែឯង។ ហើយដល់ឮថា ខ្ញុំឈប់នៅ ទៅនៅកងចល័ត ក៏គ្រួសារខ្ញុំដឹងឮក៏ទៅតាមដែរ។

**ស៖** លោកចង់និយាយថា ប្រពន្ធលោកហ្នឹងក៏រត់ចោលជួរដែរ ឈប់ធ្វើការមកតាមលោក ឬក៏យ៉ាងម៉េច?

**ឆ៖** ហៅថា ជាវ័យចាស់ហើយ អត់បញ្ហាទេ។ វ័យចាស់ទៅនៅចូលក្រុម នៅតាមភូមិ ដល់ទៅគេបញ្ចូលក្រុមនៅតាមភូមិបាន មិនអាចហៅថា តាំងនៅជាចល័តបានយូរទេ។

**ស៖** ខ្ញុំចង់សួរលោកថា តើគាត់ហ្នឹង គាត់ឈប់ធ្វើកន្លែងគាត់នុ៎ង ហើយមកតាមលោក? អ៊ីចឹង ខ្ញុំចង់សួរលោកថា លោកបានរត់ចេញពីអង្គភាពរបស់លោក ហើយប្រពន្ធលោកនុ៎ងក៏រត់ចេញពីអង្គភាពរបស់គាត់មកជួបលោកដែរ លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ហៅថា បានជាវ័យចាស់ហើយ មិនអាចនៅក្នុងកងសមរម្យបានទេ។ បាទ បានថយមកធ្វើការតាមពុកម៉ែជាធម្មតាក្នុងភូមិ។

[១៤:៣៤:២០]

**ស៖** អ៊ីចឹង គឺថាលោកមិនបានរត់ចោលជួរទេ គឺតាមពិតទៅគេតែងតាំងលោកឲ្យទៅធ្វើការកន្លែងផ្សេងទៀត កន្លែងថ្មី។ លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទទេ ខ្ញុំស្នើសុំប្រធានវរៈ ព្រោះខ្ញុំថាជាវ័យចាស់ហើយ មិនអាចតស៊ូជាចល័តកើតទេ គាត់ក៏អនុញ្ញាតឲ្យ។

**ស៖** ហើយប្រពន្ធលោកហ្នឹង ក៏ដាក់សំណើសុំអ៊ីចឹងដែរ ដូចលោកដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គ្រួសារខ្ញុំមានបញ្ហា។ កាលណោះវាជាទីបញ្ចប់ទៅក៏ កម្មាភិបាលក៏រត់រាត់រាយប្រាសខ្លួន គៀសខ្លួន ជាទីបញ្ចប់។

**ស៖** បើអ៊ីចឹងបានន័យថា តាមពិតគាត់ទេដែលជាអ្នករត់ចេញពីកន្លែងការងាររបស់គាត់ ក៏ប៉ុន្តែលោកវិញ លោកបានសុំការអនុញ្ញាតត្រឹមត្រូវ ស្នើត្រឹមត្រូវបានលោកចេញពីកន្លែងការដ្ឋានហ្នឹងមកនៅភូមិសហករណ៍លោកបាន។ លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** និយាយតាមការយល់ទៅតាមន័យការងារនោះឯងបាទ។

**ស៖** លោកសាក្សី លោកមានចាំថា គេលើកទំនប់ហ្នឹង គេចាប់ផ្ដើមលើកនៅពេលណាទេ? លោកនិយាយថា លោកបានលើកទំនប់នោះរហូតដល់ជិតៗដល់ពេលចប់។ អ៊ីចឹងខ្ញុំសួរលោកថា តើគេចាប់ផ្ដើមលើកទំនប់ហ្នឹងនៅពេលណាដែរ? លោកអាចកំណត់កាលបរិច្ឆេទបានទេ គេចាប់ផ្ដើមលើកទំនប់ហ្នឹងនៅពេលណាដែរ?

[១៤:៣៧:០៤]

**ឆ៖** ចាំអត់បានទេ។ យូរៗឆ្នាំណាស់ ភ្លេចភ្លាំងអស់ តាំងពីអាយុ២២, ២៣ ខ្ញុំយូរៗណាស់។ វាចូលៗជិតលើសហើយ ចាំអត់បានទេ។

**លោក អាកឡូវ វែកកែន៖**

លោកប្រធានខ្ញុំមើលទៅ ម៉ោងដូចដល់ម៉ោងសម្រាកហើយលោកប្រធាន តើលោកប្រធានសម្រេចយ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយមុននឹងសម្រាក សូមបញ្ជាក់ជូនលោកមេធាវី វ៉ិចទ័រ កូប៉េ ថារបាយការណ៍ជាក់ស្ដែងអំពីបញ្ហាសុខភាពសាក្សីនេះ មុននឹងមកផ្ដល់សក្ខីកម្មមិនមានទេ។ នេះគ្រាន់តែជាការសាកសួររបស់មន្ត្រីបុគ្គលិករបស់ វី.ស៊ូ ដែលពេលដែលទៅនាំយកគាត់ ទៅអញ្ជើញគាត់មកផ្ដល់សក្ខីកម្មហ្នឹងសួរគាត់អំពីបញ្ហាលទ្ធភាព ស្ថានភាពគាត់ហ្នឹងអាចមកផ្ដល់សក្ខីកម្មបានដែរឬទេ? ហើយគាត់បានថា គាត់អាចមកផ្ដល់សក្ខីកម្មបាន ប៉ុន្តែគាត់មានបញ្ហាកង្វល់មួយថា គាត់មានបញ្ហាភ្លេចភ្លាំង ដោយសារក្រោយពីគាត់មានអាការៈជំងឺ កើតជំងឺ ដើបពីឈឺអ៊ីចឹង គឺថាគាត់មានបញ្ហាអ៊ីចឹង។ ហើយគាត់នៅតែប្ដេជ្ញាថានឹងមកផ្ដល់សក្ខីកម្មឲ្យចប់បញ្ហានេះ។ នេះគ្រាន់តែជាព័ត៌មានបន្ថែម។ អ៊ីចឹងព្រឹកមិញការផ្ដល់ព័ត៌មាននេះ គឺតាមព័ត៌មានដែលគាត់បានទទួលផ្ទាល់មាត់នៅក្នុងអំឡុងពេលដែលទៅពិភាក្សាជាមួយគាត់ ដើម្បីនាំគាត់មកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតែប៉ុណ្ណោះ។

បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

លោក អាកទូរ វែកកែន កុំអាលទាន់!

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ក្នុងពេលឈប់សម្រាក គឺយើងព្យាយាមស្វែងរករបាយការណ៍ជាលាយលក្ខណ៍អក្សរ ប៉ុន្តែមិនមានរបាយការណ៍ជាលាយលក្ខណ៍អក្សរទេ។ ប៉ុន្តែនៅពេលឈប់សម្រាកលើកដំបូង សាក្សីបានប្រាប់ទៅបុគ្គលិករបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញថា គាត់បានធ្លាក់ខ្លួនឈឺថ្មីៗនេះ។ អ៊ីចឹងឯងការចងចាំរបស់គាត់អាចមិនបានល្អដូចពីមុនទេ។ ហើយព័ត៌មាននេះក៏បានជម្រាបមកមន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ហើយមន្ត្រីច្បាប់ក៏បានជម្រាបមកលោកប្រធានអង្គជំនុំជម្រះសាលាដំបូងអំពីស្ថានភាពសុខភាពរបស់គាត់នេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក អាកទូរ វែកកែន!

[១៥:00:0៤]

**លោក អាកទូរ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកកែន៖**

**ស៖** លោកសាក្សី លោកទើបតែឮលោកស្រីចៅក្រម ហ្វេនស៍ រៀបរាប់អម្បាញ់មិញហ្នឹងហើយនេះ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាលោកមានជំងឺអ្វី? ហើយលោកបាននិយាយអ្វីខ្លះប្រាប់ទៅអង្គភាពគាំពារសាក្សី?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំបាទក៏សួរ ហៅថាសុខាភិបាលនៅស្វាយ ហើយស្រុកភ្នំស្រុក ក៏វាមានរោគាជាច្រើន ច្រើនណាស់ ថាច្រើនណាស់។ ហើយខ្ញុំបាទក៏បានរក ហៅថា ពីប្រពៃណីដូចជាលោកគ្រូមេមត់សព្វបែបយ៉ាងទាំងអស់ក្នុងកូនចៅរបស់យើងខ្ញុំ។

**ស៖** ខ្ញុំមិនដឹងថា សួរលោកយ៉ាងម៉េចទេ ថាតើជំងឺរបស់លោកហ្នឹងឈ្មោះអ្វីដែរ ជំងឺអ្វីដែរ ហើយរោគសញ្ញាហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** បាទ រកសញ្ញាថាគ្មានអ្វីទេ គ្រាន់តែដល់ពេលក៏ឡើងញើស ញើសអស់កម្លាំងៗ រាប់ខែ។

តែញៀសអស់កម្លាំងៗ ដាក់ស៊ីរ៉ូមអស់រាប់ម៉ឺនបាត ខ្ញុំអស់២០.០០០បាត។

**ប្រធានអង្គជំនុំ៖**

សូមតាំងសំណួរបន្តទៅ សំណួរសារធាតុ ចូលសំណួរសារធាតុទៅលោក អាកទួរ វែកគែន។ យើងបានខិតខំប្រឹងប្រែងស្តាប់សក្ខីកម្មរបស់គាត់ជិតដល់ទីបញ្ចប់ហើយ។

[១៥:០២:៤៦]

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំនៅសល់ពេល៥៥នាទីទៀត អ៊ីចឹងប្រហែលជាខ្ញុំអាចសួរចប់ មិនបញ្ហាអ្វីទេ។ ឥឡូវនេះ ខ្ញុំគ្រាន់តែចង់ព្យាយាមចង់ដឹងអំពីអ្វីដែលទាក់ទងទៅនឹងការចងចាំរបស់គាត់ ដូចអំមិញនេះ គាត់និយាយថា គាត់បែកញៀស ហើយអស់កម្លាំងខ្លាំង។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ លោកសាក្សី ខ្ញុំនិយាយអំពីបញ្ហានេះជាមួយលោកនេះ ពីព្រោះខ្ញុំចង់ដឹងអំពីទស្សនៈ -- កន្លែងដែលលោកនៅ ពាក់ព័ន្ធទៅនឹងមនុស្សម្នាក់ដែលត្រូវបានគេសម្លាប់។ លោកបាននិយាយជាមួយសហព្រះរាជអាជ្ញាកាលពីព្រឹកមិញ ហើយអម្បាញ់មិញនេះនិយាយជាមួយលោកមេធាវី កូប៉េ ដែលបានសួរលោកទាក់ទងនឹងការសម្លាប់មនុស្សហ្នឹងដែរ។ ហើយទាំងអស់គ្នាយល់ស្របគ្នាថា អង្គាល់ដែលលោកចុះហត្ថលេខាលើចម្លើយរបស់លោកនៅឆ្នាំ២០១១ ហើយនិងអ្វីដែលលោកនិយាយនៅទីនេះនោះ គឺមានលក្ខណៈខុសគ្នា។ អ៊ីចឹងខ្ញុំចង់សួរលោកថា នៅថ្ងៃនេះនៅពេលលោកនិយាយថា លោកគ្រាន់តែបានឮស្នូរកាំភ្លើង ហើយលោកសន្និដ្ឋានថា គេបាញ់សម្លាប់មនុស្ស។ អ៊ីចឹងខ្ញុំចង់ដឹងថា តើចម្លើយដែលលោកឆ្លើយនេះថា ឮសូរស្នូរកាំភ្លើង ហើយគេថា -- លោកសន្និដ្ឋានថា គេបាញ់សម្លាប់មនុស្ស។ ខ្ញុំចង់សួរថាតើលោកចាំច្បាស់ពីរឿងហ្នឹង ឬក៏ដោយសារតែលោកមានបញ្ហានៃការចងចាំហ្នឹង បានលោកឆ្លើយប្រហាក់ប្រហែលអ៊ីចឹងទៅ លោកមិនបានឃើញ ឬក៏មិនបានឮអីនោះទេ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ ចម្លើយនេះ បញ្ហាអ៊ីចេះឯង ឮតែស្នូរ ក៏អាចថាសន្និដ្ឋានថា ការពិតនោះឯង។

[១៥:០៥:១៦]

**ស៖** អ៊ីចឹងកាលឆ្នាំ២០១១ មានរឿងអីកើតឡើងនៅពេលដែលលោកនិយាយថា លោកបានអានដើម្បីឲ្យនឹកឃើញឡើងវិញ? អ៊ីចឹងខ្ញុំសួរលោកថា ហេតុអីក៏លោកបានចុះហត្ថលេខានៅលើកំណត់

ហេតុស្តាប់ចម្លើយលោកនោះ ពីព្រោះពេលមុនហ្នឹង លោកនិយាយថា លោកបានឃើញគេបាញ់សម្លាប់មនុស្សម្នាក់ហ្នឹង ម៉េចក៏ឥឡូវហ្នឹងលោកនិយាយថា មិនបានឃើញ ហើយកាល២០១១ លោកឆ្លើយចំពោះមុខអ្នកស៊ើបអង្កេត លោកឆ្លើយថា បានឃើញ? អ៊ីចឹងខ្ញុំសួរលោកថា ហេតុអីក៏ចុះហត្ថលេខា នៅលើកំណត់ហេតុស្តាប់ចម្លើយហ្នឹង ឥឡូវនេះ លោកថាមិនបានឃើញទៅវិញ?

**ឆ៖** មិនបានឃើញទេ ព្រោះយប់ងងឹតក៏សន្និដ្ឋានថា ព្រោះវា ឃើញគេជិត គេដើរធ្វើអ៊ីចុះ ដល់ឮស្នូរអ៊ីចុះ សន្និដ្ឋានថា ដល់បាត់មនុស្សថា ទៅជាការពិតមែន។

**សៈ** ហើយកាលនោះលោកស្ថិតនៅចម្ងាយប៉ុន្មានម៉ែត្រពីមនុស្សដែលគេបាញ់សម្លាប់ហ្នឹងដែរ?

**ឆ៖** ប្រហែលជា ៥០, ៦០, ៧០ម៉ែត្រ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន សំណួរចុងក្រោយមិនច្បាស់ថាតើគាត់ត្រូវសួរថាចម្ងាយប៉ុន្មានពីអ្នកបាញ់ ឬក៏ចម្ងាយប៉ុន្មានពីជនរងគ្រោះ។ មេធាវីការពារក្តីគួរតែសួរបែបនេះ ដើម្បីបញ្ជាក់ឲ្យច្បាស់កុំឲ្យគាត់ច្រឡំ។

[១៥:០៧:៣៤]

**សួរដោយលោក អាកឡូ វែកគែន៖**

**សៈ** អ៊ីចឹងខ្ញុំសួរលោកថាលោកស្ថិតនៅចម្ងាយប៉ុន្មានម៉ែត្រពីអ្នកដែលបាញ់សម្លាប់គេហ្នឹងដែរ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** ចម្ងាយប្រហែលជា៧០ម៉ែត្រ ហើយយប់ងងឹតផង។

**សៈ** មេឃងងឹតហ្នឹង ចម្ងាយ៦០, ៧០ម៉ែត្រហ្នឹង តើលោកអាចមើលស្គាល់មនុស្សទេ ថាអ្នកណាជាអ្នកណាទេ?

**ឆ៖** អ៊ូ! មិនអាចស្គាល់ទេ ងងឹតណាស់។

**សៈ** ហើយជនរងគ្រោះនោះ លោកមានបានឃើញគាត់ដួលទេ?

**ឆ៖** អត់ៗ បានឃើញ ហៅថាឮតែស្នូរ ខ្ញុំខ្លាច ដើរគេច។

**សៈ** បាទ សូមអរគុណ។ ឥឡូវខ្ញុំត្រឡប់ចូលមកនិយាយអំពីសំណួរមួយដែលលោកមិនទាន់បានឆ្លើយនៅឡើយ ក៏ប៉ុន្តែដោយសារអម្បាញ់មិញនេះ លោកឆ្លើយចំណុចមួយដែលខ្ញុំចាប់អារម្មណ៍ អ៊ីចឹងខ្ញុំបើកវង់ក្រចកសិន។ ឥឡូវខ្ញុំសួរលោកថា ហេតុអីបាននៅខែមីនា ឆ្នាំ២០១១ លោកបានចុះហត្ថលេខាលើកំណត់ហេតុស្តាប់ចម្លើយរបស់លោក ពីព្រោះថា ខ្លឹមសារនោះមិនស្របគ្នា មិនត្រូវគ្នានឹង

ការចងចាំរបស់លោកទេ? បាទ ខ្ញុំចង់និយាយពីកំណត់ហេតុស្តាប់ចម្លើយរបស់លោកដែលចុះនៅឆ្នាំ ២០០៩។ បើខ្លឹមសារនោះមិនស្របគ្នានឹងការចងចាំរបស់លោក ហេតុអីក៏លោកចុះហត្ថលេខាទៅលើ កំណត់ហេតុស្តាប់ចម្លើយលោកនេះ?

**ផ៖** មិនយល់ទេ ស្តាប់មិនបាន។

[១៥:១០:០៥]

**ស៖** តើលោកមានចាំទេថា កាលខែមីនា ឆ្នាំ២០០៩ នោះលោកបានជួបអ្នកស៊ើបអង្កេតនៃ តុលាការខ្មែរក្រហមនេះប៉ុន្មានដងដែរ? ខ្ញុំសូមរំឭកលោកថាលោកបានជួបពួកគាត់នៅភូមិថ្មីខាងត្បូង ឃុំណាំតៅ នៅភ្នំស្រុក – ស្រុកភ្នំស្រុក។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកចាំថាបានជួបអ្នកស៊ើបអង្កេត នៅពេលនុ៎ងទេ គឺលោកបានផ្តល់កិច្ចសម្ភាសន៍ឲ្យអ្នកស៊ើបអង្កេតនៃតុលាការខ្មែរក្រហមនេះកាលនុ៎ង?

**ផ៖** បាទ បានជួបម្តង។

**ស៖** អ៊ីចឹងលោកបានជួបអ្នកស៊ើបអង្កេតហ្នឹងតែម្តងទេ ហើយម្តងហ្នឹងគឺតែមួយថ្ងៃទេ។ តើ អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ផ៖** បាទ តែមួយថ្ងៃ ហើយរយៈពេលតែមួយម៉ោងតែប៉ុណ្ណោះ។

**ស៖** តើលោកច្បាស់អំពីរយៈពេលជួបសម្ភាសហ្នឹងទេ? លោកនិយាយអម្បាញ់មិញនេះថា តែមួយ ម៉ោងទេ លោកច្បាស់ទេ?

**ផ៖** ប៉ុន្តែថា ថាប៉ុណ្ណោះ។

**ស៖** បាទ គេនិយាយប្រាប់ខ្ញុំថា បើតាមខ្សែអាត់នោះគឺថាប្រហែលជារយៈពេលពីរម៉ោង ហើយ កាលពី៦ឆ្នាំមុននេះ លោកផ្តល់កិច្ចសម្ភាសន៍ឲ្យអ្នកស៊ើបអង្កេតពីតុលាការយើងនេះ។ ក៏ប៉ុន្តែនៅក្នុង ខ្សែអាត់ហ្នឹង ធ្វើឲ្យខ្ញុំមានសំណួរមួយចង់សួរទៅលោក នៅថ្ងៃនោះអ្នកដែលសម្ភាសលោក ឈ្មោះ ឯម ហ៊ិយ ហើយនិងលោក តូម៉ាស ហ្វ្រង់ម៉ូរ៉ូ ដែលបានសួរលោក ហើយខាងពួកខ្ញុំនេះបានឲ្យគេបកប្រែខ្សែ អាត់នុ៎ង គឺនៅនាទីទី១៦ ចុងនាទីទី១៦--

[១៥:១២:៥៦]

**លោក ត្រាវីស ហ្វារ៖**

លោកមេធាវីការពារក្តីសូមផ្តល់លេខ ERN និងផ្តល់លេខឯកសារនេះផង។

**លោក អាកទូរ វែកគែន៖**

បាទ គឺឯកសារ D166/123R។ បាទ យើងបានសុំឱ្យបកប្រែ ហើយយើងមានប្រតិចារឹកជាភាសាខ្មែរ ដែលមានលេខ ERN 01132539។ នេះគឺជាការបកប្រែនៃប្រតិចារឹកហ្នឹង ខ្ញុំមិនទាន់មាននៅឡើយទេ។ តើយល់ខ្ញុំច្បាស់ហើយឬនៅ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ដើម្បីឱ្យច្បាស់ទាំងអស់គ្នា បើសិនជាខ្ញុំយល់មិនច្រឡំទេគឺថា មានប្រតិចារឹកនៃខ្សែអាត់ហ្នឹង ខ្សែអាត់នៃកិច្ចសម្ភាសន៍សាក្សីហ្នឹង ហើយលោកប្រើប្រតិចារឹកជាភាសាខ្មែរហ្នឹង ហើយនិងការបកប្រែក្រៅផ្លូវការដើម្បីចោទសំណួរទៅសាក្សីរូបនេះ។ អ៊ីចឹងមែនទេ?

[១៥:១៤:៥៨]

**លោក អាកទូរ វែកគែន៖**

បាទ ត្រូវហើយលោកចៅក្រម។ ព្រោះវាពាក់ព័ន្ធតែពាក្យមួយប៉ុណ្ណឹងទេ ហើយៗយើងនឹងអាចផ្ទៀងផ្ទាត់ចំណុចនេះបានទាំងអស់គ្នា ដោយមានជនជាតិខ្មែរនៅទីនេះស្រាប់ហើយ។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** នៅនាទីទី១៦ អ្នកស៊ើបអង្កេតលោក ហែម ហ៊ុយ -- ឯម ហ៊ុយ បាទ។ គាត់សួរថានៅក្នុងកិច្ចសម្ភាសន៍មុនរបស់លោកនោះ លោកបាននិយាយដូចតទៅនេះ អ៊ីចឹងខ្ញុំមើលទៅឃើញដូចជាគួរឱ្យឆ្ងល់ដែរ ពីព្រោះលោក ឯម ហ៊ុយ ហ្នឹងដូចជាយោងទៅនឹងជំនួបពីមុនមក។ ពីមុនមក គឺថាពួកគាត់ជួបជាមួយសាក្សីហើយ ព្រោះថាពេលសម្ភាសនេះ នាទីទី១៦តែប៉ុណ្ណឹងទេ។ អ៊ីចឹងខ្ញុំចង់សួរលោកសាក្សីថាតើលោកពិតជាប្រាកដថា បានជួបអ្នកស៊ើបអង្កេតនៃតុលាការខ្មែរក្រហមនេះ តែមួយដងទេ គឺនៅថ្ងៃទី៣១ មីនា ឆ្នាំ២០០៩ ឬក៏យ៉ាងណា? ព្រោះថានៅក្នុងខ្សែអាត់នេះ យើងឃើញថាអ្នកស៊ើបអង្កេតហ្នឹងនិយាយយោងទៅកិច្ចសម្ភាសន៍មួយដែលធ្វើកន្លងមក ពីមុនមកជាមួយលោក។ អ៊ីចឹងខ្ញុំសួរលោកថាលោកចាំទេ ចាំថាមានបានសម្ភាសជាមួយគាត់មុនខែមីនា ឆ្នាំ២០០៩ហ្នឹងទេ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ បានសម្ភាសមួយដងនៅក្នុងភូមិថ្មីខាងត្បូង ឃុំណាំតៅ ស្រុកភ្នំស្រុក បាទតែម្តងគត់។

**ស៖** អ៊ីចឹងនិយាយថាលោកជួបគាត់តែម្តងហ្នឹងទេ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ជួបតែម្តងប៉ុណ្ណោះ។

[១៥:១៧:២៩]

**ស៖** បាទ ខ្ញុំសូមអរគុណដែលបានផ្តល់ចម្លើយនេះ។ បាទ លោកប្រធាន ខ្ញុំសូមជម្រាបជូនថា បញ្ហានេះមានជាច្រើនដងហើយ ខ្ញុំចង់ឲ្យនិយាយអំពីវិធីសាស្ត្រនៃការធ្វើការរបស់អ្នកស៊ើបអង្កេត។ ខ្ញុំចង់បានសេចក្តីពន្យល់អំពីរបៀបស៊ើបអង្កេតនេះ។ ខ្ញុំដឹងថាថ្ងៃនេះមិនអាចផ្តល់ចម្លើយមកខ្ញុំបានទេ ឥឡូវខ្ញុំសូមចូលទៅសួរសំណួរមួយទៀតដែលទាក់ទងទៅនឹងផែនការ ដែលគេកំណត់ឲ្យលើកដី។ អម្បាញ់មិញនេះ គេសួរសំណួរលោកទាក់ទងនឹងផែនការដែលដាក់ទិសឲ្យនេះ។ លោកនិយាយថា ចុង និង តាវ៉ាល់ មកផ្ទៀងផ្ទាត់ផែនការពីបរិមាណដីដែលត្រូវរែក។ បាទ អ៊ីចឹងខ្ញុំចង់សួរថា ឈួង ហើយនិង តាវ៉ាល់ នេះដែលគាត់មកផ្ទៀងផ្ទាត់បរិមាណនេះ គាត់មកផ្ទៀងផ្ទាត់យ៉ាងម៉េច? គាត់មានរបៀបណា ប្រើដើម្បីត្រួតពិនិត្យការងារហ្នឹងដែលមានមនុស្សដល់ទៅ ប្រហាក់ប្រហែលដល់៣០.០០០នាក់ឯណោះ ធ្វើការនៅលើការដ្ឋានហ្នឹង? លោកដែលជាប្រធានកងធំនោះ លោកអាចជម្រាបជូនតុលាការបានទេ អំពីរបៀបបច្ចេកទេសក្នុងការផ្ទៀងផ្ទាត់បរិមាណដីដែលគេកំណត់ឲ្យរែកនេះ លើកនេះ? តើគេមាន វិធីសាស្ត្រអី ដើម្បីផ្ទៀងផ្ទាត់ថាបំពេញផែនការបាន ឬមិនបាននោះ?

**ឆ៖** បាទ ខ្ញុំបាទក៏បានហៅថាទទួលបន្ទុកពីថ្នាក់លើ កំណត់ដែលប្រគល់ឲ្យប៉ុន្មាន ចងចាំដើម្បី ហៅថាអនុវត្តទៅតាមផែនការនោះហើយ។

**ស៖** លោកសាក្សី កាលនៅសម័យនោះ តើលោកអាចកំណត់ដឹងថាបរិមាណដី២ម៉ែត្រគូបហ្នឹង ប៉ុនណាដែរ? ហើយដើម្បីឲ្យដឹងនោះ លោកធ្វើយ៉ាងម៉េច ដើម្បីវាស់ឲ្យដឹងថា អ្នកធ្វើការនៅក្រោម បង្គាប់របស់លោកនោះ ទាំង១៥០នាក់ហ្នឹង គេលើកដីគ្រប់ផែនការហ្នឹង? ចង់និយាយថា ម្នាក់២ម៉ែត្រ គូបហ្នឹង ដើម្បីឲ្យដឹងថា គេរែកបានគ្រប់ផែនការហ្នឹង លោកធ្វើយ៉ាងម៉េច?

[១៥:២០:៣១]

**ឆ៖** បានហៅថា “វាស់” ធ្វើពលកម្មហ្នឹងទៅបានសម្រេចទៅតាមទិសជាកំណត់គ្រប់ផែនការ ២ម៉ែត្រគូប។ បើអ្នកណាមិនហើយ គឺយើងខ្ញុំ ដើម្បីឯកភាពមេក្រុមៗជួយកាប់ ហៅថាបង្ហើយ សង់ ផែនការឲ្យបានសម្រេច។

**ស៖** អ៊ីចឹងខ្ញុំសួរលោកថា តើគេវាស់បរិមាណដី២ម៉ែត្រគូបហ្នឹងតាមរបៀបណាដែរ? គេប្រើ

ម៉ែត្រវាស់ គេយកឈើ ឬក៏ឫស្សីអីមកវាស់ ដើម្បីឲ្យដឹងថា សម្រេចផែនការបាន ប្រើជញ្ជីងថ្លឹង អីក៏យ៉ាងម៉េច?

**ឆ៖** បាទ គេវាស់ដោយម៉ែត្រឈើ វាស់ដោយម៉ែត្រឈើ។

**ស៖** តើលោកហ្នឹងជាអ្នកផ្ទៀងផ្ទាត់ហ្នឹង ឬក៏មានមនុស្សដែលការងារគាត់ហ្នឹង គឺសម្រាប់តែផ្ទៀងផ្ទាត់ផែនការហ្នឹងឯង ថាគេអ្នកវាស់ហ្នឹង ឬក៏លោករាល់ព្រឹកហ្នឹង លោកមក លោកមានម៉ែត្រមកវាស់ឲ្យគេក្នុងបរិវេណដីណាមួយ ហើយរសៀលល្ងាចហ្នឹងលោកត្រឡប់មកវិញ មកផ្ទៀងផ្ទាត់ខ្លួនឯង ឬក៏លោកនៅទីនុំងពេញមួយថ្ងៃតែម្ដង អត់ទៅណាទេ? តើអ៊ីចឹងខ្ញុំសួរបញ្ជាក់ថា តើលោកធ្វើយ៉ាងម៉េចដើម្បីផ្ទៀងផ្ទាត់ថា គេធ្វើការហ្នឹងសម្រេចផែនការបាន ឬក៏មិនបាន?

**ឆ៖** បាទ ខ្ញុំជាប្រធាន គឺនៅចាំក្នុងកន្លែងនោះ គ្មានដើរទៅណាបានទេ។ ចាំសម្រេចផែនការអ្នកណាដែលមិនទាន់ហើយ គឺជួយដើម្បីសម្រេចតាមប្រធានក្រុមៗ ដើម្បីឯកភាពជួយទាល់តែសម្រេចបាន។ ហើយរឿងបញ្ហាវាស់វែង ទៅដល់កន្លែង គឺប្រធានក្រុមគេវាស់ឲ្យកូនក្រុមគេ។

[១៥:២៣:៤០]

**ស៖** លោកសាក្សី ខ្ញុំមើលទៅឃើញដូចជាមិនគួរឲ្យយល់សោះ។ មានអ្នកធ្វើការដល់ទៅ៣០.០០០នាក់ឯណោះ ហើយបើត្រូវការ – តាមលោក អ្វីដែលនិយាយនេះ ថាត្រូវការអ្នកផ្ទៀងផ្ទាត់ហ្នឹងចំនួនមនុស្សស្មើនឹងអ្នករែកដែរ។ ហើយអ៊ីចឹង វាមិនដែលអ្នកណាវាស់ដល់ -- ត្រូវការពេលរាប់ម៉ោងនោះទេ។ អ៊ីចឹងខ្ញុំសូមសួរសំណួរបែបផ្សេងពីហ្នឹង។--

**លោក ត្រាវីស ហ្វារ៖**

លោកប្រធានការលើកឡើងបែបនេះ គឺមិនសមស្របទេ ពីសំណាក់មេធាវីការពារក្ដី។ គួរតែសួរថា ក្រៅពីកងរបស់គាត់នោះ នៅសល់រាប់រយរាប់ពាន់ទៀតនេះ តើគេធ្វើយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងអន្តរជាតិលោកអាចពន្យល់យើងបានទេ ថាតើវិធីសាស្ត្ររបស់លោកមកបង្រៀនភាគីម្ខាងទៀតឲ្យរៀបចំតាំងសំណួរនេះ តើលោកមានយុត្តិសាស្ត្រអន្តរជាតិឯណាដែលតម្រូវឲ្យលោកធ្វើដូច្នេះ? លោកអាចពន្យល់យើងបានទេ? យើងដូចជាឆ្លងកាត់សវនាការ៧ឆ្នាំមកនេះ យើងបាននិយាយគ្នាដូចច្បាស់លាស់ហើយ ភាគីម្ខាងទៀតអាចជំទាស់បាន។ ប៉ុន្តែមិនអាចមកបង្រៀនភាគីម្ខាងទៀតឲ្យ -- ទើបរៀន មកចូលវិទ្យាល័យរៀនតាំងសំណួរនោះឡើយ។ លោកអាចពន្យល់យើងបានទេ

ឥឡូវនេះ? ព្រោះដូចជាពីរប៉ុន្មានដងហើយ។ ក្រែងលោលោកមិនសូវចូល ឬក៏អី លោកអាចពិនិត្យមើលប្រតិចារឹកឡើងវិញ សួរសហព្រះរាជអាជ្ញាធំ ដើម្បីឲ្យដឹងពីនីតិវិធី ទម្រង់ណាខ្លះដែលយើងបានពិភាក្សាគ្នារួចហើយ ដែលមិនអាចប្រើប្រាស់នៅទីនេះបានទេ។ កន្លងមកអ្នកដែលជំទាស់លើបញ្ហានេះ គឺខាងភាគីសហព្រះរាជអាជ្ញាជំទាស់ទៅនឹងក្រុមមេធាវីការពារក្ដី អំពីការបង្ហាត់បង្រៀនឲ្យភាគីម្ខាងទៀតតាំងសំណួរនេះ។

[១៥:២៥:៤៦]

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំសូមអធ្យាស្រ័យ។ បើសិនណាជាខ្ញុំ -- គាត់មិនមែន -- គឺថាគាត់មិនជាសួរសំណួរឲ្យបានចំៗទេ ខាងមេធាវីការពារក្ដី។

**ប្រធានអង្គជំនុំ៖**

លោកអាចជំទាស់ពីការសួរមិនចំ ឬក៏សួរច្រំដែល សួរប្រភេទដែលគេ សំណួរហាមឃាត់ លោកអាចជំទាស់ ហើយបង្ហាញពីមូលហេតុនៃការជំទាស់។ ប៉ុន្តែលោកមិនអាចប្រើវិធីសាស្ត្រក្នុងការបង្រៀនភាគីម្ខាងទៀតឲ្យ ទើបនឹងចាប់ផ្ដើមរៀនតាំងសំណួរទេ។

**សួរដោយលោក អាកឡូ វែកគែន៖**

**ស៖** លោកសាក្សី ខ្ញុំសូមនិយាយអ្វីមួយប្រាប់ឲ្យលោកស្ដាប់ ហើយលោកឆ្លើយខ្ញុំ ថាតើត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ នៅក្នុងអង្គភាពរបស់លោក ការគោរពផែនការហ្នឹង ជាភាសាបារាំង ខ្ញុំមិនដឹងថាយ៉ាងម៉េចទេ តើការវាស់ដីដែលយើងវែកបានហ្នឹង គ្រាន់តែថាប៉ាន់ស្មានទេ មិនមានបច្ចេកទេសអីឲ្យច្បាស់លាស់នោះទេ គ្រាន់តែមើលនឹងភ្នែកហើយ ទាយទៅ ប៉ាន់ស្មានទៅ ថាតើសម្រេចផែនការបាន ឬមិនបាន តែប៉ុណ្ណឹងទេ គ្មានបច្ចេកទេសអ្វីឲ្យវាសុក្រឹត អស្ចារ្យនោះទេអង្កាល់នុំងនោះ តើអ៊ីចឹងមែនទេ?

[១៥:២៧:២៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ លោកសាក្សីបានជម្រាបអំពីវិធីសាស្ត្រនៅក្នុងការវាស់ម៉ែត្រនេះហើយ ថាវាស់ដោយម៉ែត្រឈើ។ ហើយសំណួរដែលសួរដោយលោក អាកឡូ វែកគែន និយាយអំពី

ការវាស់ដោយភ្នែក ថាតើការវាស់ដោយភ្នែកហ្នឹងវាត្រឹមត្រូវ វាប្រាកដប្រជា ឬក៏អត់។ ខ្ញុំគិតថា បើសិន -- សំណួរនេះគឺជាសំណួរដែលមិនសមស្រប ហើយខ្ញុំសូមជំទាស់ ដោយសារថា គាត់មិនបានសួរដើម្បីឱ្យសាក្សីនិយាយថា តើមានការវាស់ដោយភ្នែកឬទេ? បើសិនជាមានការនិយាយដោយសាក្សី ថាមានការវាស់ដោយភ្នែក ហើយលោក អាកទូរ វែកគែន សួរបែបនេះ ជាសំណួរសមស្រប។ ក៏ប៉ុន្តែចំពោះសំណួរនេះជាសំណួរមិនសមស្រប។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៥:២៨:៣១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណ។ លោកមេធាវី ពេជ អង្គ បានលើកឡើងអំមិញហើយ គាត់បាននិយាយហើយ។ អ៊ីចឹងថានៅនឹងការដ្ឋានហ្នឹង គឺមានដំបង មានម៉ែត្រដែលគេប្រើប្រាស់ដើម្បីវាស់បរិមាណដី។ អ៊ីចឹងខ្ញុំអត់យល់លោកមេធាវី អាកទូរ វែកគែន ទេ តើលោកយល់ឃើញថា ដំបងម៉ែត្រហ្នឹង ដែលគេប្រើ ម៉ែត្រឈើហ្នឹង វាស្មើនឹងមើលនឹងភ្នែក ឬក៏យ៉ាងម៉េច?

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកសាក្សី ម៉ែត្រឈើដែលលោកនិយាយថា គេប្រើសម្រាប់វាស់ហ្នឹង តើមានតែមួយទេ ឬក៏មានច្រើន? ឬក៏គេដំនៅនឹងដីទុកកន្លែងណាមួយជាប្រចាំនៅកន្លែងហ្នឹង ដើម្បីទុកវាស់ ឬក៏គេទុកនៅកន្លែងណាផ្សេង ដល់ពេលបានគេមកវាស់?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** ទេ បញ្ហានោះចងចាំចំណាំបានតើ។ ដូចជាថាហត្ថ ប៉ុន្មានហត្ថបានវាពេញមួយម៉ែត្រ គឺចងចាំទុក ដូចថាគេ២ហត្ថ ២ហត្ថដៃយើងៗ អាចសន្និដ្ឋានថាមួយម៉ែត្របាន គឺចងចាំទុកដើម្បីនឹងវាស់ប្រវែងឈើនោះ យកជាពុម្ពខ្នាត ទុកជារង្វាស់រង្វាល់ បាទ។

**ស៖** ហើយនៅក្នុងកងលោកហ្នឹងមានម៉ែត្រឈើហ្នឹងប៉ុន្មានដែរ? លោកមានអ្នកធ្វើការនៅក្រោមបង្គាប់លោកហ្នឹង១៥០នាក់ អ៊ីចឹងលោកត្រូវការម៉ែត្រឈើហ្នឹងប៉ុន្មានដែរអង្កាល់ហ្នឹង ដើម្បីវាស់ ឱ្យដឹងថា គេសម្រេចផែនការបាន ឬមិនបាននោះ?

[១៥:៣០:៣៨]

**ឆ៖** បាទ ម៉ែត្រឈើយកនឹងហត្ថទម្លាប់វាស់ម៉ែត្រ យកថា កំណត់ទៅតាមម៉ែត្រ ម៉ែត្រដែលហៅថារង្វាស់រង្វាល់ជាកំណត់នោះ ដើម្បីកាន់ទុក ដើម្បីចំណាំ ហើយនិងវាស់ហត្ថចងចាំទុក ដើម្បីវាស់បន្តទៅម៉ែត្រឈើបាទ ដើម្បីយកជាកំណត់។

**ស៖** បាទ ខ្ញុំសោកស្តាយដែរ ដែលបង្ខំចិត្តទទូចសួរលោកដដែលៗ ចម្លើយដែលខ្ញុំទទួលបានជាភាសាបារាំងនេះអត់ច្បាស់ទេ។ ខ្ញុំសួរម្តងទៀត តើគេធ្វើយ៉ាងម៉េចដើម្បីផ្ទៀតផ្ទាត់ជាប្រចាំថ្ងៃនោះ ឲ្យដឹងថា អ្នករែកដីហ្នឹងគាត់រែកដីបាន២ម៉ែត្រគូបក្នុងមួយថ្ងៃ? លោកនិយាយអម្បាញ់មិញថា គេប្រើម៉ែត្រឈើ ខ្ញុំយល់ហើយ ក៏ប៉ុន្តែមានអ្នកធ្វើការដល់ទៅ១៥០នាក់ អ៊ីចឹងខ្ញុំគ្រាន់តែសុំឲ្យលោកគិតឡើងវិញមើល ថាតើពេលពីព្រលឹមដល់ព្រលប់នោះ គេដឹងថា អ្នកធ្វើការណាម្នាក់នោះ គាត់រែកដីបានគ្រប់គ្រាន់ហើយ ឬក៏មិនទាន់គ្រប់គ្រាន់ទេ។ ខ្ញុំគ្រាន់តែចង់សួរលោកថា វាស់យ៉ាងម៉េច អីយ៉ាងម៉េច ប្រើម៉ែត្រប៉ុន្មាន?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំសូមជំទាស់ សំណួរនេះ ខ្ញុំយល់ថាសំណួរនេះបានត្រូវឆ្លើយដោយសាក្សីរួចហើយ។ សាក្សីបានឆ្លើយថា គឺមេក្រុមជាអ្នកវាស់ ហើយបានមកជួបគាត់ ហើយប្រសិនបើក្រុមណាមួយធ្វើមិនគ្រប់ គាត់ជាអ្នកសម្រេចឲ្យក្រុមផ្សេងទៀតទៅជួយក្រុមផ្សេង។ ដូច្នេះមិនមែនគាត់តែម្នាក់ឯងជាអ្នកទៅវាស់គ្រប់១៥០នាក់នោះទេ គឺមេក្រុមរបស់គាត់ដែលនៅក្រោមបង្គាប់របស់គាត់ជាអ្នកវាស់ ហើយមកជួបគាត់។ ដូច្នេះ មានមនុស្សគ្នាច្រើនដែលមកវាស់។ បាទ សូមអរគុណ។

[១៥:៣៣:០៥]

**ប្រធានអង្គជំនុំ៖**

តទៅទៀតលោក អាកទួរ វែកគែន។ ទំនងសមត្ថភាព និងលទ្ធភាពរបស់សាក្សីបានឆ្លើយតបបានកម្រិតហ្នឹងទេ។ តាមគណនាតាមបែបគណិតវិទ្យា ឬក៏កម្រិតខ្ពស់ជាងហ្នឹង ទំនងមិនអាចឆ្លើយទៅរួចទេ។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំកំពុងតែថា ធ្វើយ៉ាងណាឲ្យរកការពិតឃើញ។ ខ្ញុំមើលទៅឃើញថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងមិនចង់ដឹងការពិតដែលកើតមានឡើងនៅសម័យហ្នឹងទេ។ ខ្ញុំមើលទៅឃើញថា មិនមែនជាការជំទាស់ទេ វាទៅជាការរាំងស្ទះទៅវិញ។ ខ្ញុំ ឥឡូវនេះខ្ញុំគ្រាន់តែចង់និយាយថា--

**ប្រធានអង្គជំនុំ៖**

តទៅទៀត ឥឡូវបដិសេធហ្នឹងគឺត្រឹមត្រូវហើយ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ។ លោកមេធាវីតទៅសំណួរផ្សេងទៀត។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** លោកសាក្សី នៅពេលល្ងាច តើលោកធ្វើយ៉ាងដូចម្ដេចដើម្បីឲ្យដឹងថា អ្នកធ្វើការនោះបាន វែកដីបាន២ម៉ែត្រគូបនោះ? លោកទៅផ្ទៀងផ្ទាត់ដោយខ្លួនឯង ឬក៏លោកមានកូនចៅដើម្បីទៅវាស់វាល់ ពេលធ្វើការចប់ពេលល្ងាចហ្នឹង វាស់ឲ្យដឹងថា អ្នកវែកដីហ្នឹងវែកដីបានគ្រប់ចំនួនហើយ បរិមាណ ២ម៉ែត្រគូបគ្រប់ហើយ?

[១៥:៣៤:៤៣]

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ នៅចាំហៅថា នៅចាំដោះស្រាយមើលពិចារណាទាល់តែចប់។ អាចហៅថា គេច ចេញពីកន្លែងពលកម្មបាន។

**ស៖** ខ្ញុំចង់ចោទសំណួរចុងក្រោយមួយ។ តើប្រពន្ធលោកដែលមានកូនប្រាំមួយនាក់ហ្នឹង គឺជា ប្រពន្ធដែលលោកបានរៀបការជាមួយនៅសម័យខ្មែរក្រហមមែនទេ គឺសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** នៅសម័យលើកទំនប់អាង។

**ស៖** តើប្រពន្ធលោកហ្នឹង ដែលគឺជាស្ត្រីដែលលោកបានរៀបការនៅទំនប់ត្រពាំងថ្មហ្នឹងហើយ គឺលោកបានរៀបការជាមួយគាត់ហ្នឹងនៅចន្លោះឆ្នាំ១៩៧៥ ដល់ ៧៩ ហើយរូបគាត់ហ្នឹងជាម្ដាយរបស់ ក្មេងទាំងប្រាំមួយនាក់ កូនទាំងប្រាំមួយនាក់របស់លោកហ្នឹង។ សព្វថ្ងៃនេះ គាត់នៅតែជាប្រពន្ធលោក ដដែលអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**លោក អាកឡូរ វែកគែន៖**

បាទ ខ្ញុំអស់សំណួរហើយលោកប្រធាន។ ខ្ញុំសូមផ្ដល់វេទិកាទៅសហភាតារបស់ខ្ញុំគឺលោកមេធាវី គង់ សំអុន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក ឈុយ ហ៊ុយ! ខ្ញុំមានសំណួរខ្លីទេដើម្បីសួរបញ្ជាក់។ ដំបូងខ្ញុំចង់សួរលោកអំពីស្ថានភាពនៅស្ពានទី១ នៃទំនប់ត្រពាំងថ្ម ដែលលោកបានបញ្ជាក់កន្លងមកហើយ។ ខ្ញុំចង់សួរថា តើនៅលើទំនប់ទាំងមូល ហើយជាពិសេសនៅត្រង់កន្លែងស្ពានទី១នេះ មានអ្នកស្នាក់នៅនៅក្បែរហ្នឹងទេ?

**លោក ឈុយ ហ៊ុយ៖**

**ឆ៖** បាទ សព្វថ្ងៃៗមានច្រើនតើ លក់ដូរដូចជាផ្សារ--

**ស៖** សំណួររបស់ខ្ញុំ ខ្ញុំចង់ឲ្យលោកឆ្លើយកាលពីសម័យដែលលោកធ្វើការនៅក្នុងពេលលើកទំនប់អាងត្រពាំងថ្មនោះបាទ។

**ឆ៖** សម័យនោះគ្មានទេ មានតែកម្លាំងៗពលកម្ម។

**ស៖** បាទ ខ្ញុំចង់សួរពីកម្លាំងពលកម្មហ្នឹង តើមានអ្នកដែលតាំងនៅ ឧទាហរណ៍ធ្វើជារោងស្នាក់នៅ ដូចជាលោកជាដើមដែលលោកបានថា ក្រុមរបស់លោកបានធ្វើរោងស្នាក់នៅនៅក្បែរកន្លែងការដ្ឋាននោះ។ អ៊ីចឹងខ្ញុំចង់សួរថា នៅក្បែរទំនប់ (សុំទោស) នៅក្បែរស្ពានទី១ នៃទំនប់ត្រពាំងថ្មនោះមានមនុស្សរស់នៅដែរទេ? បានន័យថាមានអ្នកធ្វើរោងស្នាក់នៅក្បែរនោះទេ?

[១៥:៣៩:៣៧]

**ឆ៖** អត់មានទេ មានតែអ្នកពលកម្មលើកទំនប់នោះឯង។

**ស៖** លោកចង់បញ្ជាក់ថាម៉េច មានតែអ្នកពលកម្មលើកទំនប់ហ្នឹង? មានន័យថាមានតែពលកម្មឬក៏ពលករដែលលើកទំនប់ទាំងអស់នោះជាអ្នកនៅ ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ មានតែអ្នកហៅថា លោកដែលមានហៅថាវាម្ចាស់ទំនប់ គណៈទទួលខុសត្រូវ ហើយនិងពួកកូនដែលពលកម្មដែលត្រូវលើកដី។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីចំនួនអ្នកដែលនៅ ឬក៏ធ្វើរោងនៅក្បែរស្ពានទី១ហ្នឹងបានទេ ប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ចាំមិនបានទេ។ ភាគច្រើនណាស់ គឺថាកន្លែងអ្នកណាគេ អ្នកនោះធ្វើ ដោះស្រាយទៅ

ហៅថាក្រុម កង។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារ E3/5283 ដែលជាឯកសារស្ដាប់ចម្លើយ – កំណត់ហេតុស្ដាប់ចម្លើយរបស់លោក ត្រង់ ERN ជាភាសាខ្មែរ 00295943, ភាសាអង់គ្លេស 00322198, ភាសាបារាំង 00702920។ ក្នុងចម្លើយរបស់លោកទាក់ទងទៅនឹងសំណួរដែលលោកឆ្លើយទាក់ទងនឹង តាវ៉ាល់ លោកបានឆ្លើយថា៖ “ពួកគេស្នាក់នៅស្ថានទី១។” ខ្ញុំចង់សួរថា តើក្រុមរបស់ តាវ៉ាល់ ហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ លោកបានដឹងទេ?

[១៥:៤២:៥៦]

**ឆ៖** បាទ មិនយល់ដល់ទេ ព្រោះហៅថាមិនមានកំណត់ទេ។ គាត់មានហៅថាឡានចេញចូលៗ ក៏យើងខ្ញុំក៏មិនយល់ដល់ដែរ ចេញចូលមិនដឹងគាត់ទៅឯណា មកឯណាអី ទៅមកៗ។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំបន្ទាប់មិនទាក់ទងនឹង តាវ៉ាល់ ទេ ប៉ុន្តែទាក់ទងទៅនឹងអ្នកផ្សេងទៀតនៅក្នុងក្រុម ឬក៏អាចអ្នកថាជិតដិតជាមួយនឹង តាវ៉ាល់។ ថាតើកន្លែងដែលស្នាក់នៅរបស់ តាវ៉ាល់ នេះ មានអ្នកនៅជាប្រចាំទេ នៅពេលដែល តាវ៉ាល់ មិននៅ?

**ឆ៖** មានតើ មានអ្នកហៅថា គេហៅថាជាអ្នកភស្តុភារដំណោះស្រាយ ហើយម្ហូបអាហារនៅប្រចាំ។

**ស៖** បាទ សូមអរគុណ។ តាមដែលលោកដឹង តើស្នាក់ការដែល តាវ៉ាល់ ធ្វើនៅក្នុងស្ថានទី១ នោះចាប់ផ្ដើមកសាងពីពេលណា ហើយនៅរហូតដល់ពេលណាដែរ?

**ឆ៖** បាទ មិនយល់ដល់ទេ ភ្លេចភ្លាំងអស់។ ខ្ញុំបាទធ្វើតាំងពីៗចប ធ្វើដល់គ្រឿងចក្រ មានអាសានី ចាំអត់បានទេខែថ្ងៃ។

**ស៖** បាទ ខ្ញុំអត់យល់ពីសំណួររបស់លោក។ តើលោកចង់បញ្ជាក់ថា នៅទីស្នាក់ការនោះ មានអាសានី គ្រឿងចក្រនៅក្បែរនោះដែរ ឬយ៉ាងម៉េច?

**ឆ៖** បាទ មានជាច្រើន។ មានតែពីរឡាន ហើយដូចជា គ្រឿងចក្រអាសានីអីរាប់ទៅប្រាំមួយប្រាំពីរគ្រឿង។

[១៥:៤៥:៤១]

**ស៖** បាទ សូមអរគុណ។ ចុះក្រោយពីបាត់ខ្លួន តាវ៉ាល់ តើទីស្នាក់ការហ្នឹងមានអ្នកផ្សេងទៀតប្រើប្រាស់តទៅទៀតទេ? អាចមានអ្នកមេដឹកនាំថ្មីណា គេមកជំនួស ប្រចាំការនៅទីស្នាក់ការហ្នឹង

ដដែលទេ?

**ឆ៖** បាទ ខ្ញុំក៏មិនបាននៅប្រចាំទល់ចប់ក្នុងកន្លែងអាងនោះទេ គឺមកនៅហៅថា ភូមិបុស្សស្បូវ ធ្វើស្រែប្រាំង។ គេឲ្យធ្វើស្រែប្រាំង ក៏ខ្ញុំធ្វើបានហៅថា រយៈតែមួយខែអីនេះ ក៏ខ្ញុំដូចថាបញ្ហាដូចមុន និយាយប្រាប់ថា ខ្ញុំសុំមេទៅផ្ទះ ខ្ញុំសុំទៅផ្ទះ។ បញ្ហានោះ មិនដឹងថាគាត់ដើរបាត់ទៅខាងណា ក៏អត់ដឹង។

**ស៖** បាទ សូមអរគុណ។ តាមអ្វីដែលខ្ញុំស្ដាប់បាន នៅពេលដែលលោករៀបការហើយ លោកសុំទៅផ្ទះ គឺជាពេលមួយដែលជិតដាច់របបកម្ពុជាប្រជាធិបតេយ្យហើយ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ជិតចប់ហើយ ដែលខ្ញុំមកហៅថា ទៅផ្ទះ។ អត់ដឹងហៅថាទៅយ៉ាងណាទេ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមចូលប្រធានបទមួយទៀត ទាក់ទងទៅនឹងសក្ខីកម្មរបស់លោកកាលពីព្រឹកមិញនេះ លោកបានឆ្លើយទាក់ទងទៅនឹងការដកតំណែងរបស់លោក ពីប្រធានកងធំឲ្យទៅបោចរពាក់ និងធ្វើបង្គី។ ខ្ញុំចង់សួរលោកថា (សូមទោស) ខ្ញុំចង់បន្ថែមទាក់ទងទៅនឹងព័ត៌មានដែលលោកបានបញ្ជាក់ គឺថាខណៈនោះ គឺលោកមានជំងឺ ហើយដែលមានគេចោទថា លោកមានជំងឺសតិអាម្មរណ៍។ ដូច្នេះបានជាគេដកលោកចេញពីប្រធានកងធំ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីបទពិសោធន៍របស់លោក ក្នុងការងារលើកទំនប់ រែកដីនៅត្រពាំងថ្ម ហើយនិងការងារទៅបោចវល្លិ៍បោចរពាក់ធ្វើបង្គីនេះ តើការងារណាធ្ងន់ជាងការងារមួយណា?

[១៥:៤៨:៤៤]

**ឆ៖** បាទ ខ្ញុំបាទរាយការណ៍ជូនហៅថា បញ្ហានោះដែលខ្ញុំមិនបាន ហៅថាចុះទៅប្រឡូកក្នុងសមរភូមិ ក៏ប្រធានវរៈមានបញ្ហាជាមួយខ្ញុំថា ខ្ញុំមិនធ្វើការ ខ្ញុំហៅថា មិនស្រួលក្នុងខ្លួន ខ្ញុំមិនបានចុះទៅប្រកាន់ទុកថា ខ្ញុំមិនធ្វើ។ ដល់នេះបានន័យថា ចាត់ន័យថា ខ្ញុំមិនធ្វើ ថាខ្ញុំសតិអារម្មណ៍។ ម៉្លោះហើយបញ្ជូនខ្ញុំឲ្យចេញពីកង បាទចេញពីកង។ ហើយខ្ញុំក៏បានទៅតាមទិសផែនការប្រគល់ឲ្យមួយថ្ងៃធ្វើបានប្រាំបង្គី ឬដប់បង្គី ក៏ខ្ញុំបាទនឹងគោរពផែនការបាន។ ដល់ខ្ញុំគោរពផែនការបាន ហៅខ្ញុំមកឲ្យចូលកន្លែងដដែលវិញ។ បាទ មានតែប៉ុណ្ណោះ។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំ គឺខ្ញុំចង់ដឹងពីស្ថានភាពនៃការងារ ថាតើការងារណាវាធ្ងន់ធ្ងរជាង បើប្រៀបធៀបការងារទាំងពីរដែលលោកបានធ្វើជាមេកងនៅទំនប់ត្រពាំងថ្ម ហើយនិងការងារបោចរពាក់ធ្វើបង្គីនោះ លោកអាចប្រៀបធៀបបានទេ? ការងារណាដែលមានការទទួលខុសត្រូវខ្លាំងជាង ហើយវាមានការលំបាកជាង លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ វាដូចតែគ្នាទេ។ ម៉េចបានថាដូចតែគ្នា រពាក់ក៏មិនងាយថា គោលដៅទៀងទាត់ ដើររកសម្លឹងសព្វបែបសព្វយ៉ាង គ្រប់ទីកន្លែង ទាល់តែបាន។ បាទ មិនធម្មតាទេ វាលំបាកដូចគ្នាបាទ។

**សៈ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីរយៈពេលដែលលោកទៅធ្វើការបោចរពាក់នោះបានទេ ហើយធ្វើបង្គីនោះ?

**ឆ៖** បញ្ជាក់យ៉ាងណា?

[១៥:៥១:៣៣]

**សៈ** បាទ ខ្ញុំចង់និយាយអំពីរយៈពេលដែលលោកទៅធ្វើការបោចរពាក់ ហើយនិងធ្វើបង្គីនេះ លោកធ្វើក្នុងរយៈពេលប៉ុនណា យូរប៉ុនណា ឬក៏ឆាប់ប៉ុនណា លោកអាចបញ្ជាក់បានទេ?

**ឆ៖** ធ្វើមិនទៀងទាត់ កាលណោះចាំអត់បាន រយៈកាលថាពីរអាទិត្យ ហើយនិងទៅបីអាទិត្យ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកសាក្សីខ្ញុំអស់សំណួរ។ លោកប្រធាន ខ្ញុំអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៥ ខែសីហា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃស្អែក -- អញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមនិយាយសង្ខេបទេ គឺថាយើងទទួលបានពីមន្ត្រីច្បាប់ជាន់ខ្ពស់ ពាក់ព័ន្ធទៅនឹងឯកសារសំខាន់ៗមួយចំនួន។ យើងខ្ញុំសូមស្នើទាក់ទងទៅនឹងការអនុវត្តជាក់ស្តែង ប្រហែលជាពេលវេលាយ៉ាងហោចណាស់ គឺសម្រាប់ព្រឹកថ្ងៃស្អែក នៅវគ្គដំបូង សូមលើកឡើងពាក់ព័ន្ធទៅនឹងឯកសារដែលយើងខ្ញុំទើបតែទទួលបានព័ត៌មាន គឺសវនាការអំពីឯកសារគន្លឹះនេះ។

[១៥:៥៣:៤៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី លោកត្រូវការរយៈពេលប៉ុន្មានដើម្បីដាក់សំណើនេះ? តើមីក្រូប្រតិបត្តិការទេ? លោកស្តាប់ឮទេ? លោកមេធាវីសូមជម្រាបជូនមកអង្គជំនុំជម្រះផង លោកត្រូវការពេលប៉ុន្មាន?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចស្នើសុំនៅពេលនេះក៏បានដែរ លោកស្រីចៅក្រម ខ្លីទេ។ គំនិតយោបល់របស់ខាងយើងខ្ញុំនេះ គឺថាត្រូវដាក់សំណើមួយសម្រាប់ការដ្ឋានការងារមួយកន្លែង។ ហើយក្រោយមកខាងផ្នែកព្រះរាជអាជ្ញា មេធាវីនាំមុខគឺថាអាចឆ្លើយតប យើងអាចមានការប្រតិកម្មទៅតាមនោះ ហើយឆ្លើយតបទៅតាមនោះ។ ហើយយើងខ្ញុំនេះ កាលពីសប្តាហ៍មុន រកឃើញថាមានឯកសារគន្លឹះជាច្រើនដែលយើងខ្ញុំយល់ឃើញថា ពាក់ព័ន្ធទៅនឹងការដ្ឋានទាំងបីកន្លែងនេះ។ រហូតមកទល់ឥឡូវនេះ គឺថា យើងបានកំណត់ឯកសារចំនួន៣០សម្រាប់ការដ្ឋានទាំងនេះ ហើយក្នុងនោះ២២ទៅ២៣ឯកសារ ពាក់ព័ន្ធទៅនឹងការដ្ឋានការងារមួយកន្លែងៗ។ អ៊ីចឹងឯងបានជាយើងខ្ញុំគិតថា គឺថាព្រះរាជអាជ្ញាត្រូវមានពេលមួយថ្ងៃពេញជាមួយមេធាវីនាំមុខសម្រាប់ការដ្ឋានការងារនីមួយៗ ហើយថ្ងៃបន្ទាប់យើងមានពេលវេលាសម្រាប់មេធាវីការពារក្តីសម្រាប់ការដ្ឋានទាំងអស់។ ហើយបន្ទាប់មក ទើបឲ្យភាគីទាំងអស់មានការឆ្លើយតបជំទាស់តវ៉ា មានប្រតិកម្មទៅវិញទៅមកទៅនឹងការលើកឡើងអំពីឯកសារទាំងអស់នេះ។ ដូច្នេះបញ្ហាអនុវត្តជាក់ស្តែងនោះ គឺយើងខ្ញុំអាចជឿជាក់ថា ត្រូវតែដាក់សំណើពាក់ព័ន្ធទៅនឹងឯកសារគន្លឹះៗ ដែលពាក់ព័ន្ធទៅនឹងការដ្ឋានការងារនីមួយៗ។

[១៥:៥៦:១៥]

**លោក អាកទូរ វែកគែន៖**

បញ្ជាក់បន្ថែមអំពីមេធាវី កូប៉េ។ ខ្ញុំសូមបញ្ជាក់ថា វាជារឿងស្មុគស្មាញក្នុងការដឹងអំពីឯកសារដែលនឹងបង្ហាញដោយភាគីផ្សេងៗ ពីព្រោះនៅថ្ងៃស្អែកនេះ យើងក៏មានសវនាការ។ ហើយនៅក្នុងថ្ងៃដដែលនោះ គឺមានការ តម្រូវឲ្យមានការឆ្លើយតបទៅនឹងការបង្ហាញឯកសារ។ ដូច្នេះ ខ្ញុំមើលទៅថា យើងពិបាកឆ្លើយតបណាស់ ពីព្រោះថា យើងអត់មានពេលគ្រប់គ្រាន់សម្រាប់ធ្វើការនោះទេ។ នេះជាការកត់សម្គាលទី១។ ការកត់សម្គាលទី២ ដើម្បីចៀសវាងនូវបញ្ហាផ្សេងៗដូចដែលបានកើតឡើងនៅក្នុងសវនាការអំពីឯកសារគន្លឹះកាលពីលើកមុន។ ខ្ញុំចង់ដឹងថា តើការរៀបចំតាមលំដាប់លំដោយ នៃទីតាំងការដ្ឋានការងារហ្នឹង វាជាអ្វីដែលអង្គជំនុំជម្រះបានសម្រេចក្នុងការច្រានចោលឯកសារផ្សេងៗ ដែលមិនជាប់ពាក់ព័ន្ធ ជាពិសេសទៅនឹងការដ្ឋានទាំងបីនោះ ឬក៏យ៉ាងណា? ឧទាហរណ៍ដូចជាកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ដែលបង្ហាញអំពីគោលនយោបាយទូទៅ ឧទាហរណ៍សៀវភៅរបស់អ្នកនិពន្ធណាមួយ ដែលលើកឡើងអំពីបញ្ហាពាក់ព័ន្ធនឹងភូមិភាគជាទូទៅ ឬក៏បញ្ហាពាក់ព័ន្ធនឹងម្ហូបអាហារ ឬក៏ការបង្ក

បង្កើនស្រូវជាលក្ខណៈទូទៅ។ ដូច្នេះ តើយើងគួរតែរៀបចំសវនាការដូចដែលអង្គជំនុំជម្រះបានសម្រេចកាលពីលើកមុន ពាក់ព័ន្ធអំពីឯកសារគន្លឹះ ឬក៏យ៉ាងម៉េច? គឺថាតម្រូវឱ្យមានការកំណត់ជាក់លាក់ទៅលើការដ្ឋានណាមួយតែម្តង ឬក៏យើងអាចបង្ហាញឯកសារជាលក្ខណៈទូលំទូលាយ។ អ៊ីចឹងខ្ញុំចង់បានការបញ្ជាក់ឱ្យបានច្បាស់។ ទី១ គឺបញ្ហាពាក់ព័ន្ធនឹងពេលវេលាក្នុងការឆ្លើយតបទៅនឹងការបង្ហាញ ហើយទី២ គឺបញ្ហាវិសាលភាពនៃការបង្ហាញឯកសារទាំងអស់នេះ។

[១៥:៥៨:៤៤]

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខាងការិយាល័យសហព្រះរាជអាជ្ញាមិនមានទស្សនៈអ្វីតឹងរ៉ឹងទៅលើឯកសារទាំងអស់នេះទេ។ គឺយើងខ្ញុំយល់ឃើញថា ទី១គឺត្រូវជ្រើសរើសឯកសារណាដែលពាក់ព័ន្ធទៅនឹងដំណាក់កាលនៃសវនាការនេះតែម្តង ហើយបានយើងយកឯកសារទាំងអស់នោះ មកនិយាយពាក់ព័ន្ធទៅនឹងដំណាក់-កាលនៃការជំនុំជម្រះរួមតែម្តង។ ប៉ុន្តែដំបូងគឺថា យកឯកសារពាក់ព័ន្ធទៅនឹងការដ្ឋាននីមួយៗនេះប្រហែលជាបញ្ហាមួយដែលអាចនឹងមានប្រយោជន៍នៅក្នុងការលើកឡើងពីករណីជាក់ស្តែងនីមួយៗ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានការជំទាស់អ្វីទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជាទេ។ ខ្ញុំគិតថា របៀបធ្វើការបែបនេះ គឺមានលក្ខណៈងាយស្រួលជាងសម្រាប់យើងដើម្បីឱ្យយើងអាចដឹងអំពីឯកសារទាំងអស់បាន ក៏ប៉ុន្តែអ្វីៗគឺសម្រេចទៅលើបញ្ហានេះ ដោយអង្គជំនុំជម្រះ។ យើងនឹងគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវមតិយោបល់ដែលបានលើកឡើងនេះ។ យើងគិតថាអ្វីដែលអង្គជំនុំជម្រះបានរៀបចំនេះ យើងបានស្តាប់មតិរបស់ភាគី ហើយមានមតិភាគីមួយចំនួនបានផ្តល់ជូន ហើយយើងបានជម្រើសយកជម្រើសនេះ ដោយគិតថាជម្រើសនេះជាជម្រើសល្អបំផុតនៅក្នុងការរៀបចំដាក់បង្ហាញឯកសារគន្លឹះនេះ។ តែទោះបីយ៉ាងណា យើងនឹងលើកយកមតិយោបល់របស់ភាគីដែលបានលើកឡើងអម្បាញ់មិញនេះយកទៅពិចារណា ហើយនិងជម្រាបជូនដល់ភាគីនៅថ្ងៃស្អែក ឱ្យបានមុនពេលដែលយើងដំណើរការសវនាការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ។

[១៦:០០:៣២]

ហើយខ្ញុំក៏សូមបញ្ជាក់ជូនលោក អាកទួរ វែកគែន ផងដែរថា យើងបានជម្រើសយកពេលវេលានេះ គឺល្អណាស់ដោយសារយើងយកថ្ងៃ២៦ និងថ្ងៃ២៧ គឺដាក់បង្ហាញរបស់ឯកសាររបស់ភាគីទាំងសងខាង ហើយយើងនៅសល់ថ្ងៃសុក្រ ហើយបើអាចធ្វើការងារបានបន្ថែមទៀត រហូតដល់ថ្ងៃសៅរ៍ ថ្ងៃអាទិត្យនោះ គឺយើងមានឱកាសច្រើនក្នុងការត្រួតពិនិត្យដើម្បីដល់ពេល យើងដល់ថ្ងៃ៣១ យើងបានធ្វើសវនាការទី៣ ដែលជាថ្ងៃពិភាក្សា -- ថ្ងៃជំទាស់តវ៉ាលើបញ្ហាឯកសារនេះ។ នេះគឺយើងបានកំណត់គោលការណ៍នៅក្នុងការដាក់កាលវិភាគ ដូចបានជូនភាគីរួចហើយ កាលពីថ្ងៃទី១៩ ខែសីហា កន្លងទៅ។ ហើយទំនងជាខ្ញុំនិយាយភ័ន្តច្រឡំបានជាលោក វ៉ិចទ័រ កូប៉េ គ្រវីក្បាល។ យើងបានឃើញថា កម្មវិធីនៃការដាក់ឯកសារគឺថ្ងៃទី២៦ និងថ្ងៃ២៧ និងថ្ងៃ៣១។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំធ្វើកាយវិការដែររបស់ខ្ញុំនេះ គឺជារឿងមួយផ្សេងទេ។ តាមការពិត យើងមានថ្ងៃចន្ទចុងសប្ដាហ៍ដើម្បីអាន ហើយនិងធ្វើការឆ្លើយតប ឬក៏មានប្រតិកម្មទៅនឹងបញ្ហាឯកសារនេះ។ យើងខ្ញុំមិនមានបញ្ហាជាមួយនឹងការកំណត់ពេលវេលានេះទេ។

[១៦:០២:៣២]

**ប្រធានអង្គជំនុំ៖**

ខ្ញុំបញ្ជាក់សាឡើងវិញ យើងនឹងយកបញ្ហាដែលលើកឡើងរបស់ភាគីនៅពេលនេះ នឹងពិចារណា ហើយនិងជម្រាបជូនភាគីនៅបញ្ជាក់បន្ថែមនៅថ្ងៃស្អែក។ យើងជម្រាបជូនហើយអំមិញ។

បាទ ហើយសាជាថ្មីម្ដងទៀត សវនាការលើកទៅធ្វើនៅថ្ងៃស្អែក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-269 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ការស្ដាប់សក្ខីកម្មរបស់លោកបានចប់ហើយ លោក ឈុយ ហ៊ុយ ហើយអង្គជំនុំជម្រះសូមអរគុណលោក ឈុយ ហ៊ុយ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរយៈពេលមួយថ្ងៃនេះ។ ហើយសក្ខីកម្មរបស់លោក អាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ហើយវត្តមានរបស់លោកនៅពេលនេះ លែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។

សូមលោកវិលត្រឡប់ទៅប្រកបដោយសុវត្ថិភាព មានសំណាងល្អ បានសេចក្ដីសុខ សេចក្ដីសប្បាយ។

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី។ សវនាការស្ដាប់សក្ខីកម្ម ឈុយ ហ៊ុយ បានដល់ទីបញ្ចប់ហើយ ដូច្នេះ លោកអាចសម្រាកបានហើយ។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញជូនលោក ឈុយ ហ៊ុយ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ ហើយនិងជូនដើមបណ្ដឹងរដ្ឋប្បវេណីបម្រុង 2-TCCP-269 ទៅកាន់កន្លែងគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់មកចូលរួមមកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*